ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ទស្សនៈរបស់នាយក គ្រូ សិស្ស និង សហគមន៍ចំពោះ ការរៀបចំបរិស្ថានសិក្សានៅកម្រិតបឋមសិក្សា ក្នុងខេត្តតាកែវ

# PRINCIPALS, TEACHERS, STUDENTS AND COMMUNITY PERCEPTIONS OF THE LEARNIG ENVIROMENT AT THE PRIMARY LEVEL IN TAKEO PROVINCE

ដោយ/ by

លឿង កុសល/ Ms Loeung Kosal

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល

ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី ១០

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២១-២០២៣

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ទស្សនៈរបស់នាយក គ្រូ សិស្ស និងសហគមន៍ ចំពោះ ការរៀបចំបរិស្ថានសិក្សានៅកម្រិតបឋមសិក្សា ក្នុងខេត្តតាកែវ

# PRINCIPALS, TEACHERS, STUDENTS AND COMMUNITY PERCEPTIONS OF THE LEARNIG ENVIROMENT AT THE PRIMARY LEVEL IN TAKEO PROVINCE

ដោយ/ by

លឿង កុសល/ Ms Loeung Kosal

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល

ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី ១០

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២១-២០២៣

គ្រូណែនាំគោល ៖ បណ្ឌិត នី រដ្ឋា

គ្រូណែនាំរង ៖ ឯកឧត្តមបណ្ឌិត សិត សេង

# សេចក្តីអះអាងរបស់បេក្ខនារី

នាងខ្ញុំឈ្មោះ **លឿង កុសល** សូមបញ្ជាក់ថានិក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា «**ទស្សនៈរបស់នាយក គ្រូ សិស្ស និងសហគមន៍ ចំពោះការរៀបចំបរិស្ថានសិក្សានៅកម្រិតបឋមសិក្សាក្នុងខេត្តតាកែវ**» សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ គឺពិតជាស្នាដៃរបស់នាងខ្ញុំទាំងស្រុង។ ស្នាដៃនេះពុំទាន់ត្រូវបានគេយកមកប្រើប្រាស់ ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលបានសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណាមួយឡើយ។ ហើយពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះពិតជាត្រូវបានស្រាវជ្រាវ និងចងក្រងដោយនាងខ្ញុំពិតប្រាកដមែន។

ថ្ងៃ **សុក្រ ១១ រោច** ខែ **កត្តិក** ឆ្នាំ **ថោះ** បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០២៣

**ហត្ថលេខា**

Konsal

**លឿង កុសល**

# លិខិតបញ្ជាក់

**គ្រូណែនាំគោល ៖ បណ្ឌិត នី រដ្ឋា**

**គ្រូណែនាំរង ៖ ឯកឧត្តមបណ្ឌិត សិត សេង**

**សូមបញ្ជាក់ និងទទួលស្គាល់ថា**

កញ្ញា **លឿង កុសល** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី ១០ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវលើប្រធានបទស្តីពី « **ទស្សនៈរបស់នាយក គ្រូ សិស្ស និងសហគមន៍ ចំពោះការរៀបចំបរិស្ថានសិក្សានៅកម្រិតបឋមសិក្សាក្នុងខេត្តតាកែវ**» ពិតប្រាកដមែន។

ថ្ងៃ សុក្រ ១១ រោច ខែ កត្តិក ឆ្នាំ ថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០២៣

.......................................... ..........................................

**បណ្ឌិត នី រដ្ឋា**

ប្រធានការិយាល័យសិក្សា នៃវិទ្យាស្ថានជាតិអប់រំ

**ឯកឧត្តមបណ្ឌិត សិត សេង**

នាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខៈ** ៣៤៧៣ **អយក.ខុទន**

(**ការសម្ងាត់**)

## លិខិតឧទ្ទេសនាម
## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

**យោង៖** - បទប្បញ្ញត្តិស្ដីពីការបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

- ផែនការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា ២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។
- សំណើសុំដូរកាលបរិច្ឆេទរៀបចំការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្នាក់ដឹកនាំ និងបុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការមេប្រយោគ** សម្រាប់ការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៨-០៩ ខែធ្នូ ឆ្នាំ២០២៣ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិតសភាចារ្យ | ហង់ជួន ណារ៉ុន | ក្រសួង អយក | ប្រធាន |
| ២-ឯកឧត្តម | អ៊ុង បូរាត | ក្រសួង អយក | អនុប្រធាន |
| ៣-ឯកឧត្តម | លាង សេងហាក់ | ក្រសួង អយក | សមាជិក |
| ៤-ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥. ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-ឯកឧត្តមបណ្ឌិត | សិត សេង | វិទ្យាស្ថានគរ.ភ្នំពេញ | សមាជិក |
| ៧-លោកបណ្ឌិត | នូវ វ៉ៅ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោកបណ្ឌិត | ឈូក ច័ន្ទឆាយា | នាយកដ្ឋានបវ. | សមាជិក |
| ១២-លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃព្រហស្បតិ៍ ៣រោច ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- អគ្គនាយកដ្ឋានរ.ហិ អគ្គនាយកដ្ឋានឧស.
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទអយកដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារៈ វិទ្យាស្ថានជាតិអប់រំ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខ**...៤៥០១...**អយក.ខុធន**

(**ការសម្ងាត់**)

**លិខិតឧទ្ទេសនាម**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**យោង៖** - បទប្បញ្ញត្តិស្ដីពីការបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

- ផែនការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ ចុះថ្ងៃទី២៣ ខែធ្នូ ឆ្នាំ២០២២។
- សំណើសុំដូរកាលបរិច្ឆេទរៀបចំការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ឆ្នាំសិក្សា២០២២-២០២៣ នៅវិទ្យាស្ថានជាតិអប់រំ។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទស្រាវជ្រាវបញ្ចប់** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី១០ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០៨-០៩ ខែធ្នូ ឆ្នាំ២០២៣ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិត ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២. លោកស្រីបណ្ឌិត បូ ច័ន្ទគុលិកា | នាយកដ្ឋានគោលនយោបាយ | អនុប្រធាន |
| ៣. លោកបណ្ឌិត កាន់ ពុទ្ធី | នា.បឋមសិក្សា អយក. | សមាជិក |
| ៤. លោក ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥. លោកស្រី សាំង សុចិន្តា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦. លោកបណ្ឌិត មាឃ ចាន់ថេង | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ៧. លោកបណ្ឌិត អែ សុងហ៊ាង | SEAMEO TED អយក | សមាជិក |
| ៨. ឯកឧត្តមបណ្ឌិត ប៉ិច សៀង | វិ.បច្ចេកវិទ្យាកំពង់ឈើទាល | សមាជិក |
| ៩.លោកបណ្ឌិត លី គឹមឡុង | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ១០.លោក ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១.លោក លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២. លោកបណ្ឌិត អាន រ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣. លោកស្រី នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤. លោកស្រី បណ្ឌិត ឡឹយ សុខគា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥. លោកបណ្ឌិត អ៊ុំម គឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦. លោកបណ្ឌិត ទី សុផល | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧. លោកបណ្ឌិត គួយ សូគាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨. លោកបណ្ឌិត សោន វណ្ណៈ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩. លោកបណ្ឌិត ឈន ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០. លោកបណ្ឌិត សឿង សុផា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១. លោក ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

| | | |
|---|---|---|
| ២២. លោកបណ្ឌិត សោភទ្រា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣. លោក ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤. លោក ចាន់ រ៉ាដា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

លោក និងលោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិត នៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០២៣ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃព្រហស្បតិ៍ ៣រោច ខែ កត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- អគ្គនាយកដ្ឋានរ.ហ៊ អគ្គនាយកដ្ឋានឧស.
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទអយកដែលមានការពាក់ព័ន្ធ
  "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន " ដើម្បីអនុវត្ត "
- កាលប្បវត្តិ
- ឯកសារៈ វិទ្យាស្ថានជាតិអប់រំ

# មូលន័យសង្ខេប

ការស្រាវជ្រាវនេះ សិក្សាលើប្រធានបទស្តីពី «**ទស្សនៈរបស់ នាយក គ្រូ សិស្ស និងសហគមន៍ចំពោះការរៀបចំបរិស្ថានសិក្សានៅកម្រិតបឋមសិក្សាក្នុងខេត្តតាកែវ**» ដើម្បីសិក្សាឈ្វេងយល់ពីស្ថានភាពការរៀបចំបរិស្ថានសិក្សានៅកម្រិតបឋមសិក្សា ព្រមទាំងរកឱ្យឃើញនូវបញ្ហាប្រឈមនានា និងសំណូមពរក្នុងការរៀបចំបរិស្ថានសិក្សា។ ព្រោះបញ្ហាបរិស្ថានសិក្សា គឺជាបញ្ហាដែលត្រូវដោះស្រាយដោយប្រុងប្រយ័ត្ននិងជាបន្ទាន់ ព្រោះវាកំពុងប៉ះពាល់ដល់សុខភាព សោភ័ណភាពនិងបរិស្ថាន (Ellström et al., 2008)។

អ្នកស្រាវជ្រាវបានសិក្សាតាមបែបបរិមាណវិស័យ(Quantitative Research) និងជាការពិពណ៌នា (Descriptive Research Design)។ ឧបករណ៍នៃការស្រាវជ្រាវតាមរយៈការស្ទង់មតិ(Survey)ដោយបំពេញកម្រងសំណួរ(Questionare) និងគណនាតាមរយៈ Descriptive Statistics ដោយប្រើកម្មវិធី SPSS Version 28 ដែលចំនួនសំណាកយកចេញពី៣ស្រុក និង៦សាលា ធ្វើការរើសដោយចៃដន្យ។ ចំពោះអ្នកចូលរួមមាន គណៈគ្រប់គ្រង ៦នាក់ តាម Critical Sampling គ្រូ (ថ្នាក់ទី១ ដល់ទី៦) ៦៧នាក់ សិស្ស(ថ្នាក់ទី៦)៤២០នាក់ និងសហគមន៍១៧នាក់ តាមPurposive sampling ។

ជាលទ្ធផល បានបង្ហាញថាតាមសាលាបឋមសិក្សានីមួយៗ មានការរៀបចំបរិស្ថានសិក្សាស្របតាមឧបករណ៍វាយតម្លៃសាលារៀនស្អាត(២០១៨)។ ប៉ុន្តែមិនទាន់មានការអនុវត្តបានល្អនៅឡើង ដោយហេតុសាលាមួយចំនួនមានបញ្ហាប្រឈមមួយចំនួនដូចជា៖ បញ្ហាសំរាម និងកំណើនប្លាស្ទិកមានកម្រិត នៃការឆ្លើយរបស់អ្នកចូលរួម(៤៣.៥%) សកម្មភាពសិស្ស និងសកម្មភាពគ្រូ(៥៨.៨%) កន្លែងលក់ដូរ (៥៧.៣%) អាគារសិក្សាចាស់ៗ(៤២.៩%)និងសាលានីមួយៗសំបូរព្រៃ និងស្មៅច្រើន(៤០.៦%)។

ដោយផ្អែកតាមលទ្ធផលបានបង្ហាញឱ្យឃើញថាសិស្សមានអារម្មណ៍សប្បាយរីករាយ យល់ច្បាស់ពីតម្រូវការ និងភាពចាំបាច់នៃបរិស្ថានសិក្សា និងមានការឱ្យតម្លៃខ្ពស់ទៅលើការរៀបចំបរិស្ថានសិក្សា។ បញ្ហាប្រឈមមួយចំនួនដែលមានដូចជាបញ្ហាសំរាម កង្វះធុងសំរាម ការចូលរួម និងការយល់ដឹងពីបរិស្ថានមិនទាន់បានល្អ កង្វះឯកសារស្រាវជ្រាវផ្សេងៗ និងសម្ភារៈដែលជាជំនួយដល់ការរៀបចំបរិស្ថានសិក្សា ជាកត្តាជះឥទ្ធិពលមិនល្អដល់ការសិក្សារបស់សិស្សផងដែរ។

# Abstract

This research studies the topic of "**Principles of Teachers, Students, and Communities on the Organization of the Learning Environment at the Primary Level in Takeo Province**" to study the situation of the organization of the learning environment at the primary level and to identify challenges. And suggestions for setting up a learning environment. The study environment is an issue that needs to be addressed carefully and urgently because it is affecting health, aesthetics, and the environment (Ellström et al., 2008).

Researchers studied quantitative research and descriptive research design. Survey tool, survey questionnaire, and descriptive statistics using SPSS Version 28, randomly selected from 3 districts and 6 schools. For the participants, there were 6 management teams through Critical Sampling, 67 teachers (1st to 6th grade), 420 students (6th grade) and 17 community through Purposive sampling.

The results show that each primary school has a learning environment in accordance with the Clean School Assessment Tool (2018). However, there is still no good practice due to some schools having some challenges such as: garbage problem and plastic growth, limited response rate of participants (43.5%), student activity and teacher activity (58.8%). Shops (57.3%), old school buildings (42.9%) and each school is rich in forest and grass (40.6%).

Based on the results, it shows that students feel happy, understand the needs and necessities of the learning environment and value the design of the learning environment. Some of the challenges, such as the problem of garbage, lack of bins, poor participation and understanding of the environment, lack of research documents and materials that help to organize the learning environment are also negative factors affecting students' learning.

# លិខិតថ្លែងអំណរគុណ

នាងខ្ញុំជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ជំនាញគ្រប់គ្រងអប់រំជំនាន់ទី១០ ក្នុងឆ្នាំសិក្សា ២០២១-២០២៣ នៅវិទ្យាស្ថានជាតិអប់រំ សូមថ្លែងអំណរគុណចំពោះមនុស្សសំខាន់ៗមួយចំនួនដែលបានដើរតួនាទីក្នុងការនាំខ្ញុំឱ្យមកកាន់ចំណុចនេះ។

- ឯកឧត្តមបណ្ឌិត **សៀង សុវណ្ណា** នាយកនៃវិទ្យាស្ថានជាតិអប់រំ ដែលជាម្លប់ដ៏ត្រជាក់ និងកក់ក្តៅសម្រាប់វិទ្យាស្ថាន និងជាអ្នកដឹកនាំផលិតធនធានមនុស្សក្នុងការអភិវឌ្ឍសង្គមជាតិ។
- ជាពិសេសសូមថ្លែងអំណរគុណ ចំពោះលោកគ្រូណែនាំបង្គោល **បណ្ឌិត នី វង្សា** និង លោកគ្រូណែនាំរង **ឯឧត្តមបណ្ឌិត សិត សេង** ដែលបានជួយជ្រោមជ្រែងដឹកនាំកែសម្រួល និងអនុសាសន៍យ៉ាងល្អៗក្នុងការធ្វើសារណាបទ ដល់រូបនាងខ្ញុំចាប់តាំងពីដើមរហូតដល់ចប់ ហើយថែមទាំងទទួលបានជោគជ័យជាស្ថាពរ។
- លោកគ្រូ និងអ្នកគ្រូដែលបង្ហាត់បង្រៀននាងខ្ញុំតាំងពីថ្នាក់បឋម រហូតមកដល់មហាវិទ្យាល័យ។
- លោកឪពុក **ឈឹម ពៅ** និង អ្នកម្តាយ **ប្រាក់ ស៊ីង** ព្រមទាំងបងប្អូនទាំងអស់ដែលបានចិញ្ចឹមបីបាច់មើលថែរក្សា ទំនុកបំរុងសព្វគ្រប់បែបយ៉ាងផ្តល់ចំណីអាហារ សម្លៀលបំពាក់ បញ្ជូនទៅសាលារៀនទូន្មានប្រៀនប្រដៅដល់រូបនាងខ្ញុំយ៉ាងធំធេញតាំងពីដើមរហូតមកដល់នាពេលបច្ចុប្បន្ន។
- លោកគ្រូនាយកនៃសាលាបឋមសិក្សាហ៊ុនសែនអង្គបុរី បឋមសិក្សាភ្នំបាទេព បឋមសិក្សាហ៊ុនសែនបានយ បឋមសិក្សាព្រៃល្វា បឋមសិក្សាអង្គតាសោម និងបឋមសិក្សាអង្គរុន ដែលបានអនុញ្ញាតឱ្យនាងខ្ញុំបានចុះកម្មសិក្សាស្រាវជ្រាវ និងបានដកបទពិសោធន៍ផ្ទាល់នៅអង្គភាពសម្រាប់ចងក្រង និក្ខេបបទសម្រាប់បញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់។

ជាទីចុងបញ្ចប់នេះដែលនាងខ្ញុំសូមគោរពជូនពរ សូមជួបប្រទះតែសេចក្តីសុខ សេចក្តីចម្រើន មានសុខភាពល្អបរិបូណ៌ សម្រេចបានជោគជ័យគ្រប់ភារកិច្ច និងទទួលបាននូវពុទ្ធពរទាំងឡាយ ៤ ប្រការគឺៈ អាយុ វណ្ណៈ សុខៈ និងពលៈគ្រប់ៗគ្នាកុំបីឃ្លៀងឃ្លាតឡើយ និងជានិច្ចនិរន្តន៍។

**សូមអរគុណ**!

# មាតិកា

សេចក្តីអះអាងរបស់បេក្ខនារី.....i
លិខិតបញ្ជាក់.....ii
មូលន័យសង្ខេប.....vii
លិខិតថ្លែងអំណរគុណ.....ix
បញ្ជីរូបភាព/ តារាង ឬការលើកឧទាហរណ៍.....xiv
បញ្ជីនៃសញ្ញា និង អក្សរកាត់.....xv

## ជំពូក១

## សេចក្តីផ្តើម

១.១ លំនាំបញ្ហានៃការស្រាវជ្រាវ.....1
១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ.....3
១.៣ គោលបំណងនៃការស្រាវជ្រាវ.....5
១.៤ សំណួរស្រាវជ្រាវ.....5
១.៥ សារៈសំខាន់នៃការស្រាវជ្រាវ.....5
១.៦ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ.....7
១.៧ ក្របខ័ណ្ឌគោលគំនិតនៃការស្រាវជ្រាវ.....9
១.៨ រចនាសម្ព័ន្ធស្រាវជ្រាវ.....9

## ជំពូក ២

## ការរំលឹកទ្រឹស្តី

២.១ និយមន័យប្រតិបត្តិនៃពាក្យគន្លឹះ.....12
២.២ ការដឹកនាំ និងការគ្រប់គ្រង.....13
    ២.២.១ គោលដៅអប់រំជាតិ និងសមាសភាពទាំង៥នៃការអប់រំ.....13
    ២.២.២ ស្ថិតិសាលារៀនបឋមសិក្សានៅប្រទេសកម្ពុជា និងខេត្តតាកែវ.....13

២.២.៣ គោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព 14
២.៣ ស្តង់ដាសាលារៀនបឋមសិក្សា 15
២.៣.១ សាលារៀនស្អាត 19
២.៣.២ ការវង្វាយតម្លៃសាលារៀនស្អាត 25
២.៤ បរិស្ថានសិក្សា 26
២.៤.១ បរិស្ថានសិក្សា និងសុខភាពអនាម័យក្នុងសាលារៀន 27
២.៤.២ សារៈសំខាន់នៃបរិស្ថានសិក្សា 28
២.៤.៣ អនាម័យបរិស្ថានសិក្សា 29
២.៤.៤ លទ្ធផលពីការយល់ដឹងពីបរិស្ថានសិក្សា 30
២.៤.៥ បញ្ហាប្រឈមក្នុងការរៀបចំបរិស្ថានសិក្សា 32
២.៥ ការកាត់បន្ថយផលប៉ះពាល់បរិស្ថានសិក្សា 34
២.៥.១ ផលប៉ះពាល់ពីការប្រើប្រាស់ប្លាស្ទិក 34
២.៥.២ វិធានការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក 34
២.៥.៣ យុទ្ធនាការសាលាគ្មានសំរាម 37
២.៥.៤ យុទ្ធនាការកាត់បន្ថយ បញ្ឈប់ការប្រើប្រាស់ប្លាស្ទិកក្នុងសាលា 37
២.៥.៥ យុទ្ធនាការពិពណ៌ស្នាដៃក្នុងការកែច្នៃសំរាម 38
២.៦ ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន 38
២.៦.១ អគារសិក្សា និងបន្ទប់រៀន 38
២.៦.២ សម្ភារៈបរិក្ខារ និងការផ្គត់ផ្គង់ 38
២.៦.៣ បរិស្ថានសាលារៀន 39
២.៦.៤ បរិស្ថានសិក្សា 40
២.៦.៥ ការរៀបចំសោភ័ណភាពសាលា 41
២.៧. ការចូលរួមរបស់ភាគីពាក់ព័ន្ធ 42
២.៧.១ ការចូលរួមរបស់នាយកសាលារៀន 43
២.៧.២. ការចូលរួមរបស់លោកគ្រូ អ្នកគ្រូ 44
២.៧.៣. ការចូលរួមរបស់សិស្ស 45
២.៧.៤. ការចូលរួមរបស់សហគមន៍ 46

## ជំពូក ៣

## វិធីសាស្ត្រស្រាវជ្រាវ


៣.១ គម្រោងការស្រាវជ្រាវ ........ 51

៣.២ ការជ្រើសរើសភាគសំណាក........ 52

៣.៣ ឧបករណ៍ស្រាវជ្រាវ ........ 54

៣.៤ ការប្រមូលទិន្នន័យ ........ 56

៣.៥ ការវិភាគទិន្នន័យ........ 58

៣.៦ ក្រមសីលធម៌នៃការស្រាវជ្រាវ........ 59


## ជំពូក ៤

## លទ្ធផល និងការពិភាក្សា


៤.១ លទ្ធផល ........ 62

៤.១.១ សេចក្តីផ្តើម ........ 62

៤.១.២ ព័ត៌មានទូទៅប្រជាសាស្ត្រ........ 62

៤.១.៣ ស្ថានភាពនៃការរៀបចំបរិស្ថានសិក្សានៅកម្រិតបឋមសិក្សា........ 64

៤.១.៤ បញ្ហាប្រឈមក្នុងការរៀបចំបរិស្ថានសិក្សា ........ 76

៤.២ ការពិភាក្សា ........ 79

៤.២.១ ស្ថានភាពនៃការរៀបចំបរិស្ថានសិក្សានៅកម្រិតបឋមសិក្សា........ 79

៤.២.២ បញ្ហាប្រឈមក្នុងការរៀបចំបរិស្ថានសិក្សា ........ 82


## ជំពូក ៥

## សេចក្តីសន្និដ្ឋាន និងសំណូមពរ


៥.១ សេចក្តីសន្និដ្ឋាន........ 85

៤.២.១ ស្ថានភាពនៃការរៀបចំបរិស្ថានសិក្សានៅកម្រិតបឋមសិក្សា........ 85

៤.២.២ បញ្ហាប្រឈមក្នុងការរៀបចំបរិស្ថានសិក្សា ........ 85

៥.២ សំណូមពរ ........ 86

៥.២.១ មន្ទីរអប់រំ យុវជន និងកីឡា....86

៥.២.២ ចំពោះគណៈគ្រប់គ្រងសាលា....87

៥.២.៣ ចំពោះគ្រូ....88

៥.២.៤ ចំពោះសិស្ស....88

៥.២.៥ ចំពោះសហគមន៍....89

៥.២.៦ អ្នកសិក្សាជំនាន់ក្រោយ....89

ឯកសារយោង....92

ឧបសម្ព័ន្ធទី១៖ កម្រងសំណួរ....97

ឧបសម្ព័ន្ធទី២៖ ឧបករណ៍វាយតម្លៃសាលារៀនស្អាត....121

ឧបសម្ព័ន្ធទី៣៖ លិខិតបង្គាប់ការរបស់គណៈកម្មការការពារនិក្ខេបបទ....128

ឧបសម្ព័ន្ធទី៤៖ លិខិតចាត់តាំងគ្រូដឹកនាំ និងគ្រូដឹកនាំរង សម្រាប់សរសេរនិក្ខេបបទ....136

ឧបសម្ព័ន្ធទី៥ លិខិតអនុញ្ញាតរបស់ក្រសួងអប់រំ យុវជន និងកីឡា....140

ឧបសម្ព័ន្ធទី៦៖ លិខិតអនុញ្ញាតរបស់មន្ទីអប់រំ យុវជន និងកីឡាខេត្តតាកែវ....141

ឧបសម្ព័ន្ធទី៧៖ សកម្មភាពនៃការចុះប្រមូលទិន្នន័យនៅតាមបណ្ដាសាលាបឋមសិក្សាទាំង៦ ជាមួយ សិស្ស គ្រូ នាយក និងសហគមន៍....142

# បញ្ជីរូបភាព/ តារាង ឬការលើកឧទាហរណ៍


ក្រាហ្វិកទី១ ចំនួនសាលាដែលចូលរួម ....................................................62

ក្រាហ្វិកទី២ ចំនួនគណគ្រប់គ្រង គ្រូ សិស្ស សហគមន៍ដែលបានចូលរួមក្នុងការបំពេញកម្រងសំណួរ ...........63

ក្រាហ្វិក៤.១.៣.២. ការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន និងភាពស្អាត ........................64

តារាង៤.១.៣.៣ ភាពស្អាតនៅក្នុងបរិវេណសាលា បន្ទប់រៀន បង្គន់   អនាម័យ និងភាពបៃតង............66

តារាង ៤.១.៣.៤ ទីតាំងលេងកម្សាន្ត ចំណតយានជំនិះ និងទីតាំងដាក់ធុងសំរាម..........................67

ក្រាហ្វិក៤.១.៣.៥ ការគ្រប់គ្រងសំណល់ (ការវេចខ្ចប់ និងប្រមូលសំរាម)...............................68

ក្រាហ្វិក៤.១.៣.៦ អនាម័យចំណីអាហារ .......................................................69

ក្រាហ្វិក៤.១.៣.៧ ការប្រើប្រាស់ទឹកស្អាត ការបំពុលដោយសារក្លិន និងការបំពុលដោយផ្សែង ...........70

ក្រាហ្វិក៤.១.៣.៨ សុខុមាលភាពគ្រូសិស្សនិងបុគ្គលិកអប់រំផ្សេងទៀត...............................71

តារាង៤.១.៣.៩ អត្តសញ្ញាណមន្ត្រីរាជការ.......................................................71

ក្រាហ្វិក៤.១.៣.១០ ការចាត់តាំងអនុវត្តការងារគ្រប់គ្រងអនាម័យ និងបរិស្ថាន ............................73

ក្រាហ្វិក៤.១.៤.១ សារៈសំខាន់នៃការរៀបចំបរិស្ថានសិក្សាស្អាត.......................................74

តារាង៤.១.៤.៤ វិធានការ ឬវិធីសាស្ត្រក្នុងការគ្រប់គ្រងទៅលើបញ្ហាសំរាម....................................76

# បញ្ជីនៃសញ្ញា និង អក្សរកាត់

| | |
|---|---|
| KAPE | អង្គការសកម្មភាពសំរាប់ការអប់រំនៅកម្ពុជា |
| M | Mean |
| MoE | ក្រសួងបរិស្ថាន |
| MoEYS | Ministry of Education, Youth and Sport |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| Ms.Excel | Microsoft Excel |
| N | Number of Simples |
| NIE | National Institute Education |
| S.D | Standard Deviation |
| SPSS | Statistical package for the Social Sciences |
| UNICEF | អង្គការយូនីសេហ្វ |
| UNSCO | គណកម្មការជាតិយូណេស្កូកម្ពុជា |
| WHO | អង្គការសុខភាពពិភពលោក |
| វ.ជ.អ | វិទ្យាស្ថានជាតិអប់រំ |

# ជំពូក ១

# សេចក្តីផ្តើម

# ជំពូក១

# សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

វិស័យអប់រំ គឺជាគន្លឹះមួយដ៏សំខាន់ក្នុងការកសាងនូវរាល់ហេដ្ឋារចនាសម្ព័ន្ធសង្គម និងមានគុណភាពពិតប្រាកដ រួមមានការកសាងធនធានបញ្ញាដែលពោរពេញដោយចំណេះដឹង ចំណេះធ្វើ និងឥរិយាបថល្អក្នុងសង្គម (ក្រសួងអប់រំ យុវជន និងកីឡា ២០១១)។ សាលារៀន គឺជាកន្លែងដែលមានគ្រូបង្រៀន សិស្ស និងមានហេដ្ឋារចនាសម្ព័ន្ធរូបវន្តសមស្រប (ក្រសួងអប់រំ យុវជន និងកីឡា ២០១៦)។ លើសពីនេះទៀតការគ្រប់គ្រងតាមសាលារៀននីមួយៗ គឺជាការផ្តល់និយ័តភាពក្នុងការសម្រេចចិត្តទៅកម្រិតមូលដ្ឋានដោយផ្អែកលើលទ្ធផលនៃការអនុវត្តការងារជាក់ស្តែងរបស់សាលារៀន និងលទ្ធផលសិក្សារបស់សិស្ស (ក្រសួងអប់រំ យុវជន និងកីឡា ២០១៨)។

ម្យ៉ាងវិញទៀតការគ្រប់គ្រងតាមសាលារៀននៅកម្ពុជា មានការផ្លាស់ប្តូរទៅជាវិជ្ជមានលើការងាររដ្ឋបាលសាលារៀន ការរៀន និងការបង្រៀន បរិស្ថានសាលារៀន អត្រាឡើងថ្នាក់ ការចូលរួមរបស់សិស្សស្រី គណនេយ្យភាពនៅក្នុងការគ្រប់គ្រងសាលារៀន លទ្ធផលការបំប៉នសមត្ថភាពជាប្រចាំ និងគោរពក្រមសីលធម៌វិជ្ជាជីវគ្រូបង្រៀនបានប្រសើរធ្វើឱ្យសហគមន៍មានទំនុកចិត្តលើសាលា (ស៊ឹម វិសុទ្ធ ២០១៧)។ យោងកម្មវិធីសិក្សាវគ្គនាយក របស់វិទ្យាស្ថានជាតិអប់រំ ឆ្នាំសិក្សា ២០១៨ - ២០១៩ បានបង្ហាញថាការគ្រប់គ្រងសាលារៀនត្រូវផ្អែកលើលទ្ធផលតាមរយៈការលើកកម្ពស់ការបង្រៀន និងរៀន បរិស្ថានសិក្សាកម្មវិធីកុមារមេត្រី កម្មវិធីសិក្សា ការបំពេញការងាររបស់គ្រូបង្រៀន និងអធិការកិច្ចសាលារៀន។

ក្នុងនោះគោលដៅរបស់សាលាចង់ឱ្យសិស្សរៀនក្នុងសាលាដែលមានសុវត្ថិភាព បរិស្ថានក្នុងថ្នាក់និងជុំវិញសាលាស្អាត គ្រូមានបច្ចេកទេស វិធីសាស្ត្របង្រៀនគ្រប់ជ្រុងជ្រោយ សិស្សសុខភាពអនាម័យល្អ ហើយការជួសជុល និងសាងសង់សាលាមានជាបន្តបន្ទាប់តាមដំណាក់កាល។ ដោយឡែកទាក់ទងនិងការគ្រប់គ្រងសាលារៀនកម្រិតបឋមសិក្សា សាលារៀននីមួយៗត្រូវកំណត់គោលនយោបាយកម្មវិធីសាលា

កុមារមេត្រីរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលបានដាក់ឱ្យអនុវត្តចាប់តាំងពីឆ្នាំ២០០៧ រហូតមកដល់សព្វថ្ងៃនេះ។ ក្នុងនោះផងដែរការអនុវត្តសមាសភាគទាំងប្រាំមួយនៃកម្មវិធីសាលាកុមារមេត្រីគឺផ្តល់ឱកាសស្មើៗ គ្នា ដល់កុមារទទួលបានចំណេះដឹង ជំនាញ សមធម៌ និងចេះរស់នៅជាមួយគ្នាប្រកបដោយភាពសុខដុមរមនា។ មិនតែប៉ុណ្ណោះធានាកុមារទាំងអស់បានចូលរៀន ធានាការបង្រៀននិងការរៀនប្រកបដោយប្រសិទ្ធភាពខ្ពស់ ធានាសុខភាព សុវត្ថិភាពនិងការពារកុមារ ធានាការឆ្លើយតបទៅនឹងយេនឌ័រ ធានាការចូលរួមរបស់ក្រុមគ្រួសារ សហគមន៍ និងប្រព័ន្ធអប់រំជាតិបានជួយគាំទ្រកម្មវិធីសាលាកុមារមេត្រី និងលើកទឹកចិត្តដល់សាលារៀនឱ្យទៅជាសាលាកុមារមេត្រី (ក្រសួងអប់រំ យុវជន និងកីឡា ២០១២)។

សៀវភៅស្តង់ដាសាលាបឋមសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា (២០១៧) បានបង្ហាញឱ្យឃើញថាការអនុវត្តស្តង់ដាសាលាបឋមសិក្សាជាមគ្គុទ្ទេស ដែលអ្នកពាក់ព័ន្ធត្រូវយល់ដឹងអំពីសាលារៀនដើម្បីធានាបាននូវ ប្រសិទ្ធភាព និងធានាគុណភាពនៃការសិក្សាដោយប្រែកុមារទៅជាពលរដ្ឋសកល (ស្អាត របៀប សុខភាព ទៀងពេល និងសមាធិ)។ ចំពោះការរៀបចំកម្មវិធីសិក្សាសម្ភារៈបង្រៀនផ្សេងៗ ការកែលម្អបណ្ណាល័យ និងលើកទឹកចិត្តសិស្សរៀបចំសម្ភារៈសិក្សារៀនសូត្រទៀត (ក្រសួងអប់រំ យុវជន និងកីឡា ២០១៨)។

ជាមួយគ្នានេះដែរអង្គការសកម្មភាពសម្រាប់ការអប់រំកម្ពុជា(ខេប) បានធ្វើគម្រោងសាលារៀនគោលដៅទាំងអស់ទទួលបានការរីកចម្រើនផ្នែកសាលាកុមារមេត្រី ដោយសារការដឹកនាំ និងគ្រប់គ្រងកាន់តែប្រសើរឡើងរបស់នាយកសាលារៀន។ ក្នុងនោះសាលាចំនួន ១៤៦ ដែលអង្គការបានជួយកែលម្អគណៈគ្រប់គ្រងសាលារៀនតាមរយៈផ្តល់ការបំប៉នពីភាពជាអ្នកដឹកនាំ និងគ្រប់គ្រងលម្អបរិស្ថានសាលាកុមារមេត្រី លើការពង្រឹងសមត្ថភាពគណៈសាលារៀន នឹងផ្តល់អំណោយអភិវឌ្ឍសាលរៀនបញ្ចូលសាលាកុមារមេត្រី។ ពិតណាស់ការគ្រប់គ្រងអនាម័យសាលារៀន ជាកត្តាចម្បងមួយ ដែលអ្នកគ្រប់គ្រងត្រូវយកចិត្តទុកដាក់ថែរក្សា និងអភិវឌ្ឍប្រកបដោយចីរភាព។ម្យ៉ាងទៀតអនាម័យសាលារៀន ក៏ជាផ្នែកមួយមិនអាចខ្វះបាន និងដើរតួនាទីសំខាន់ណាស់ក្នុងការឆ្លុះបញ្ចាំងអំពីគុណភាព សាលារៀនល្អ ឬជាសាលាកុមារមេត្រី ហើយក៏បានបង្ហាញផងដែរអំពីការងារគ្រប់គ្រងល្អ ការបង្រៀននិងការរៀនល្អ ដែលវាជាផ្នែកមួយ

ទាក់ទាញអារម្មណ៍សិស្សទូទៅឱ្យស្រឡាញ់ការសិក្សា និងជួយជំរុញការលើកកម្ពស់ការថែរក្សាអនាម័យ និងបរិស្ថាននៅតាមសហគមន៍។ ហេតុនេះហើយអនាម័យសាលារៀនល្អ ជាកត្តាជំរុញឱ្យមានបរិយាកាសនៃការរៀនសូត្រមួយប្រកបដោយសុខមាលភាព សុវត្ថិភាព និងដែលនាំឱ្យមានភាពជឿទុកចិត្តអំពីសំណាក់អាណាព្យាបាលសិស្សនានា និងប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន ពិសេសជាកត្តាជំរុញឱ្យគុណភាពប្រសិទ្ធភាពនៃការរៀនសូត្រឱ្យកាន់តែប្រសើរឡើងថែមទៀត។ យោងគោលនយោបាយជាតិស្តីពីសុខភាពសិក្សា (២០១៩) បានលើកឡើងថាសុខភាពរបស់អ្នកសិក្សា គឺជាកត្តាដ៏សំខាន់មួយដែលរួមចំណែកដល់ការធានាបាននូវការសិក្សាប្រកបដោយគុណភាព ប្រសិទ្ធភាព និងបង្កើនអត្រាបញ្ចប់ការសិក្សា។ កត្តានេះ គឺជាមធ្យោបាយមួយសម្រាប់ចូលរួមចំណែក ជួយបំពេញគោលដៅយុទ្ធសាស្ត្ររបស់ក្រសួងអប់រំ យុវជន និងកីឡា ពោលគឺ ការអប់រំមានការធនាគុណភាព ប្រសិទ្ធភាព ភាពសក្តិសិទ្ធប្រកបដោយសមធម៌ និងការអប់រំប្រកបដោយចីរភាព។ ក្នុងនោះផងដែរបរិស្ថានសិក្សានៅតាមសាលានីមួយៗតែងតែមានបញ្ហាប្រឈមបណ្តាលមកពីបញ្ហាសំរាម ជាផ្នែកមួយកើតមាននៅតាមសាលារៀន ទីសាធារណៈជាដើមដែលបង្កអោយប៉ះពាល់ដល់សុខភាពយ៉ាងខ្លាំង (ក្រសួងបរិស្ថាន ២០២១)។

ដូចនេះទើបអ្នកស្រាវជ្រាវ បានលើកប្រធានបទ « **ទស្សនៈរបស់នាយក គ្រូ សិស្ស និងសហគមន៍ចំពោះការរៀបចំបរិស្ថានសិក្សានៅកម្រិតបឋមសិក្សាក្នុងខេត្តតាកែវ** » មកសិក្សាដើម្បីឱ្យតាមសាលារៀនមានការយកចិត្តទុក្ខដាក់ទៅលើបញ្ហាទាំងអស់នេះ ទទួលបានបរិស្ថានសាលាស្អាត និងមានផាសុកភាព។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ការគ្រប់គ្រងបរិស្ថានសាលារៀនបានល្អ គឺមានសារៈសំខាន់ណាស់សម្រាប់ជាប្រយោជន៍ដល់សុខភាពនៃបរិយាកាសសិក្សា និងលទ្ធផលសិក្សារបស់សិស្ស។ ម៉្យាងការងារគ្រប់គ្រងបរិស្ថានសាលារៀនជាការងារដែលមានសារៈសំខាន់ និងចាំបាច់ដើម្បីពង្រឹងគុណភាពសាលារៀនឲ្យឈានទៅសម្រេចគោលបំណង និងគោលដៅរបស់ខ្លួន ក្នុងការផ្លាស់ប្តូរបរិស្ថានសិក្សាតាមគ្រឹះស្ថានសិក្សាសាធារណៈរបស់រដ្ឋថ្នាក់ក្រោមជាតិទាំងឡាយឱ្យក្លាយជាសាលារៀនមានភាពពណ៌បៃតង (Green School) ក្នុងន័យធានាឲ្យ

បាននូវគុណភាព និងមានប្រសិទ្ធភាពនៃសេវាអប់រំនៅថ្នាក់ក្រោមជាតិ ស្របទៅនឹងគោលនយោបាយកំណែទម្រង់របស់រាជរដ្ឋាភិបាលក៏ដូចជាផែនការកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា។

មួយវិញទៀតបរិស្ថានសិក្សា គឺជាផ្នែកមួយដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រងសាលារៀន ការងារបង្រៀនរបស់លោកគ្រូ អ្នកគ្រូ និងការរៀនរបស់សិស្ស ហើយវាក៏ជាឧបករណ៍វាយតម្លៃអំពីសមត្ថភាពដឹកនាំ និងគ្រប់គ្រងរបស់នាយកសាលាផងដែរ។ តាមរយៈការសង្កេតឃើញថាចាប់តាំងពីមានប្រកាសរបស់ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញសេចក្តីណែនាំលេខ ៤១៤៩អយក សណន ចុះថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០០៥ ស្តីពីការរៀបចំក្រុមប្រឹក្សាអភិវឌ្ឍន៍កម្មវិធីសាលាកុមារមេត្រី ថ្នាក់ខេត្តក្រុង និងស្រុក-ខណ្ឌ រហូតដល់ពេលនេះមានសាលារៀនមួយចំនួនបានរៀបចំ និងដំណើរការក្រុមការងាររបស់ខ្លួនបានយ៉ាងសកម្ម។

រីឯសាលារៀនមួយចំនួនទៀតមិនបានរៀបចំក្រុមការងារនេះនៅឡើយទេ ដែលធ្វើឱ្យមានផលប៉ះពាល់ដល់ការពង្រឹង និងអភិវឌ្ឍសាលាកុមារមេត្រី ឬសាលាបរិស្ថានបៃតងស្របតាមផែនការនៅឡើយ។ ម្យ៉ាងដោយមានគោលការណ៍ណែនាំស្តីពីសាលាកុមារមេត្រី (២០១៦) ហើយដើម្បីជំរុញការងារនេះឱ្យមានការសន្ទុះទៅមុខទាមទារនូវការរៀបចំយន្តការបន្ថែមទៀត ពិសេសដើម្បីឆ្លើយតបទៅនឹងគោលដៅរបស់ក្រសួងអប់រំ យុវជន និងកីឡាដែលបានដាក់ចេញឆ្ពោះទៅរកបរិស្ថានស្អាត និងមានសុវត្ថិភាពខ្ពស់។ ដោយហេតុថាបញ្ហាបរិស្ថានសិក្សាជាបញ្ហាចម្បងមួយ ទាមទារជាចាំបាច់នូវការចូលរួមថែរក្សាការពារឱ្យបានស្អាត ដើម្បីបង្កើនវិស្ថានសិក្សាដែលប្រកបដោយប្រសិទ្ធភាព និងមានផាសុខភាពសម្រាប់ការរៀន និងការបង្រៀនឱ្យផ្សារភ្ជាប់ជាមួយទិដ្ឋភាពនៃការរស់នៅប្រចាំថ្ងៃ។

ហេតុនេះត្រូវធ្វើការសិក្សាស្វែងយល់ឱ្យបានស៊ីជម្រៅ ពីបញ្ហានៃការរៀបចំបរិស្ថានសិក្សា និងបញ្ហាប្រឈម។ ក្នុងនោះផងដែរ មានការប្រគួតប្រជែងសាលាបរិស្ថានស្អាត ដែលវិទ្យាល័យស្វាយរៀង នៃខេត្តស្វាយរៀង បានទទួលជ័យលាភីពានរង្វាន់សម្តេចតេជោហ៊ុនសែនចំណាត់ថ្នាក់លេខ១ លំដាប់ប្រទេសដែលមានបរិស្ថានសិក្សាល្អ និងសាលាបឋមសិក្សាអង្គរុនជាប់ចំណាត់ថ្នាក់ សាលាស្អាតលេខ៩ (ក្រសួងអប់រំ យុវជន និងកីឡា ២០២០-២០២១)។ យោងក្រសួងអប់រំ យុវជន និងកីឡា មានកម្មវិធី

ប្រកួតប្រជែងសាលាបរិស្ថានស្អាតដែលវិទ្យាល័យភ្ញីមាស ស្រុកព្រៃកប្បាសខេត្តតាកែវ បានជាប់ចំណាត់ថ្នាក់សាលាស្អាតលេខ៣ (២០១៩-២០២០) និងជាប់ចំណាត់ថ្នាក់លេខ៦ (២០១៨-២០១៩)។

លើសពីនេះទៀត បរិស្ថានសិក្សាគឺជា អ្វីៗដែលនៅជុំវិញខ្លួនយើង ដែលយើងមានទំនាក់ទំនងដោយផ្ទាល់ ឬដោយប្រយោល ហើយជីវិតយើងគ្រប់គ្នាទាំងអស់សុទ្ធតែត្រូវការបរិស្ថានស្អាតជាចាំបាច់ដោយមិនអាចខ្វះបាន(Ellström et al., 2008)។ ហេតុនេះបញ្ជាក់ឱ្យឃើញថា បញ្ហាបរិស្ថានសិក្សា គឺពិតជាមានសារៈសំខាន់ណាស់ដែលត្រូវយកចិត្តទុកដាក់ និងដោះស្រាយ ជាពិសេសបញ្ហាសំរាមតែម្តង។ ដូចនេះ បញ្ហាបរិស្ថានសិក្សា គឺជាបញ្ហាដែលត្រូវដោះស្រាយដោយប្រុងប្រយ័ត្ន និងជាបន្ទាន់ ព្រោះវាកំពុងប៉ះពាល់ដល់សុខភាព សោភ័ណភាព និងបរិស្ថាន (Ellström et al., 2008)។

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងសំខាន់ៗចំនួន២គឺ៖

(១) ឈ្វេងយល់ពីស្ថានភាពនៃការរៀបចំបរិស្ថានសិក្សា នៅកម្រិតបឋមសិក្សាក្នុងខេត្តតាកែវ។

(២) សិក្សាពីបញ្ហាប្រឈមនានា ក្នុងការរៀបចំបរិស្ថានសិក្សានៅបឋមសិក្សា។

## ១.៤ សំណួរស្រាវជ្រាវ

(១) តើស្ថានភាពនៃការរៀបចំបរិស្ថានសិក្សានៅបឋមសិក្សាមានលក្ខណៈដូចម្តេច?

(២) តើការរៀបចំបរិស្ថានសិក្សានៅសាលាបឋមសិក្សាជួបបញ្ហាប្រឈមអ្វីខ្លះ?

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណង ដើម្បីរកឱ្យឃើញពីបញ្ហាប្រឈមនានាទាក់ទងជាមួយនឹងការរៀបចំបរិស្ថានសិក្សា ដែលកំពុងកើតមានឡើងនៅក្នុងសាលាបឋមសិក្សានាពេលបច្ចុប្បន្ន និងស្វែងយល់ពីដំណោះស្រាយ និងសំណូមពរនានារបស់នាយក គ្រូ សិស្ស សហគមន៍ក្នុងការជួយកែលម្អបរិស្ថានសិក្សាសម្រាប់ការបង្រៀននិងរៀនឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

ប្រសិនបើបរិស្ថានសិក្សាស្អាតជាផ្នែកមួយ ដែលជួយអោយគ្រូ សិស្សមិនបោះបង់ចោលសាលា មានន័យថាគ្រូមានអារម្មណ៍ល្អក្នុងការធ្វើការងារ និងសិស្សចង់មករៀន ថែមទាំងបរិយាកាសប្រកបដោយផាសុកភាព (ក្រសួងអប់រំ យុវជន និងកីឡា ២០២១)។

ជាការពិតណាស់លទ្ធផលនៃការបង្រៀន និងរៀនរបស់គ្រូ សិស្សកាន់តែមានភាពប្រសើរឡើង ប្រសិនបើបញ្ហាប្រឈមទាំងឡាយក្នុងសាលាត្រូវបានកាត់បន្ថយ។ បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវដោយយកចិត្តទុកដាក់ខ្ពស់ និងការប្រើប្រាស់នូវវិធីសាស្ត្រសមស្របលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ និងក្លាយទៅជាព័ត៌មានដ៏មានសារៈសំខាន់មួយ សម្រាប់អ្នករៀបចំ គោលនយោបាយអប់រំ និងអ្នកពាក់ព័ន្ធនានាក្នុងវិស័យអប់រំ ជាពិសេសគណៈគ្រប់គ្រងសាលាទាំងមូល (ក្រសួងអប់រំ យុវជន និងកីឡា ២០១២)

ម្យ៉ាងវិញទៀតការស្រាវជ្រាវនេះពិតជាមានសារៈប្រយោជន៍ណាស់ចំពោះនាយក គ្រូ សិស្ស និងសហគមន៍ ដើម្បីសិក្សាឈ្វេងយល់បានស៊ីជម្រៅពីស្ថានភាព និងបញ្ហាប្រឈមនានារបស់ខ្លួនក្នុងការរៀបចំថែរក្សាបរិស្ថានសិក្សា។ ក្នុងនោះផងដែរ បរិស្ថានសិក្សា គឺជាសញ្ញាណក្នុងការធ្វើឱ្យមានការផ្លាស់ប្តូរ និងត្រូវបំពេញបន្ថែមដែលអាចធានាបាននូវប្រសិទ្ធភាពនៃការអនុវត្តការសិក្សា។

មិនតែប៉ុណ្ណោះការស្រាវជ្រាវនេះ និងអាចជួយដល់ការចុះពិនិត្យតាមដាន និងវាយតម្លៃផ្សេងៗ ហើយក៏បានចូលរួមចំណែកក្នុងការឆ្លុះបញ្ចាំងនូវការធានាបាននូវគុណភាពអប់រំ នៅក្នុងសាលារៀននាពេលបច្ចុប្បន្ននេះ។ មួយវិញទៀតការសិក្សានេះ ជាសារមួយដែលជួយឱ្យមានការកែលម្អឥរិយាបថរបស់អ្នកពាក់ព័ន្ធទាំងអស់ក្នុងការអនុវត្ត ការរៀបចំបរិស្ថានសិក្សា និងការទុកដាក់សំរាម ក៏ដូចជាការអនុវត្តជាប្រចាំថ្ងៃនៅក្នុងថ្នាក់រៀនផ្ទាល់ ព្រមទាំងទទួលបាននូវបរិស្ថានសិក្សាល្អប្រសើរ។

ក្នុងនោះផងដែរការឈ្វេងយល់បានស៊ីជម្រៅអំពីការរៀបចំ និងការថែរក្សាបរិស្ថានសិក្សប្រកបដោយគុណភាព និងប្រសិទ្ធភាពខ្ពស់ស្របតាមកំណែទម្រង់វិស័យអប់រំការរៀបចំហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀនប្រកបដោយបរិយាបន្ន ផាសុកភាព និងមេត្រីភាពនាពេលបច្ចុប្បន្ន។ ការសិក្សាមួយនេះ នឹងអាចរួមចំណែកលើកកម្ពស់ការបង្រៀន និងរៀនរបស់គ្រូ សិស្សតាមរយៈសាលាមានបរិស្ថានសិក្សាស្អាតដែលបណ្តាលឱ្យគុណភាពអប់រំមានប្រសិទ្ធភាព និងកាន់តែមានភាពល្អប្រសើរឡើង។

ហេតុនេះការសិក្សាស្រាវជ្រាវនេះមានសារៈសំខាន់ផងដែរ សម្រាប់អ្នកអានគ្រប់មជ្ឈដ្ឋានដែលត្រូវ និងបរិបទខ្លឹមសារនេះ ហើយសម្រាប់អ្នកសិក្សាស្រាវជ្រាវបន្តបន្ទាប់ទៅមុខទៀតពាក់ព័ន្ធទៅនឹងប្រធានបទខាងលើឱ្យមានភាពស៊ីសង្វាក់ និងធ្វើការពង្រីកឱ្យបានលំអិតទៅតាមនិយមន័យបរិស្ថានសិក្សា នឹងស្ថានភាពអប់រំនាពេលបច្ចុប្បន្ន។ ម្យ៉ាងវិញទៀតការសិក្សាស្រាវជ្រាវនេះក៏ចង់លើកកម្ពស់សុខភាពសិក្សាអនាម័យការរស់នៅរបស់នាយក របស់គ្រូ និងរបស់សិស្សក្នុងគ្រឹះស្ថានសិក្សាឱ្យកាន់តែមានភាពប្រសើរឡើង។ ការស្រាវជ្រាវនេះនឹងបង្កលក្ខណៈឱ្យគណៈគ្រប់គ្រងសាលា គ្រូបង្រៀនកាន់តែមានភាពងាយស្រួល និងភាពច្បាស់លាស់ក្នុងការតាមដាន វាយតម្លៃ និងឈ្វេងយល់ពីបញ្ហាប្រឈមក្នុងសាលារបស់ខ្លួនលើការរៀបចំបរិស្ថានសិក្សាដែលអាចជាផលជះយ៉ាងសំខាន់ទៅលើគុណភាពនៃការអនុវត្តការងារ និងលទ្ធផលសិក្សារបស់គ្រូ សិស្ស។

មិនតែប៉ុណ្ណោះការសិក្សាស្រាវជ្រាវនេះមានគោលបំណងរកឱ្យឃើញនូវបញ្ហាប្រឈមនានា និងដំណោះស្រាយអំពីការរៀបចំបរិស្ថានសិក្សាទាំងបីរួមមាន អនាម័យសិក្សា (ការគ្រប់គ្រងបញ្ហាសំរាម) ហេដ្ឋារចនាសម្ព័ន្ធស្តីពីការបង្រៀន និងរៀន(ក្នុងថ្នាក់) និងបរិស្ថានសាលាទាំងមូល(ក្រៅថ្នាក់) ដែលធ្វើឱ្យការបង្រៀន/រៀនរបស់គ្រូ-សិស្ស កាន់តែមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អ។

ដូចនេះការសិក្សាស្រាវជ្រាវនេះនឹងជួយឱ្យសាលាទាំងមូលដឹងពីចំណុចខ្វះខាត បញ្ហាប្រឈម និងសំណូមពរក្នុងការអនុវត្តវិធីសាស្ត្រការរៀបចំបរិស្ថានសិក្សានិងការគ្រប់គ្រងសំរាមដើម្បីបង្កើតបានបរិស្ថានសិក្សាស្អាតមួយដែលមានប្រសិទ្ធភាព នាំឱ្យលទ្ធផលនៃការសិក្សារបស់សិស្សទទួលបានភាពជោគជ័យ។

## ១.៦ វិសាលភាព និងដែនកំណត់នៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះមានវិសាលភាព និងដែនកំណត់ដែលនិងត្រូវធ្វើឡើងដោយកំណត់យកចំនួន ៣ ស្រុក គឺស្រុកអង្គរបុរី ស្រុកព្រៃកប្បាស ស្រុកត្រាំកក់ ចំនួន៦សាលា និង១កម្រិតថ្នាក់ទី៦តែប៉ុណ្ណោះដោយមិនសិក្សាសាលាទាំងអស់ទេ។ សាលាបឋមសិក្សាគោលដៅចំនួន០៦រួមមាន៖

(១) បឋមសិក្សាភ្នំបាទេព ស្រុកអង្គរបុរី ចំនួនសិស្ស៦៤នាក់ និងគ្រូ២នាក់

(២) បឋមសិក្សាហ៊ុនសែនអង្គរបុរី ស្រុកអង្គរបុរី ចំនួនសិស្ស៧៤៧ នាក់ និងគ្រូ ២៦នាក់

(៣) បឋមសិក្សាហ៊ុនសែនបានយស្រុកព្រៃកប្បាសចំនួនសិស្ស៧១៤៨៣នាក់ និងគ្រូ១៨នាក់

(៤) បឋមសិក្សាព្រៃល្វា ស្រុកព្រៃកប្បាស ចំនួនសិស្ស៧០៧នាក់ និងគ្រូ ១២នាក់

(៥) សាលាបឋមសិក្សាអង្គតាសោម ស្រុកត្រាំកក់ ចំនួនសិស្ស៦០៩នាក់ និងគ្រូ ១៣នាក់

(៦) សាលាបឋមសិក្សាអង្គរុន ស្រុកត្រាំកក់ ចំនួនសិស្ស៤១៥នាក់ និងគ្រូ១៦នាក់

សាលាបឋមសិក្សាទាំង០៦ខាងលើ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ការិយាល័យស្រុកអង្គរបុរី ស្រុកព្រៃកប្បាស ស្រុកត្រាំកក់ និងមន្ទីរអប់រំ យុវជន និងកីឡាខេត្តតាកែវ សម្រាប់យកមកធ្វើសំណាក ដោយជ្រើសរើសយក គណៈគ្រប់គ្រងចំនួន ៦រូប គ្រូបង្រៀនក្នុងសាលាបឋមសិក្សាទាំងអស់ សិស្សថ្នាក់ទី៦ និងសហគមន៍ប្រមាណចំនួន ១២នាក់ សម្រាប់ការសិក្សាស្រាវជ្រាវនេះ។ ក្នុងនោះផងដែរអ្នកស្រាវជ្រាវបានកំណត់យកកម្រិតថ្នាក់ទី៦ដោយហេតុសិស្សអាចចូលរួមបញ្ចេញមតិនិងឆ្លើយសំណួរបាន។

គោលបំណងនៃការជ្រើសរើសទីតាំងនេះ គឺអាចតំណាងឱ្យសាលាបឋមសិក្សាទាំងអស់ក្នុងខេត្តតាកែវដោយសារតែសាលាមានចំនួនសិស្សច្រើន មធ្យម និងសិស្សតិច តំបន់ជួបការលំបាក តំបន់ប្រជុំជន តំបន់ជនបទ សាលាស្អាត និងសាលាធម្មតា។ ជាពិសេសជាផ្នែកមួយជួយបំផុសស្មារតីស្រលាញ់ថែរក្សាបរិស្ថានសិក្សា និងជំរុញឱ្យសាលាបឋមសិក្សាទាំងអស់ មានការអភិវឌ្ឍន៍សោភ័ណភាពបរិស្ថានសិក្សាកាន់តែប្រសើរជាងមុន។

ម្យ៉ាងវិញទៀត ការស្រាវជ្រាវនេះធ្វើឡើងនៅទីតាំងសាលារៀនបឋមសិក្សាទាំងនេះ ដោយសារមានភាពងាយស្រួលសម្រាប់ការចុះសិក្សា និងទីតាំងដែលមានបញ្ហាប្រឈម ជាមួយបញ្ហានៃការរៀបចំបរិស្ថានសិក្សាជាក់ស្តែង និងអាស្រ័យដោយពេលវេលាខ្លី ឯកសារ និងធនធានមានកំណត់ទើបអ្នកសិក្សាមិនអាចលើកយកសាលាបឋមសិក្សាទាំងអស់ និងកម្រិតថ្នាក់ផ្សេងៗទៀត ក្រៅពីកម្រិតថ្នាក់ខាងលើ សម្រាប់ការសរសេរនិក្ខេបបទនេះ។ មួយវិញទៀតអ្នកស្រាវជ្រាវមិនបានសិក្សាលម្អិតទៅលើខ្លឹមសារនិយមន័យ និងឧបករណ៍វង្វាយតម្លៃសាលាស្អាតទាំងអស់នោះទេ។ ដោយការសិក្សានេះផ្តោតសំខាន់លើទស្សនៈរបស់នាយក គ្រូ សិស្ស និងសហគមន៍ បញ្ហាប្រឈមនានា និងសំណូមពរក្នុងការរៀបចំបរិស្ថានសិក្សា។

ការសិក្សាផ្តោតសំខាន់ទៅលើ៖

១. ស្ថានភាពនៃការរៀបចំបរិស្ថានសិក្សានៅកម្រិតបឋមសិក្សា នាពេលបច្ចុប្បន្ន

២. បញ្ហាប្រឈមនានា និងសំណូមពរក្នុងការរៀបចំបរិស្ថានសិក្សា។

ចំពោះរយៈពេលនៃការសិក្សាគឺ ចាប់ពីខែមេសា ដល់ខែវិច្ឆិកា នៅឆ្នាំ២០២៣។

## ១.៧ ក្របខ័ណ្ឌគោលគំនិតនៃការស្រាវជ្រាវ

ក្របខ័ណ្ឌគោលគំនិតនៃការសិក្សាស្រាវជ្រាវលើប្រធានបទ "ទស្សនៈរបស់នាយក គ្រូ សិស្ស និងសហគមន៍ ចំពោះការរៀបចំបរិស្ថានសិក្សានៅកម្រិតបឋមសិក្សាក្នុងខេត្តតាកែវ" គឺដើម្បីសិក្សាពីស្ថានភាពនៃការរៀបចំបរិស្ថានសិក្សានៅកម្រិតបឋមសិក្សាក្នុងខេត្តតាកែវ សិក្សាពីបញ្ហាប្រឈមនានា ក្នុងការរៀបចំបរិស្ថានសិក្សានៅបឋមសិក្សា ដំណោះស្រាយ និងសំណូមពរ។




រូបភាព ១.០ រៀបរៀងដោយ និស្សិត លឿង កុសល (ក្របខ័ណ្ឌគោលគំនិតនៃការសិក្សាស្រាវជ្រាវ)

## ១.៨ រចនាសម្ព័ន្ធស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការស្រាវជ្រាវនេះ មាន៥ដែលរួមមាន៖

**ជំពូកទី១៖** សេចក្តីផ្តើម ពណ៌នាដោយសង្ខេបទៅលើលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ គោលដៅនៃការស្រាវជ្រាវ សំណួរនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ និយមន័យនៃពាក្យគន្លឹះ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

**ជំពូកទី២៖** រំលឹកទ្រឹស្តី ធ្វើការបកស្រាយ និងពន្យល់យ៉ាងលម្អិតទៅលើទ្រឹស្តីដែលទាក់ទងទៅនឹងការយល់ឃើញ និងការរៀបចំបរិស្ថានសិក្សាដើម្បីឱ្យបរិស្ថានសិក្សាកាន់តែល្អប្រសើរ។

**ជំពូកទី៣៖** វិធីសាស្ត្រនៃការស្រាវជ្រាវ ជំពូកនេះនឹងលើកឡើងពីវិធីសាស្ត្រនៃការស្រាវជ្រាវ នីតិវិធីនៃការប្រមូលទិន្នន័យ ការជ្រើសរើសភាគសំណាក ឧបករណ៍ស្រាវជ្រាវ ការប្រមូលទិន្នន័យ ការវិភាគទិន្នន័យ និងក្រមសីលធម៌ ។

**ជំពូកទី៤៖** លទ្ធផល និងការពិភាក្សា ជំពូកនេះនឹងធ្វើការពិភាក្សាយ៉ាងលម្អិតទៅ លើកម្រងសំណួរសម្រាប់យកមកវិភាគទិន្នន័យ ធ្វើការបកស្រាយទិន្នន័យដែលប្រមូលបានជាក់ស្តែង និងវិភាគបញ្ហាចំណុចខ្លាំង ចំណុចខ្សោយនៃការស្រាវជ្រាវ។

**ជំពូកទី៥៖** សន្និដ្ឋាន និងសំនូមពរ ជំពូកនេះបានសង្ខេបគ្រប់ទាំងអស់នូវអ្វីដែលបានរកឃើញវិភាគ និងផ្តល់ជាយោបល់ឬជាសំណូមពរសម្រាប់ធ្វើការកែលម្អ។




រូបភាព១.១៖ រៀបរៀងដោយនិស្សិត លឿង កុសល (សង្ខេបពីរចនាសម្ព័ន្ធនៃការស្រាវជ្រាវទាំង៥ជំពូក)

# ជំពូក ២

# ការរំលឹកទ្រឹស្តី

# ជំពូក២

# ការរំលឹកទ្រឹស្តី

សាលារៀនជាមជ្ឈមណ្ឌលសម្រាប់បណ្តុះបណ្តាលពលរដ្ឋឱ្យមានសមត្ថភាព និងគុណធម៌ដើម្បីរួមចំណែកអភិវឌ្ឍន៍សហគមន៍ក៏ដូចជា ប្រទេសឱ្យរីកចម្រើន តាមរយៈហេដ្ឋារចនាសម្ព័ន្ធរូបវន្តបម្រើឱ្យការបង្រៀន និងរៀនសមស្របរួមមាន វិធីសាស្ត្រគរុកោសល្យ បរិស្ថានសិក្សាស្អាត ការគ្រប់គ្រង ការដឹកនាំដែលមានភាពល្អប្រសើរសម្រាប់ធានាដល់ដំណើរការប្រព្រឹត្តប្រកបទៅដោយប្រសិទ្ធភាព និងនិរន្តភាព (បាន គនហេង ២០១៩)។

ហេតុនេះការស្រាវជ្រាវមានគោលបំណងឈ្វេងយល់ពីការរៀបចំ បរិស្ថានសិក្សា បញ្ហាប្រឈមនានាដែលកើតមានឡើងនៅក្នុងសាលាបឋមសិក្សា ដើម្បីទទួលបានបរិស្ថានសិក្សាមួយដ៏ល្អប្រសើរ ដែលនាំឱ្យគុណភាពនៃការបង្រៀន និងរៀនរបស់គ្រូ សិស្ស កាន់តែប្រសើរឡើង។

## ២.១ និយមន័យប្រតិបត្តិនៃពាក្យគន្លឹះ

នៅក្នុងការសិក្សាស្រាវជ្រាវនេះ ជាដំបូងត្រូវសិក្សាពាក្យមួយចំនួនជាមុនសិនរួមមាន៖

**ទស្សនៈ៖** ពាក្យនេះមានន័យថា ការឃើញ ដំណើរយល់ឃើញ បញ្ញាសាមញ្ញ ដែលជាដំណើរនៃរបៀបដែលព័ត៌មានត្រូវទទួលបានតាមរយៈឧបករណ៍ទទួលអារម្មណ៍ (Kumar, 2010)។

**ការរៀបចំ៖** ការរៀបចំជាសំណុំសកម្មភាពពិគ្រោះគ្នា ក្នុងបំណងធ្វើអោយមានរបៀបរៀបរយនៃការរស់នៅការតាំងទីរបស់មនុស្សរបៀបរៀបរយចំពោះសកម្មភាពសំណង់សំភារៈបរិក្ខារនិងមធ្យោបាយគមនាគមន៍ នៅលើដែនដីណាមួយ (ក្រសួងអប់រំ យុវជន និងកីឡា ២០១៧)។

**បរិស្ថានសិក្សា៖** សំដៅដល់អ្វីៗទាំងអស់ដែលមាននៅក្នុងបរិវេណ និងជុំវិញគ្រឹះស្ថានសិក្សាដូចជាអាគារសិក្សា បន្ទប់រៀន កន្លែងលក់ដូរ ឬរៀបចំចំណីអាហារ របង សម្ភារៈរូបវន្តផ្នែកអនាម័យ សម្ភារៈសិក្សាសួនច្បារ សួនបន្លែ រុក្ខជាតិជាដើម (ក្រសួងអប់រំ យុវជន និងកីឡា ២០១៨)។

## ២.២ ការដឹកនាំ និងការគ្រប់គ្រង

### ២.២.១ គោលដៅអប់រំជាតិ និងសមាសភាពទាំង៥នៃការអប់រំ

ក្រសួងអប់រំ យុវជន និងកីឡា បានកំណត់គោលដៅសម្រាប់ការអប់រំ គឺធ្វើឱ្យសិស្សក្លាយជាមនុស្សពេញលេញរីកចម្រើនលូតលាស់គ្រប់ផ្នែក មានតុល្យភាពរវាងវៃ ប្រាជ្ញាស្មារតីសញ្ចេតនា និងរូបកាយ។ ដែលនាំឱ្យគោលដៅនេះកសាងបានពលរដ្ឋថ្លៃថ្នូរ មានចំណេះដឹង បំណិន និងឥរិយាបថ។

មិនតែប៉ុណ្ណោះការអប់រំអាចនាំឱ្យសិស្សក្លាយជាពលរដ្ឋសាកល ដែលជាធាតុសំខាន់មួយនៅក្នុងជំនាញសតវត្សទី២១ ស្របទៅនឹងស្តង់ដាសាលាបឋមសិក្សាមាន៥យ៉ាងគឺស្អាត របៀប សុខភាព ទៀងពេល និងសមាធិ (ក្រសួងអប់រំ យុវជន និងកីឡា ២០១៧)។

រីឯការអប់រំត្រូវតែមានសមាសភាព៥យ៉ាងដូចជា ការអប់រំសីលធម៌ ការអប់រំបញ្ញា ការអប់រំកាយនិងកីឡា ការអប់រំពលកម្ម និងការអប់រំសោភ័ណ។ សម្រាប់សសរស្តម្ភទាំង៥នៃការអប់រំថ្នាក់បឋមសិក្សារួមមាន៖ វិន័យ អនាម័យ បៃតង គុណភាព និងសុខដុម (ក្រសួងអប់រំ យុវជន និងកីឡា ២០១៩)។ ដោយឃើញថាបរិស្ថានសិក្សា ជាផ្នែកមួយដ៏សំខាន់ដែលចំចាច់សម្រាប់តាមសាលា ត្រូវរៀបចំឱ្យកាន់តែប្រសើរ ដែលក្រសួងអប់រំ យុវជន និងកីឡា មានការយកចិត្តទុកដាក់ដែលមានដាក់បញ្ចូលនៅពេលបើកបវេសនកាលសិក្សាឆ្នាំ២០២៣-២០២៤។

លើសពីនេះទៀត ក្រសួងបរិស្ថាន (២០២៣) បានដាក់ចេញនូវការយន្តការចុះតាមសាលានីមួយៗនៅតាមបណ្តាខេត្ត ពីប្រធានបទថ្ងៃនេះខ្ញុំឈប់ប្រើប្លាស្ទិកជាដើម។

### ២.២.២ ស្ថិតិសាលារៀនបឋមសិក្សានៅប្រទេសកម្ពុជា និងខេត្តតាកែវ

ផ្អែកតាមស្ថិតិ និងសូចនាករអប់រំសាធារណៈឆ្នាំ ២០២១ -២០២២ របស់ក្រសួងអប់រំបានឱ្យដឹងថាសាលាបឋមសិក្សាទូទាំងប្រទេស ទូទាំងខេត្ត និងនៅតាមសាលាគោលដៅដូចតទៅនេះ៖

| បរិយាយ | ចំនួនសាលា | សាលាបឋមសិក្សា | សិស្ស | បុគ្គលិក |
|---|---|---|---|---|
| សាលាទូទាំងប្រទេស | ៧ ៣០៦ | ៦៣ ២៦៣ | ២ ០៣៦ ៥៦៦ | ៤៥ ១៤៨ |
| ខេត្តតាកែវ | ១៧៩ | ៣ ៥០៤ | ១១៣ ៦៧៥ | ៣ ៦៨៩ |

| | | | | |
|---|---|---|---|---|
| ស្រុកព្រែកប្រាសព | ៤១ | ៤០៣ | ១៣៧៦ | ២៣៦ |
| ស្រុកអង្គរបុរី | ៣៨ | ២៨០ | ៩ ៨៧៨ | ៣៩១ |
| ស្រុកត្រាំកក់ | ៦៤ | ៦៤៣ | ២ ៣៤៩១ | ៤៨៨ |

ប្រភពះស្ថិតិ និងសូចនាករអប់រំសាធារណៈឆ្នាំ ២០២១ -២០២២ របស់ក្រសួងអប់រំ (www.moeys.gov.kh)

តាមសាលានីមួយៗមានចំនួនសិស្ស គ្រូ និងសិស្សថ្នាក់ទី៦ សរុបដូចដែលបង្ហាញក្នុងតារាងខាងក្រោមៈ

| បរិយាយ | សិស្សសរុប | សិស្សថ្នាក់ទី៦ | គ្រូ |
|---|---|---|---|
| បឋមសិក្សាបានយ(តំបន់ធម្មតា) | ៧១៤/៣៤៣ | ១២១ | ១៨ |
| បឋមសិក្សាព្រៃល្វា(តំបន់ប្រជុំជន) | ៧០៧/៣៧០ | ៨១ | ១២ |
| បឋមសិក្សាហ៊ុនសែនអង្គរបុរី(ប្រជុំជន) | ៧៤៧/៣៣៧ | ១២៥ | ២៧ |
| បឋមសិក្សាភ្នំបាទេព(លំបាក) | ៦៤/២៩ | ០៩ | ២ |
| បឋមសិក្សាអង្គតាសោម(ប្រជុំជន) | ៦០៩/៣០៤ | ៧៩ | ១៣ |
| បឋមសិក្សាអង្គរុន(ធម្មតា) | ៤១៥/២០៧ | ៦២ | ១៦ |

ប្រភពស្ថិតិ និងសូចនាករអប់រំសាធារណៈឆ្នាំ ២០២១-២០២២ របស់ក្រសួងអប់រំ (www.moeys.gov.kh)

### ២.២.៣ គោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព

យោងតាមគោលនយោបាយ ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព (២០២១) បានលើកឡើងពី ការមានសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ជាកត្តាគន្លឹះដែលផ្តល់ភាពអនុគ្រោះដល់ដំណើរការនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងវិស័យផ្សេងៗទៀត មានការរីកចម្រើនស្របតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណគ្រប់ដំណាក់កាលរបស់រាជរដ្ឋាភិបាលកម្ពុជា។ ទោះបីយើង មានសន្តិភាព ស្ថិរភាពយ៉ាងរឹងមាំ ប៉ុន្តែសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ បញ្ហាសុខមាលភាពរបស់ប្រជាពលរដ្ឋ និងផ្តល់សេវាចាំបាច់នានា នៅតែជាបញ្ហាអាទិភាពដែលត្រូវយកចិត្តទុកដាក់ជាប្រចាំ ដើម្បីធានាឱ្យជនគ្រប់រូប និងសង្គមទាំងមូល មានសុវត្ថិភាពយ៉ាងល្អប្រសើរ ជីវភាពរុងរឿង និងសុខដុមរមនា។

ក្នុងនោះផងដែរក៏មានចំណុចមួយ នៃគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព បានលើកឡើងទាក់ទងភូមិ ឃុំ សង្កាត់ មានអនាម័យ មានសោភ័ណភាពល្អ និងមានបរិស្ថានល្អ គឺមានវិធានការក្នុង

ការគ្រប់គ្រងថែរក្សានិងការពារធនធានធម្មជាតិ និងបរិស្ថាន អនាម័យក្នុងភូមិ ឃុំ សង្កាត់ប្រកបដោយប្រសិទ្ធភាព ជាពិសេសយន្តការដោះស្រាយបញ្ហាសំរាម សំណល់រឹង និងសំណល់រាវ សំដៅធ្វើឱ្យភូមិ ឃុំ សង្កាត់ មានសោភ័ណភាព គ្មានសំរាម ធ្វើឱ្យការរស់នៅប្រកបដោយផាសុកភាព មានភាពថ្លៃថ្នូរ ស៊ីវិល័យ និងមានអនាគតរុងរឿង ផ្អែកតាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន និងក្រសួង ស្ថាប័នពាក់ព័ន្ធ។ បញ្ជ្រាបការអប់រំដល់ប្រជាពលរដ្ឋ អំពីច្បាប់ គោលការណ៍និងវិធានការនានា ស្តីពីកិច្ចការពារថែរក្សាបរិស្ថាន រួមទាំងវិធីសាស្ត្រនៃការរក្សាសុខភាព ការចូលរួមថែរក្សាអនាម័យ សុវត្ថិភាពចំណីអាហារ ឧទាហរណ៍៖ ការផលិតស្រាខុសបទដ្ឋានបច្ចេកទេស ការចែកចាយ លក់ដូរ និងប្រើប្រាស់ថ្នាំពេទ្យ គ្រឿង សម្អាង ក្លែងក្លាយ ឬអត់គុណភាព ។

## ២.៣ ស្តង់ដាសាលារៀនបឋមសិក្សា

នៅឆ្នាំ២០២៧ ក្រសួងអប់រំ យុវជន និងកីឡា បានចេញផ្សព្វផ្សាយ ឯកសារស្តីពី ស្តង់ដាសាលារៀនបឋមសិក្សា ក្នុងគោលបំណងកំណត់នូវស្តង់ដាសាលារៀន ដើម្បីលើកកម្ពស់គុណភាពការអប់រំនៅកម្រិតបឋមសិក្សាដែលមាន៩ស្តង់ដារួមមាន៖

១. វត្ថុបំណងគោលនយោបាយរបស់សាលារៀន

២. បំណែងចែកកម្មវិធី និងការបង្រៀន រៀន

៣. ការងារមាតាបិតាសិស្ស និងសហគមន៍

៤. សិស្ស និងសេវាជួយសិស្ស

៥. ការដឹកនាំ និងគ្រប់គ្រង

៦. ធនធានមនុស្ស និងរចនាសម្ព័ន្ធគ្រប់គ្រង

៧. កម្មវិធីសិក្សា និងសម្ភារៈបង្រៀន និងរៀន

៨. ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន

៩. ការគ្រប់គ្រងហិរញ្ញវត្ថុ

ដែលក្នុងនោះផងដែរមានស្តង់ដាទី៨បានលើកឡើងពីហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន៖

(១) អគារសិក្សា និងបន្ទប់រៀន៖ មានបន្ទប់សិក្សាតាមនិយាមគរុកោសល្យតាមបទដ្ឋានបច្ចេកទេសបន្ទប់សិក្សាធៀបនឹងចំនួនសិស្សតាមនិយាមគរុកោសល្យ ទីចាត់ការ សាលប្រជុំ សាលគ្រូបង្រៀន បន្ទប់ធនធាន បន្ទប់ថែទាំសុខភាព បង្គន់អនាម័យបុរស ស្ត្រីស្របតាមសមាមាត្រចំនួនសិស្ស អគារ និងបន្ទប់ទាំងអស់មានជម្រាលសម្រាប់សិស្សពិការ បំពាក់សម្ភារៈបរិក្ខារអគ្គិសនីនៅលើអគារ និងបន្ទប់សិក្សា។

(២) បរិស្ថានសាលារៀន៖ មានរបង និងទ្វាសាលារៀនគត់មត់ ស្លាក ខ្លោងទ្វារទីធ្លាសាលាសួនច្បារ ដង់ទង់ជាតិ សួនជីវៈ ចម្រុះ ទីលានកីឡា សួនកុមារ មណ្ឌលវប្បធម៌ ប្រពៃណី រោងបាយ ធុងសំរាមឡដុតសំរាម កន្លែងចតយានជំនិះគ្រប់ប្រភេទ និងមានសណ្តាប់ធ្នាប់ មានផ្លូវដើរពីអគារមួយទៅអគារមួយទៀត និងមានដើមឈើជាម្លប់ បើមានកន្លែងលក់ចំណីអាហារត្រូវមានអនាម័យ និងសុវត្ថិភាព។

ក្រសួងអប់រំ យុវជន និងកីឡា (២០២២) បានដាក់ចេញគោលការណ៍ប្រត្តិបត្តិស្តង់ដា ស្តីពីការលើកកំពស់សុខភាពសិក្សាសម្រាប់គ្រឹះស្ថានចំណេះទូទៅ ក្នុងនោះផងដែរ មានសូចចនាករទី១៣ដែលពាក់ព័ន្ធជាមួយបរិស្ថានសិក្សា គឺអនាម័យបរិស្ថាន គ្រឹះស្ថានសិក្សាស្អាត និងមានសុវត្ថិភាព៖ បរិស្ថានសិក្សាមានភាពចាំបាច់ណាស់ចំពោះអ្នកសិក្សា ដែលគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាទាំងអស់ត្រូវយកចិត្តទុកដាក់ជាចម្បងដោយត្រូវគិតពីសុវត្ថិភាព បរិយាបន្ន ផាសុកភាព និងមេត្រីភាព ដោយធ្វើយ៉ាងណាធ្វើឱ្យគ្រឹះស្ថានសិក្សាគ្មានកន្លែងដក់ទឹក ភក់ ជ្រាំ គ្មានសំរាម គ្មានសំបុកពីងពាង គ្មានផ្សែងបារី ដោយគ្មានការប្រើប្រាស់ផលិតផលប្លាស្ទិក។ ផ្ទុយទៅវិញគ្រឹះស្ថានសិក្សាត្រូវបំពាក់នូវស្លាកសញ្ញាសុវត្ថិភាពផ្សេងៗមានរបងការពារកន្លែងមានហានិភ័យ មានកន្លែងជួបជុំពេលមានហានិភ័យ អគ្គីភ័យ គ្រោះទឹកជំនន់ មានបរិស្ថានស្អាតជាប់ជាប្រចាំ។

ហេតុនេះគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា ត្រូវដឹកនាំចលនាស្អាតក្នុងចំណោមក្រុមប្រឹក្សា កុមារយុវជន ពិសេសត្រូវមានយន្តការបោសសម្អាតបរិវេណគ្រឹះស្ថានសិក្សា បន្ទប់រៀន និងកន្លែងផ្សេងៗទៀតនៃគ្រឹះស្ថានសិក្សា ដើម្បីធានាថា បុគ្គលិកអប់រំនិងអ្នកសិក្សាមានសុវត្ថិភាព។ និងសូចនាករទី៤៖ សួនស្មៅសួនផ្កា ដើមរុក្ខជាតិសម្រាប់លម្អ និងដើមឈើម្លប់៖ ការរៀបចំឱ្យមានសួនច្បារនៅក្នុងបរិវេណគ្រឹះស្ថាន

សិក្សាចាត់ទុកថា ជាកត្តាមួយសំខាន់បំផុតនៅក្នុងពេលបច្ចុប្បន្នក៏ដូចជាទៅអនាគត ព្រោះសួនច្បារជាចំណុចសំខាន់មួយដោយសារជាមុខជាមាត់របស់សាលា (ក្រសួងអប់រំ យុវជន និងកីឡា ២០២២)។

ជាការបំពេញបន្ថែមដល់ចំណីចក្ខុវិញ្ញាណ និងភាពរីករាយដល់មនុស្សគ្រប់រូបដែលបានចូលមកដល់ទីកន្លែងនេះ ព្រមទាំងទាក់ទាញសិស្សានុសិស្សឱ្យចង់មកសាលាផងដែរ។ ម្យ៉ាងវិញទៀតសួនច្បារអាចកាត់បន្ថយភាពតានតឹងចិត្ត និងជួយបន្ធូរអារម្មណ៍ក្នុងខួរក្បាល។ ដើម្បីបង្កើតសួនច្បារមួយឱ្យសមស្របតាមគ្រឹះស្ថានសិក្សា លោកគ្រូ អ្នកគ្រូគួរគិតដល់ចំណុចដូចខាងក្រោមធ្វើការសិក្សាពីសួនច្បារដែលគ្រឹះស្ថានសិក្សាផ្សេងៗ ដោយបានធ្វើកន្លងមក ពិសេសគ្រឹះស្ថានសិក្សាដែលទទួលស្គាល់ថាបរិស្ថានស្អាត (ក្រសួងអប់រំ យុវជន និងកីឡា ២០២២)។

សង្កេតមើលទីតាំងរបស់គ្រឹះស្ថានសិក្សាដែលត្រូវរៀបចំសួនច្បារ និងធ្វើការវិភាគដើម្បីកំណត់ថាតើរុក្ខជាតិណាដែលនឹងលូតលាស់ល្អបំផុត។ ពិចារណាបង្កើតជាសួនឈើប្រណិតដូចជា នាងនួន បេងធ្នង់ ជាដើម គ្រឹះស្ថានសិក្សាមានដីធំទូលាយ។ ពិចារណាពីការដាក់វត្ថុតុបតែងកុំធ្វើឱ្យវាហួសប្រមាណបើមិនដូច្នេះទេវាធ្វើឱ្យសួនមានសភាពស្មោកស្មះ។

ហេតុនេះសូចនាករទាំងអស់នេះសុទ្ធតែមានភាពពាក់ព័ន្ធ ក្នុងការរៀបចំបរិស្ថានសិក្សានៅតាមសាលាឱ្យមានផាសុកភាព(ក្រសួងអប់រំ យុវជន និងកីឡា ២០១៧)។ ទោះបីជាមានស្តង់ដា លក្ខណៈវិនិច្ឆ័យព្រមទាំងសូចនាករ ដូចបានបង្ហាញខាងលើក៏ដោយមិនមានន័យ ថាគ្រឹះស្ថានសិក្សា(បឋមសិក្សា និងមធ្យមសិក្សា) ដែលចង់ឱ្យគ្រឹះស្ថានសិក្សារបស់ខ្លួនត្រូវបានទទួលស្គាល់ថា ជាសាលាបំពេញគ្រប់នូវសូចនាករទាំងអស់នោះទេ។

ដោយមូលហេតុគណៈគ្រប់គ្រងសាលាត្រូវអនុវត្តន៍តាមសកម្មភាពអប់រំបរិស្ថានមួយចំនួន ដើម្បីលើកកម្ពស់ការយល់ដឹង និងចំណេះដឹងបរិស្ថានសិក្សាដល់គ្រូ និងសិស្ស ព្រមទាំងសហគមន៍ជុំវិញសាលារួមមាន៖

- ភាពបៃតងរបស់សាលារៀន ការដាំស្មៅ ដាំដើមឈើ បន្លែ ការថែសួនច្បារ សួនជីវៈចម្រុះឱ្យមានភាពបៃតងសម្រាប់ការសិក្សារបស់សិស្ស ការដាំដើមឈើហូបផ្លែ ការដាំឈើ (ប្រភេទក្នុងស្រុក) ការបង្កើតជាប្លង់ដាំដើមឈើ មានការធ្វើកសិកម្មសិរីរាង្គ ការដាំដើមកោងកាង។
- ថាមពលក្នុងសាលា សាលារៀនគួរកាត់បន្ថយ ឬបញ្ឈប់ប្រើថាមពលឥន្ធនៈផូស៊ីលមកប្រើប្រាស់ថាមពលស្អាតដោយការប្រើប្រាស់ថាមពលកកើតឡើងវិញដូចជា ការប្រើប្រាស់អំពូលភ្លើង និងបរិក្ខារដែលសន្សំសំចៃអគ្គិសនី( ស៊ីភ្លើងតិច ) ការប្រើឧស្ម័នចរន្តទឹកជាថាមពលដើម្បីកាត់បន្ថយការប្រើប្រាស់អគ្គិសនីឱ្យបានច្រើន។ ការប្រើប្រាស់ថាមពលកកើតឡើងវិញមាន( បន្ទះសូឡា ខ្យល់ )ការបង្កើតលំហូរ និងពន្លឺធម្មជាតិក្នុងសាលារៀនដើម្បីកាត់បន្ថយការប្រើប្រាស់អគ្គិសនី។
- ការអភិរក្សទឹកក្នុងសាលារៀន យុទ្ធនាការសហគមន៍សាលារៀន ដើម្បីសន្សំសំចៃទឹក សាលាត្រូវណែនាំដល់សិស្សឱ្យយកដបទឹកដែលប្រើរួចមកធ្វើជាធុងស្រោចដំណាំក្នុងសាលារៀន រៀបចំការត្រង់ទឹកភ្លៀងដាក់ដបប្លាស្ទិកនៅតាមអាងទឹក ឬជីកអណ្តូង បង្គន់ ដើម្បីកាត់បន្ថយការប្រើប្រាស់ទឹកការស្រោចស្រពដោយប្រើបច្ចេកវិទ្យា។
- ការអភិរក្សធនធាន ការគ្រប់គ្រងសំណល់ បែងចែកតាមប្រភេទសំណល់ដោយអនុវត្តគោលការណ៍៣យ៉ាងគឺ កាត់បន្ថយ ប្រើប្រាស់ឡើងវិញ និងការកែច្នៃឡើងវិញ( សម្រាប់គ្រប់គ្រងសំណល់ប្លាស្ទិក ) ជាកត្តាចំបាច់សម្រាប់អ្នកគ្រប់គ្រងសាលារៀន។ សម្រាប់ការគ្រប់គ្រង សំណល់ប្លាស្ទិកឱ្យបានល្អ និងមានប្រសិទ្ធភាពខ្ពស់ សាលារៀនត្រូវមានវិធានការចំពោះការបោះចោលសំរាមក្នុងបរិវេណសាលា ពិសេសត្រូវមានធុងសំរាមគ្រប់គ្រាន់ក្នុងបរិវេណសាលារៀន។
- ត្រូវបំផុសការប្រើប្រាស់មធ្យោបាយធ្វើដំណើរដែលមានមេត្រីភាពនឹង បរិស្ថាន ដើម្បីកាត់បន្ថយការបំពុលបរិស្ថាន ធ្វើអនាម័យដូចជា ការតាមដានភាពស្អានក្នុងបន្ទប់ទឹក និងការប្រើស្បែកជើងធ្វើអំពីសម្ភារៈប្រើបានឡើងវិញ ដួសដុលឡើងវិញនូវសម្ភារៈទាំងអស់ដូចជា កែច្នៃគ្រឿងសង្ហារឹមដែលប្រើហើយ។

- ភាពស្អាត និងសុខភាពរបស់សិស្ស សាលារៀនត្រូវហាមប្រាមអាហារសម្រន់ ឬអាហារដែល មានរសជាតិ ពណ៌សិប្បនិម្មិត និងហួសសុពលភាពធ្វើឱ្យសិស្សងងុយគេង ឬឈឺក្លាមៗ ឬក៏នៅពេលក្រោយ(ដូចជាអាហារដែលមាន ជាតិប៊ីចេងច្រើន មេស្ករ ល័ក្ខជាដើម ត្រូវហាមប្រើប្រាស់ថង់ប្លាស្ទិកក្នុង ការវេចខ្ចប់ចំណីអាហារ និងភេសជ្ជៈនៅតាមតូបលក់ចំណីក្នុងបរិវេណសាលារៀន។ លើកទឹកចិត្ត និងស្នើសិស្សឱ្យយកដបទឹក និងប្រអប់អាហារតាមខ្លួន ដើម្បីកាត់បន្ថយសំណល់។ មានការហាមប្រាមការប្រើប្រាស់សារធាតុមិនមានប៉ូស្ទើរីន នៅទីធ្លាសាលាផ្តួចផ្តើមឱ្យមានការជិះកង់ក្នុងសហគមន៍ ដើម្បីកាត់បន្ថយការបំពុល។ ផ្នែកអនាម័យមានការតាមដានភាពស្អាតក្នុងបន្ទប់ទឹក និងប្រើស្បែកជើងផ្ទាត់ក្នុង បន្ទប់ទឹក ដែលផលិតពីសម្ភារៈអាចប្រើប្រាស់ឡើងវិញ។
- ការសិក្សាការផ្សព្វផ្សាយ និងការយល់ដឹងពីបរិស្ថាន ការសិក្សាផ្សព្វផ្សាយ និងយល់ដឹងពីបរិស្ថានជាកត្តាសំខាន់សម្រាប់ធ្វើការជំរុញការកែលម្អ និងអភិវឌ្ឍបរិស្ថាន ក្នុងសាលារៀនឱ្យកាន់តែមានភាពប្រសើរឡើងដោយអនុវត្តការលើកកម្ពស់ការយល់ដឹងបរិស្ថាន។
- ព័ត៌មានផ្សព្វផ្សាយពីបរិស្ថានសិក្សានៅក្នុងបរិវេណសាលាអំពីការអប់រំបរិស្ថាន នៅតាមអគារសាលាទាំងអស់ រៀបចំព្រឹត្តិការណ៍ពិភពលោកដូចជាទិវាភពផែនដី បិទភ្លើងមួយម៉ោងដើម្បីភពផែនដី ម៉ោងបរិស្ថាន( ទិវាគ្មានថង់ប្លាស្ទិក និងរុក្ខជាតិជាដើម)។ សិក្ខាសាលាបណ្តុះបណ្តាលដល់លោកគ្រូអ្នកគ្រូ និងពិសេសសិស្សានុសិស្ស អំពីការអប់រំ បរិស្ថាន។ រៀបចំសកម្មភាពអប់រំបរិស្ថានតាមរយៈការបង្កើតក្រុមក្លឹប និងអង្គការផ្សេងៗ (ក្រសួងអប់រំ យុវជន និងកីឡា ២០១៧)។

### ២.៣.១ សាលារៀនស្អាត

សាលារៀនស្អាត ផ្តល់នូវវេទិកាសុវត្ថិភាពសម្រាប់អ្នកសិក្សា។ មុនពេលដែលអ្នកអាចរំពឹងថាអ្នកសិក្សានឹងទទួលបានជោគជ័យក្នុងការសិក្សា ពួកគេក៏គួរតែមានអារម្មណ៍ថាមានសុវត្ថិភាពទាំងផ្លូវចិត្ត និងរាងកាយផងដែរ។ ខណៈពេលដែលសាលារៀនភាគច្រើនចាត់វិធានការសុវត្ថិភាពរាងកាយ វេទិកាសិក្សាមិនមានច្រើនទេដែលគិតពីសុវត្ថិភាពផ្លូវចិត្តរបស់អ្នកសិក្សា(ក្រសួងអប់រំ យុវជន និងកីឡា ២០១៨)។

ក្រសួងអប់រំ យុវជន និងកីឡា នឹងរៀបចំកម្មវិធីប្រឡងប្រណាំងសាលារៀនស្អាត តាមរយៈរូបភាព ដែលនឹងប្រព្រឹត្តទៅជារៀងរាល់ខែដោយបានផ្តល់ ឱកាសដល់គ្រឹះស្ថានសិក្សាសាធារណៈទាំងអស់ ទូទាំងប្រទេស ចាប់ពីកម្រិតមត្តេយ្យសិក្សា ដល់ថ្នាក់ទី១២ ចូលរួមប្រកួតប្រជែងបង្ហាញស្នាដៃ។ ការផ្តួចផ្តើមកម្មវិធីនេះក្នុងគោលដៅលើកទឹកចិត្តគ្រឹះស្ថានសិក្សាទាំងអស់ ឱ្យយកចិត្តទុកដាក់ ការរៀបចំបរិស្ថានសាលាឱ្យបានស្អាត មានអនាម័យ មានខ្យល់អាកាសល្អបរិសុទ្ធ អំណោយផលដល់ការសិក្សារបស់សិស្សានុសិស្ស ដែលជាចំណែកមួយក្នុងការលើកកម្ពស់គុណភាពអប់រំនៅកម្ពុជា។ សម្រាប់ជ័យលាភីនឹងប្រកាសជារៀងរាល់ខែ ដោយសាលាដែលមាន បរិស្ថានសាលារៀនស្អាតជាងគេ គោរពតាមលក្ខខណ្ឌដែលបានកំណត់ នឹងទទួលបានលិខិតបញ្ជាក់ជ័យលាភីពីក្រសួងអប់រំ យុវជន និងកីឡា។

ក្នុងនោះផងដែរសាលាបឋមសិក្សា ស្វាយជ្រុំ ខេត្តស្វាយរៀង ដែលទទួលបានជ័យលាភីសាលារៀនស្អាតនាឆ្នាំកន្លងមក។ ក្រសួងអប់រំ យុវជន និងកីឡា បានអំពាវនាវ ឱ្យគ្រឹះស្ថានសិក្សាសាធារណៈនានាទូទាំងប្រទេស ត្រៀមខ្លួនក្នុងការចូលរួមកម្មវិធីប្រកួតប្រជែងផងដែរ។ សាលាបឋមសិក្សាចំនួន៣និងមធ្យមសិក្សាចំនួន៣ បានទទួលជ័យលាភីសាលាមេត្រីបរិស្ថានឆ្នាំ២០២១។

**ក. សម្រាប់កម្រិតបឋមសិក្សារួមមាន៖**

១) សាលាបឋមសិក្សា វត្តចែង ខេត្តបាត់ដំបង ជ័យលាភីកម្រិតមាស

២) សាលាបឋមសិក្សា ក្រវ៉ាន់ ខេត្តសៀមរាប ជ័យលាភីកម្រិតប្រាក់

៣) សាលាបឋមសិក្សា ឈើខ្លឹម ខេត្តត្បូងឃ្មុំ ជ័យលាភីកម្រិតសំរឹទ្ធ

**ខ. សម្រាប់កម្រិតមធ្យមសិក្សា**

១) វិទ្យាល័យ ហ៊ុន សែន មិត្តភាព ខេត្តព្រះសីហនុ ទទួលបានជ័យលាភីកម្រិតមាស

២) វិទ្យាល័យ ហ៊ុន សែន សម្ពះបុរៈខេត្តក្រចេះទទួលបានជ័យលាភីកម្រិតប្រាក់

៣) វិទ្យាល័យចំណេះទូទៅនិងបច្ចេកទេស ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ខេត្តកំពង់ឆ្នាំង ទទួលបានជ័យលាភីកម្រិតសំរិទ្ធ។

យោងក្រសួងបរិស្ថាន (២០២១) បានថ្លែងថាក្រសួងបរិស្ថានសូមវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារ សម្របសម្រួលកិច្ចសហប្រតិបត្តិការរវាងក្រសួងបរិស្ថាន និងក្រសួងអប់រំ យុវជន និងកីឡា ក្នុងក្របខ័ណ្ឌការងារអប់រំ ការងារបណ្តុះបណ្តាល ការសិក្សាស្រាវជ្រាវ និងការងារផ្តល់សេវាពិគ្រោះយោបល់វិស័យបរិស្ថាន ជាពិសេសគណៈកម្មការវាយតម្លៃសាលាមេត្រីបរិស្ថានដែលបានផ្តល់កិច្ចសហការយ៉ាងល្អប្រសើរ និងទទួលបានលទ្ធផលជាផ្លែផ្កាគួរឱ្យកត់សម្គាល់ក្នុងការរៀបចំការប្រឡងប្រណាំងសាលាមេត្រីភាពបរិស្ថានចំនួន៣។

ជាមួយគ្នានេះក្រសួងបរិស្ថាន ក៏សម្តែងនូវការកោតសរសើរខ្ពស់ចំពោះសាលាបឋមសិក្សា និងមធ្យមសិក្សាសរុបចំនួន៤៨ដែលបានចូលរួមក្នុងចលនាប្រឡងប្រណាំងមេត្រីភាពបរិស្ថាននៅឆ្នាំ២០២១ នេះដែលជាការប្រកួតប្រជែងសាលាមេតីបរិស្ថានរៀងរាល់២ឆ្នាំម្តងលើកទី៣។ ការប្រឡងប្រណាំងសាលាមេត្រីបរិស្ថានគឺជាគំនិតផ្តួចផ្តើមដ៏សំខាន់ និងជាយន្តការមួយដ៏មានសារៈសំខាន់ក្នុងចំណោមយន្តការ និងវិធានការជាច្រើនទៀតដែលក្រសួងបរិស្ថាន និងភាគីពាក់ព័ន្ធទាំងអស់បានខិតខំជំរុញអនុវត្តជាបន្តបន្ទាប់ សំដៅធ្វើឱ្យប្រសើរឡើងនូវកិច្ចគាំពារបរិស្ថាន ការការពារធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និងការរស់នៅដោយចីរភាព តាមរយៈការបញ្ជ្រាបចំណេះដឹង ចំណេះធ្វើក្នុងចំណោមកុមារ សិស្ស និងយុវជន។

នៅតាមសាលារៀន និងគ្រឹះស្ថានអប់រំដែលជាកន្លែងប្រមូលផ្តុំមានលក្ខណៈងាយស្រួលក្នុងការផ្លាស់ប្តូទម្លាប់ ផ្នត់គំនិត និងឥរិយាបទរបស់កុមារ និងយុវជនចំពោះ អនាម័យ និងបរិស្ថាន។ ក្រសួងបរិស្ថាន បានឲ្យដឹងថាការរៀបចំផ្តល់តម្លៃសាលាមេត្រីបរិស្ថានបានជំរុញ និងលើកទឹកចិត្តដល់សាលារៀនទាំងអស់បន្តវប្បធម៌ស្រឡាញ់ និងចូលរួមក្នុងសកម្មភាពមេត្រី បរិស្ថានកាន់តែប្រសើរឡើងថែមទៀត។ ដូចនេះសាលារៀនចាំបាច់ត្រូវសហការជិតស្និតជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ អ្នកពាក់ព័ន្ធដទៃទៀតក្នុងសហគមន៍ អាណាព្យាបាលសិស្ស ដើម្បីជានាឱ្យបាននូវការអប់រំបរិស្ថាន ដើម្បីមូលដ្ឋានស្អាត សុខភាពល្អ និងមានការអភិវឌ្ឍរុងរឿង។

សូមបញ្ជាក់ថា ចលនាសាលាមេត្រីបរិស្ថានកម្ពុជា ដើម្បីឆ្លុះបញ្ចាំងយ៉ាងច្បាស់នូវការយកចិត្តទុកដាក់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសរបស់ក្រសួងបរិស្ថាន និងក្រសួងអប់រំ យុវជន និងកីឡា

លើការបញ្ជ្រាបចំណេះដឹង ការផ្លាស់ប្តូរផ្នត់គំនិត ការលើកកម្ពស់ស្មារតីស្រឡាញ់បរិស្ថាន និងការជំរុញប្រតិបត្តិមេត្រីភាពបរិស្ថាន សំដៅគាំទ្រដល់កិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាព និងការរស់នៅដោយចីរភាព។

លើសពីនេះទៀតយុទ្ធនាការភ្នំពេញស្អាតឆ្នាំ២០២០ ត្រូវបានបិទបញ្ចប់កាលពីវេលាព្រឹកថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២០ ដែលប្រព្រឹត្តទៅនៅទីស្តីការក្រសួងបរិស្ថាន។ រយៈពេលពេញមួយខែ ភ្នំពេញស្អាតបានធ្វើសកម្មភាពជាច្រើនដើម្បីជំរុញការយល់ដឹងពីការថែរក្សាបរិស្ថាន ការគ្រប់គ្រងសំរាម និងការរស់នៅបែបអនាម័យ ជាពិសេសក្នុងបរិបទនៃការរស់នៅបែបគន្លងថ្មី។ ស្អាតជាទម្លាប់ថ្មី គឺជាអ្វីដែលយុទ្ធនាការភ្នំពេញស្អាតឆ្នាំ២០២០ បានដាក់ចេញជាទិសស្លោកថ្មីនៃបេសកកម្ម១ខែរបស់ខ្លួន។

នៅចុងបញ្ចប់នៃយុទ្ធនាការ បានរកឃើញជ័យលាភីគម្រោងទស្សនាទាន (សាលាបរិស្ថានស្អាត) ទាំង៣ផងដែរក្នុងនោះ

ក. ជ័យលាភី (ស្អាតច្នៃប្រឌិត)បានទៅសាលារៀនសុវណ្ណភូមិ

ខ. ជ័យលាភី(ស្អាតនិរន្តរភាព)បានទៅវិទ្យាល័យព្រះស៊ីសុវត្ថិ

គ. ជ័យលាភី (ស្អាតឆ្នើម) បានទៅសាលាប៉ែលជីអន្តរជាតិ។

ម្យ៉ាងវិញទៀត សាលាជាប់ជ័យលាភីសាលាស្អាតមានវិទ្យាល័យស្វាយរៀង បឋមសិក្សាវត្តចែងសាលាបឋមសិក្សាគងជ័យ សាលាបឋមសិក្សានិងវិទ្យាល័យហ៊ុនសែនមិត្តភាព និងអនុវិទ្យាល័យទីរួមខេត្តបានទទួលជ័យលាភីសាលាស្អាត ក្នុងក្របខណ្ឌទូទាំងប្រទេសពីក្រសួងអប់រំ យុវជន និងកីឡា។ បើតាមប្រកាសរបស់ក្រសួងអប់រំ ចុះហត្ថលេខាដោយលោក ហង់ជួន ណារ៉ុន កាលពីថ្ងៃទី១៩ មេសា។

បន្ថែមលើសពីនេះទៀត ពានរង្វាន់សាលាស្អាតដែលរៀបចំដោយក្រសួងអប់រំ យុវជន និងកីឡាបានរកឃើញសាលារៀនចំនួន ៥ ជាប់ជ័យលាភីសាលាស្អាតក្នុងក្របខណ្ឌទូទាំងប្រទេស។

ជ័យលាភីសាលាស្អាតទាំង ៥ រួមមានៈ

១. វិទ្យាល័យស្វាយរៀង ស្ថិតនៅ ក្រុងស្វាយរៀង ខេត្តស្វាយរៀង ជាប់ពានរង្វាន់ជ័យលាភីលេខ១ ដោយទទួលបាន ថវិកា ៥លានរៀល។

២. សាលាបឋមសិក្សាវត្តចែង ដែលស្ថិតស្រុកសង្កែ ខេត្តបាត់ដំបង ជាប់ពានរង្វាន់ ជ័យលាភីលេខ ២ ទទួលបានថវិកា ៤លានរៀល។

៣. ចំណែកពានរង្វាន់ជ័យលាភីលេខ៣ បានលើសាលាបឋមសិក្សាគងជ័យ ដែល ស្ថិតនៅស្រុកកងមាស ខេត្តកំពង់ចាម,

៤. ពានរង្វាន់ជ័យលាភីលេខ៤ បានលើសាលាបឋមសិក្សានិងវិទ្យាល័យហ៊ុនសែនមិត្តភាព ស្ថិតនៅក្រុងព្រះសីហនុ ខេត្តព្រះសីហនុ និងពានរង្វាន់ជ័យលាភីលេខ៥ បាន លើអនុវិទ្យាល័យទីរួមខេត្តមានទីតាំងនៅក្រុងច្បារមន ខេត្តកំពង់ស្ពឺ។

៥. ជ័យលាភីលេខ៣ លេខ៤ និង លេខ៥ ទទួលបានថវិកា ៣លានរៀលក្នុងមួយសាលា។ ក្រៅពីប្រគល់ពានរង្វាន់ជ័យលាភីសាលាស្អាត ក្រសួងអប់រំ យុវជន និង កីឡា ក៏បានប្រគល់ពានរង្វាន់នាយកល្អ និងគ្រូបង្រៀនល្អផងដែរ។

ការរៀបចំវាយតម្លៃជ្រើសរើសនាយកសាលាល្អ គ្រូបង្រៀនល្អ និងសាលាស្អាតនេះ គឺផ្អែកតាមគោលការណ៍លក្ខណវិនិច្ឆ័យ និងនីតិវិធីដែលបានកំណត់បន្ទាប់ពីមន្ទីរអប់រំ យុវជន និងកីឡារាជធានីខេត្ត បានផ្ញើលទ្ធផលវាយតម្លៃកម្រិតមន្ទីរមកក្រសួង។

សូមបញ្ជាក់ថា ការប្រគល់ពានរង្វាន់ជ័យលាភីសាលាស្អាតនេះ ត្រូវរៀបចំជារៀងរាល់ឆ្នាំ ដោយក្រសួងអប់រំ យុវជន និងកីឡា។ នៅចំពោះមុខយុវជនស្ម័គ្រចិត្តជិត ៤០០នាក់ ឯកឧត្តមរដ្ឋលេខាធិការក្រសួងបរិស្ថាន នេត្រ ភក្ត្រា បានជំរុញ ឱ្យយុវជនទាំងនោះខិតខំបំពេញការងារ និងសូមកុំធ្វើសកម្មភាពសម្អាតអនាម័យបរិស្ថាន ឬប្រតិបត្តិមេត្រីភាពបរិស្ថានតែមួយរយៈពេលខ្លី ប៉ុន្តែត្រូវប្រតិបត្តិតាមមេត្រីភាពបរិស្ថានជារៀងរាល់ថ្ងៃ គ្រប់ពេលវេលា គ្រប់ទីកន្លែង ដើម្បីបរិស្ថានស្អាត និងការពារភពផែនដីរបស់យើង។

ឯកឧត្តម នេត្រ ភក្ត្រា (២០២១) បានមានប្រសាសន៍លើកទឹកចិត្តដល់យុវជនស្ម័គ្រចិត្តទាំងអស់ត្រូវមានមោទនភាពចំពោះសកម្មភាពស្រឡាញ់ បរិស្ថាន និងខ្វល់ខ្វាយពីបរិស្ថានរបស់ខ្លួន និងសូមកុំរួញរា ឬបាក់ទឹកចិត្តនៅពេលបំណងប្រាថ្នារបស់ខ្លួនមិនទាន់បានសម្រេច ព្រោះការអប់រំ និងកែប្រែឥរិយាបថ

និងបណ្តុះស្មារតីមនុស្សឱ្យស្រឡាញ់បរិស្ថានគឺត្រូវការពេលវេលា និងទាមទារនូវភាពអំណត់ តស៊ូព្យាយាម និងអត់ធ្មត់ខ្ពស់បំផុត។

ក្រុមការងារប្រតិបត្តិនៃយុទ្ធនាការភ្នំពេញស្អាតឆ្នាំ២០២០ បានលើកឡើងថាដោយមានកិច្ចសហការជាមួយគ្រឹះស្ថានអប់រំរដ្ឋ និងឯកជន ក្នុងរាជធានីភ្នំពេញ បានធ្វើការអនុវត្តរៀបចំការប្រកួតប្រជែងពានរង្វាន់គម្រោងទស្សនាទាន «សាលាបរិស្ថានស្អាត» តាមប្រព័ន្ធអនឡាញ ដែលជាផ្នែកមួយដើម្បីជំរុញផែនការយុទ្ធសាស្រ្តរបស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការលើកកម្ពស់ការអប់រំអេនាម័យ និងបរិស្ថានស្អាតនៅតាមបណ្តាគ្រឹះស្ថានអប់រំ។ សាលារៀនរបស់ខ្ញុំគ្មានប្លាស្ទិក ត្រូវបានសាលារៀនអន្តរជាតិទ្រូវីហ្សិនកម្ពុជាដាក់ចេញផែនការអនុវត្តនប្រចាំថ្ងៃ។ ការបដិសេធការប្រើប្រាស់ប្លាស្ទិកដូចជា ថង់យួរដៃ ដបទឹកបរិសុទ្ធជាដើមនោះ បានជួយធ្វើឲ្យបរិស្ថានស្អាត គ្មានការបំពុលដោយសំរាមប្លាស្ទិក។ សំណល់បែបនេះត្រូវបានគេចាត់ទុកថា ជាការបំពុលដល់បរិស្ថាន ដោយសារតែវាត្រូវការពេលវេលាជាច្រើនរយឆ្នាំ ដើម្បីធ្វើការបំបែកជាតុ ឬរលួយនៅលើផែនដី។

អគ្គនាយកនៃសាលារៀនអន្តរជាតិទ្រូវិហ្សិនកម្ពុជា លោក សេង បូណា ដែលបានលើកឡើងថា «ការប្រើប្រាស់ផ្លាស្ទិក មានផលប៉ះពាល់ខ្លាំង ដល់បរិស្ថានរបស់យើង»។ លោកបានលើកឡើងថា កាលពីមុនប្លាស្ទិកមិនជាសម្បូរគ្រប់ទិសទីដូចបច្ចុប្បន្ននេះឡើយ។ ពលរដ្ឋយួរកន្ត្រកធ្វើពីឫស្សីទៅផ្សារ ដើម្បីទិញផ្លែឈើ និងបន្លែ ដែលអ្នកលក់ខ្ចប់ដោយស្លឹកឈូក ឬស្លឹកចេក ហើយការវេចខ្ចប់ចំណីអាហារ គឺប្រើប្រាស់ដោយចានស្រាក់ជាដើម។ បច្ចុប្បន្នសម្ភារៈ ដែលងាយរលាយក្នុងដីទាំងនេះស្ទើរតែជំនួសទាំងស្រុងដោយថង់ប្លាស្ទិក ទុយោជ័រ កញ្ចប់ចំណីអាហារ និងដបជ័រជាដើម។

នេះជាផែនការជំរុញឲ្យសាលារៀន ចូលរួមអនុវត្តវិធានកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក ក្នុងសាលារៀន និងសហគមន៍ឲ្យបានសកម្មជាយុទ្ធនាការនិយាយថា ទេចំពោះផលិតផលប្លាស្ទិក និងងាកមកប្រើប្រាស់ផលិតផល ដែលមិនប៉ះពាល់ដល់បរិស្ថានជំនួសវិញ។ លោកបន្តថា ដើម្បីផ្សព្វផ្សាយពីគោលគំនិតគ្មានប្លាស្ទិក នៅក្នុងសាលា យើងត្រូវចាត់វិធានការខ្លាំងក្លា ដើម្បីចាប់ផ្តើមជីវិតថ្មីប្រកបដោយសុខភាពល្អដោយការថែរក្សាបរិស្ថាន ទប់ស្កាត់ និងសន្សំការប្រើប្រាស់វត្ថុធាតុដើម លើកកម្ពស់ការយល់ដឹងដល់

សិស្សានុសិស្ស បុគ្គលិក លោកគ្រូ អ្នកគ្រូ មាតាបិតា និងសហគមន៍អំពីផលគ្រោះថ្នាក់ នៃការប្រើប្រាស់ប្លាស្ទិក។ បញ្ហាប្លាស្ទិកនឹងត្រូវបានដោះស្រាយ លុះត្រាតែមានការចូលរួមពីអ្នកទាំងអស់គ្នា។

**ខាងក្រោមនេះជាវិធី ដែលមនុស្សគ្រប់រូបអាចចូលរួមកាត់បន្ថយប្លាស្ទិកជារៀងរាល់ថ្ងៃ៖**

១. ប្រើប្រាស់ថង់បរិស្ថានតាមខ្លួន សម្រាប់ទិញទំនិញ ឬវេចខ្ចប់អាហារ

២. ការប្រើប្រាស់ដបទឹក/កែវខ្លួនឯង

៣. ប្រើប្រាស់បំពង់បឺត ឬប្រអប់ធ្វើពីក្រដាស ដែលអាចរលាយបានឆាប់

៤. វេចខ្ចប់អាហារ ដោយប្រើប្រាស់ប្រអប់ ឬចានស្រាក់ ឬសម្ភារៈមិនមែនប្លាស្ទិក

៥. ចៀសវាងទិញអាហារ ឬម្ហូបដែលវេចខ្ចប់ថង់ប្លាស្ទិកច្រើន

៦. ប្រាប់ទៅក្រុមហ៊ុន សហគ្រាស ភោជនីយដ្ឋាន និងមិត្តភក្តិ ឬក្រុមគ្រួសាររបស់អ្នកឱ្យដឹងថា អ្នកមិនចង់ប្រើប្រាស់ផលិតផលប្លាស្ទិក ដើម្បីសុខភាព និងនិរន្តរភាពបរិស្ថាន (ក្រសួងបរិស្ថាន ២០២០)។

### ២.៣.២ ការវង្វាយតម្លៃសាលារៀនស្អាត

ក្រសួងអប់រំ យុវជន និងកីឡា មានការយកចិត្តទុកដាក់យ៉ាងខ្លាំង ទៅលើការរៀបចំបរិស្ថានសិក្សា ដើម្បីឱ្យមានបរិយាកាសប្រកបដោយផាសុកភាពដែលឆ្លើយតបទៅនិងសុខភាពសិក្សា ឆ្លើយតបទៅនិងប្រកាសលេខ៧០៨ អយក.ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៨។

ក្នុងការវាយតម្លៃសាលាស្អាត ក្រសួងអប់រំ យុវជន និងកីឡា បានបង្កើតសូចនាករគោលចំនួន១០គឺ

១. អត្តសញ្ញាណជាតិ និងវិន័យ

២. ការបញ្ច្រាបការយល់ដឹងពីបរិស្ថាន និងភាពស្អាត

៣. ភាពស្អាតនៅក្នុងបរិវេណសាលា បន្ទប់រៀន បង្គន់ អនាម័យ និងភាពបៃតង

៤. ទីតាំងលេងកម្សាន្ត ចំណតយានជំនិះ និងទីតាំងដាក់ធុងសំរាម

៥. ការគ្រប់គ្រងសំណល់ (ការវេចខ្ចប់ និងប្រមូលសំរាម)

៦. អនាម័យចំណីអាហារ

៧. ការប្រើប្រាស់ទឹកស្អាត ការបំពុលដោយសារក្លិន និងការបំពុលដោយផ្សែង

៨. សុខុមាលភាពគ្រូសិស្សនិងបុគ្គលិកអប់រំផ្សេងទៀត

៩. អត្តសញ្ញាណមន្រ្តីរាជការ

១០. ការចាត់តាំងអនុវត្តការងារគ្រប់គ្រងអនាម័យ បរិស្ថាន និងមានលក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃផ្សេងៗ ដើម្បីដឹងពីសាលារៀននីមួយៗទទួលបានបរិស្ថានស្អាត ដែលជាជំនួយដល់ការបង្រៀន និងរៀនឱ្យកាន់តែមានភាពប្រសើរ(មានភ្ជាប់ទៅឧបសម្ព័ន្ធ)។

ជាលទ្ធផលសាលារៀនមួយចំនួនបានទទួលជ័យលាភីសាលាស្អាតប្រចាំឆ្នាំ ដែលមានរៀបរាប់នៅក្នុងចំណោទបញ្ហា។ លក្ខខណ្ឌវិនិច្ឆ័យទាំង៤ ចំណុចនៃសាលាមេត្រីបរិស្ថានរួមមាន៖

ទី១) មានគោលការណ៍និងរដ្ឋបាល របស់សាលាលើការងារបរិស្ថាន

ទី២) មានការបង្រៀនមេរៀនបរិស្ថាននិងសកម្មភាពអប់រំបរិស្ថានក្នុងសាលា និងសហគមន៍ជុំវិញ (ជាកម្មវិធីសិក្សាបន្ថែម ឬបញ្ជ្រាប)

ទី៣) មានសម្ភារៈបរិក្ខារអប់រំផ្នែកបរិស្ថាន ហេដ្ឋារចនាសម្ព័ន្ធនានានិងការប្រតិបត្តិបរិស្ថាន

ទី៤)មានភាពជាដៃគូជាមួយអ្នកពាក់ព័ន្ធនិងការផ្សព្វផ្សាយតាមសហគមន៍ (ក្រសួងអប់រំ យុវជន និងកីឡា ២០១៨)។

## ២.៤ បរិស្ថានសិក្សា

យោងតាមក្រសួងអប់រំយុវជន និងកីឡា & អង្គការអប់រំពិភពលោក (២០១៣) បានអោយនិយមន័យបរិស្ថានថាជាអ្វីៗដែលនៅជុំវិញខ្លួនរបស់យើង។ ដែលធាតុសំខាន់ៗបរិស្ថានបែងចែកជា ២ សំខាន់ៗ គឺបរិស្ថានធម្មជាតិ និងបរិស្ថានសង្គម។ បរិស្ថានធម្មជាតិ សំដៅទៅរកវត្ថុគ្រប់យ៉ាងនៅជុំវិញខ្លួនរបស់យើងដែលរួមបញ្ចូលទាំងអ្វីៗដែលមានជីវិតរួមមាន ទឹក ដី ខ្យល់ សត្វ រុក្ខជាតិ។ បរិស្ថានសង្គមសំដៅទៅរកវត្ថុ ដែលជាលទ្ធផលនៃសកម្មភាពរបស់មនុស្ស ដែលរួមបញ្ចូលទាំងផលិតផលរបស់សង្គមដូចជាសកម្មភាពសេដ្ឋកិច្ច ទំនៀមទំលាប់ ច្បាប់ ទង្វើរបស់បុគ្គលជាដើម។

ចំពោះបរិស្ថានសាលារៀនសំដៅដល់ សាលាមាន របង ទ្វារ និងបង្គួចគត់មត់ ទីធ្លាសាលា សួនច្បារ ដងទង់ជាតិ សួនជីវចម្រុះ ទីលានកីឡា សួនកុមារ មណ្ឌលវប្បធម៌ប្រពៃណី ធុងសំរាម និងត្រូវដុតសំរាម

មានកន្លែងចតយានជំនិះគ្រប់ប្រភេទ (សណ្តាប់ធ្នាប់) ផ្លូវដើរពីអគារមួយទៅអគារមួយទៀត ដើមឈើជាម្លប់ កន្លែងលក់ចំណីអាហារត្រូវមានអនាម័យ និងសុវត្ថិភាព (ស្តង់ដាសាលាបឋមសិក្សា ២០១៧)។

បរិស្ថានសិក្សាចែកចេញជាពីរ ប្រភេទគឺ បរិស្ថានសិក្សាអំណោយផល និងបរិស្ថានសិក្សារាំង។ បរិស្ថានសិក្សាអំណោយផល សំដៅទៅលើលក្ខខណ្ឌនិងការអនុវត្តដែលលើកកម្ពស់គុណភាពរវាងការសិក្សា និងការអភិវឌ្ឍន៍ ពោលគឺបរិយាកាសដែលបុគ្គលម្នាក់ៗអាចផ្លាស់ប្តូររបៀបសិក្សាបាន។ ផ្ទុយទៅវិញ បរិស្ថានសិក្សាដែលមានការរឹតត្បិតសំដៅលើលក្ខខណ្ឌ និងការអនុវត្តដែលទំនងជារាំងទាំងការសិក្សា និងការអភិវឌ្ឍន៍ ឬជំរុញការរៀនសូត្រ (Ellström et al, 2008)។

ហេតុនេះបរិស្ថានសិក្សា សំដៅដល់អ្វីៗទាំងអស់ដែលស្ថិតនៅក្នុងបរិវេណ និងជុំវិញគ្រឹះស្ថានសិក្សា ដូចជា អាគារសិក្សា បន្ទប់រៀន កន្លែងលក់ដូរ ឬរៀបចំចំណីអាហារ របង សម្ភារៈរូបវន្តផ្នែកអនាម័យ សម្ភារៈសិក្សា សួនច្បារ សួនបន្លែ រុក្ខជាតិជាដើម (ក្រសួងអប់រំ យុវជន និងកីឡា ២០១៩)។

### ២.៤.១ បរិស្ថានសិក្សា និងសុខភាពអនាម័យក្នុងសាលារៀន

តាមឯកសាររបស់ក្រសួងអប់រំ យុវជន និងកីឡា បានចេញផ្សាយនៅអំឡុងឆ្នាំ ២០១៧ ដែលស្តីពីបណ្ណព័ត៌មាន សាលារៀនបានលើកឡើងពីបរិស្ថាន ជាបញ្ហាចម្បងនៅក្នុងសាលារៀន។ កាលណាសាលាមានបរិស្ថានល្អ អនាម័យស្អាតនាំឱ្យសិស្សមានចំណង់ចំណូលចិត្តចង់រៀន ធានាបាននូវសុខសុវត្ថិភាពដល់សិស្ស។ សាលារៀនគ្មានគ្រោះថ្នាក់ គ្មានអំពើហឹង្សា គ្មានការគំរាមកំហែងមានវិធានការណ៍ទប់ស្កាត់បាតុភាពមិនប្រក្រតី។

ម៉្យាងទៀតបរិស្ថានសាលាត្រូវមាន របងសាលា ខ្លោងទ្វារ ដងទង់ជាតិ កញ្ចុះ ទីធ្លាលេងកំសាន្តដើមឈើជ្រកម្លប់ សួនច្បារ ទីធ្លាអង្គុយលេង ធុងសំរាម កន្លែងលក់នំចំណី អនាម័យ និងគុណភាពអាហារឃ្លាំង និងសម្ភារៈផ្ទះបាយ ប្រអប់សង្គ្រោះបឋម និងថ្នាំព្យាបាលសិស្សជាដើម (ក្រសួងអប់រំ យុវជន និងកីឡា ២០១៧)។ លើសពីនេះទៀតសាលាត្រូវមានបង្គន់អនាម័យ និងកន្លែងលាងសម្អាតដែមានទឹកនិងសាប៊ូលាងដៃ ប្រាស អំបោស ប្រដាប់ដងទឹក កម្មវិធីដុសសម្អាតធ្មេញ ការលាងសម្អាតបរិក្ខារនិងការលាងដៃជាប្រចាំ និងស្តង់ដាជាតិបានបែងចែកបង្គន់អនាម័យជា៣ផ្នែកគឺ បង្គន់ប្រុស បង្គន់ស្រី និងបង្គន់កុមារពិការ។

ក្នុងនោះផងដែរគោលដៅនៃការគ្រប់គ្រងសាលារៀនត្រូវមានស្វ័យភាព គណនេយ្យភាព ការវាយតម្លៃ (ការធ្វើតេស្ត និងប្រឡង) សុវត្ថិភាពសិស្ស បរិស្ថានក្នុងថ្នាក់ និងសាលារៀន បច្ចេកទេសវិធីសាស្ត្របង្រៀន សុខភាពអនាម័យសិស្សានុសិស្ស ការងារជួសជុលសាងសង់ ការចូលរួមរបស់មាតាបិតាសិស្ស និងសហគមន៍ក្នុងគណៈកម្មការគ្រប់គ្រងសាលា (បឋមសិក្សាបន្ទាយឈើ ២០១៨)។

**២.៤.២ សារៈសំខាន់នៃបរិស្ថានសិក្សា**

បរិស្ថានសាលារៀនស្អាតមានសារៈសំខាន់ និងមានឥទ្ធិពលដោយផ្ទាល់លើសុខភាពសិស្ស គ្រូ និងបុគ្គលិកទាំងអស់ (ក្រសួងអប់រំ យុវជន និងកីឡា ២០១៨)។ អនាម័យសាលារៀនគឺជាកត្តាមួយដ៏សំខាន់ក្នុងការធ្វើឱ្យសុខុមាលភាពរបស់គ្រូ សិស្សមានភាពប្រសើរ។ សាលារៀនមានភាព ស្រស់ស្អាតដែលប្រកបដោយអនាម័យជាការងារមួយតម្រូវឱ្យមានការចូលរួមពី គ្រូ សិស្សានុសិស្សគ្រប់គ្នា ក្នុងការរៀបចំត្រួតពិនិត្យ ថែរក្សាការពារទាំងអស់។

**(១) ការសម្អាតបន្ទប់រៀន៖** បន្ទប់រៀនស្អាត បរិយាកាសល្អនឹងជួយដល់ដំណើរការរៀនសូត្រសិស្ស យើងឱ្យបានល្អដែរ ដូច្នេះហើយយើងទាំងអស់គ្នាត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវវិធានការអនាម័យដូចជាត្រូវបើកទ្វារ បង្អួច បន្ទប់រៀន ដើម្បីឱ្យខ្យល់និងពន្លឺចេញចូលបានគ្រប់គ្រាន់ និងត្រូវបិទទ្វារ បង្អួច ឱ្យបានត្រឹមត្រូវក្រោយពេលចប់ម៉ោងសិក្សា

- ត្រូវបោស និងជូតបន្ទប់រៀន ទ្វារ បង្អួច ពិដាន តុ កៅអីឱ្យបានស្អាតរាល់ថ្ងៃ សំរាមត្រូវទុកដាក់ក្នុងធុងសំរាមឱ្យបានត្រឹមត្រូវ ចំពោះសម្ភារៈសំរាមត្រូវទុកដាក់ឱ្យមានសណ្តាប់ធ្នាប់ និងមានអនាម័យ
- សម្ភារៈសិក្សា ផ្ទាំងរូបភាព និងសម្ភារៈសិប្បកម្មត្រូវបានរៀបចំទុកដាក់ឱ្យមានសណ្តាប់ធ្នាប់ មិនត្រូវឡើងជាន់លើតុ គូសវាសលើជញ្ជាំង ខាកស្តោះក្នុងបន្ទប់រៀន
- ត្រូវត្រួតពិនិត្យសព្វបន្ទប់រៀន ក្រែងមានកណ្តៀរស៊ីគ្រឿងឈើ កណ្តុរកកេរតុ និងទូរ
- ជាពិសេសត្រូវត្រួតពិនិត្យដំបូលជាប្រចាំ ក្រែងលោមានការឆ្លុះធ្លាយ
- រៀបចំបិទផ្ទាំងរូបភាព និងផ្ទាំងគំនូរ ដែលឆ្លុះបញ្ចាំងប្រពៃណីខ្មែរនៅតាមបន្ទប់រៀន

– ត្រូវរៀបចំភ្លើងសម្រាប់បំភ្លឺនៅតាមបន្ទប់រៀននីមួយ ករណីមានភាពងងឹតដោយសារមានភ្លៀង ឬ អាកាសធាតុងងឹត ដោយកាត់បន្ថយការប្រើប្រាស់ថាមពលច្រើនហួសហេតុ និងព្យាយាមប្រើប្រាស់ថាមពលកកើតឡើងវិញជំនួស។

**(២) ការសម្អាតបរិវេណសាលារៀន**

សាលារៀនមានសារៈសំខាន់បំផុត សម្រាប់យើងទាំងអស់គ្នាជាពិសេសក្នុងពេលសិក្សា ពេលលេងល្បែងកម្សាន្ត ការហាត់កីឡា និងការជួបជុំមិត្តភក្តិរួម ដូចនេះយើងត្រូវះ កាប់ឆ្ការព្រៃស៊ុបទ្រុប លុបបំបាត់ថ្លុក និងទីកន្លែងដែលអាចដក់ទឹកបាននៅជុំវិញ បរិវេណសាលាដើម្បីកុំឱ្យមូសពងបាន។ កន្លែងលក់ចំណីអាហារត្រូវមានអនាម័យត្រឹមត្រូវ មានគម្របសម្រាប់គ្របឬដាក់ក្នុងទូសំណាញ់ឬកញ្ចក់បិទជិត។ អាហារត្រូវដាក់លើរានខ្ពស់ផុតពីដី និងឆ្ងាយពី ប្រភពចម្លងមេរោគ។ ចំពោះការរៀបចំសួនច្បារ រៀបខឿនឲ្យបានត្រឹមត្រូវ និងដាំដើមឈើទៅតាមទីតាំងដាក់ស្តែង ហើយចែកវេនស្រោចទឹក និងថែរក្សាជាប្រចាំ។ ការរៀបចំសួនជីវៈចម្រុះ និងដាំបន្លែគ្រប់ប្រភេទ មានប្រព័ន្ធស្រោចស្រព និងមានការថែទាំល្អ ធុងសំរាម ឬកន្លែងចាក់សំរាមត្រូវរៀបចំឱ្យបានសមស្រប មិនត្រូវដាក់ក្បែរបន្ទប់រៀននាំឱ្យមានក្លិនរំខានដល់ការសិក្សា។ ត្រូវបង្កើតឲ្យមានឡដុតសំរាមនៅតាមសាលារៀនឬទំនាក់ទំនងភ្នាក់ដឹកសំរាមចេញ ពីសាលាដើម្បីការកកស្ទះសំរាមក្នុងសាលា ជៀសវាងការសាយភាយក្លិនស្អុយសំខាន ហាមសត្វពាហនៈចេញ និងចូលក្នុងបរិវេណសាលារៀន។

**២.៤.៣ អនាម័យបរិស្ថានសិក្សា**

ចាប់តាំងពីឆ្នាំ២០០៦ មកក្រសួងអប់រំ យុវជន និងកីឡា បានពង្រឹងការយល់ដឹងពីបញ្ហាសុខភាពអ្នកសិក្សា និងបុគ្គលិកអប់រំ ជាពិសេសកៀរគរឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធក្នុងការលើកកម្ពស់ និងទទួលបានសេវាអប់រំសុខភាពប្រកបដោយសមធម៌ផងដែរ។

ទោះបីជាមានកិច្ចប្រឹងប្រែងក្នុងការលើកកម្ពស់សុខភាពសិក្សាដូចបានរៀបរាប់ខាងលើក្តី ក៏ការអនុវត្តការងារសុខភាពសិក្សាមិនទាន់មានជ្រុងជ្រោយពេញលេញ និងជាពិសេសមិនទាន់ទទួលបានការចូលរួមយ៉ាងផុសផុលពីស្ថាប័នពាក់ព័ន្ធនៅឡើយទេ។

អាស្រ័យហេតុនេះរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានរៀបចំគោលនយោបាយជាតិស្តីពីសុខភាពសិក្សា ដើម្បីធ្វើឱ្យមានសង្គតិភាព និងអាចអនុវត្តបានចំពោះគ្រប់ភាគីពាក់ព័ន្ធ ក្នុងការចូលរួមលើកកម្ពស់សុខភាពនៅតាមគ្រឹះស្ថានសិក្សាទាំងអស់នៅព្រះរាជាណាចក្រកម្ពុជា ក្នុងបរិបទនៃការអប់រំនាសតវត្សទី២១(ក្រសួងអប់រំ យុវជន និងកីឡា ២០១៩)។ លើសពីនេះទៅទៀត សុខភាពសិក្សាគឺមានភាពពាក់ព័ន្ធជាមួយបរិស្ថានសិក្សារបស់សាលារៀន។

យោង Fakeye (2012) បរិស្ថានសិក្សា មានសារៈសំខាន់បំផុតសម្រាប់យើងទាំងអស់គ្នាជាពិសេសក្នុងពេលសិក្សា ពេលកំសាន្ត ការហាត់កីឡា និងជួបជុំមិត្តភក្តិរួមការងាររួមមាន៖

- ✓ កាប់ឆ្ការព្រៃស៊ុបទ្រុប លុបបំបាត់ថ្លុកជ្រាំ និងកន្លែងដែលអាចមានដក់ទឹកបាននៅជុំវិញបរិវេណសាលាដើម្បីកុំឱ្យមូសពងបាន។
- ✓ កន្លែងលក់ចំណីអាហារត្រូវមានអនាម័យត្រឹមត្រូវ អាហារត្រូវមានគម្របសម្រាប់គ្រប ឬដាក់ក្នុងទូសំណាញ់បិទជិត
- ✓ រៀបចំសួន និងដាំដើមឈើទៅតាមទីតាំងជាក់ស្តែង ចែករវេនស្រោចទឹក ថែរក្សាជាប្រចាំ
- ✓ ធុងសំរាម ឬកន្លែងចាក់សំរាមត្រូវរៀបចំឱ្យបានសមស្រប និងមិនត្រូវដាក់ក្បែរបន្ទប់រៀនធ្វើឱ្យមានក្លិនរំខានដល់ការសិក្សា។
- ✓ ហាមសត្វពាហនៈចេញ និងចូលបរិវេនសាលា។

### ២.៤.៤ លទ្ធផលពីការយល់ដឹងពីបរិស្ថានសិក្សា

យោងតាមគម្រោង សាលាស្អាត របស់ខ្មែរប៊ែវើរីជីស (Khmer Beverages, 2022) បានលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធស្អាតនៅខេត្តមួយចំនួន ភ្នំពេញ បាត់ដំបង សៀមរាប បន្ទាយមានជ័យ។ ដោយយល់ឃើញថាវិស័យអប់រំដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍប្រទេសកម្ពុជា Khmer Beverages បានបង្កើតគម្រោងសាលាស្អាតនៅឆ្នាំ២០១៦។ ដើម្បីអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅតាមសាលារៀនតាមរយៈការសាងសង់ផ្លូវបេតុង ការក្រាលការ៉ូឡា របង ក្លោងទ្វា ដងទង់ជាតិ ទីលានកីឡាបាល់ទាត់ និងបាល់ទះជាដើមឱ្យសាលាជាច្រើន។

នៅឆ្នាំ២០២២ Khmer Beverages បានលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធនៅតាមសាលារៀនដោយចំណាយថវិកាប្រមាណ ២០ ទៅ ៣០ម៉ឺនដូនទៅកាន់សាលាចំនួន៣៧។ ដោយហេតុហេដ្ឋារចនាសម្ព័ន្ធស្អាត និងបម្រើផលប្រយោជន៍ដល់សិស្សឱ្យកាន់តែងាយស្រួល ផាសុកភាព អំឡុងពេលរៀន។ ក្រោមហេតុផលតែមួយគឺ សាលាជាថ្នាល់បណ្ដុះបណ្ដាលធនធានជំនាន់ក្រោយ សម្រាប់ទ្រទ្រង់សង្គមជាតិយើងពេលអនាគត។

យោងតាមការលើកឡើងរបស់សិស្សនៅសាលាអនុវិទ្យាល័យទឹកថ្លា ក្នុងខេត្តបន្ទាយមានជ័យ និងសិស្សនៅអនុវិទ្យាល័យអូរស្នួត ខេត្តបន្ទាយមានជ័យ បាននិយាយថាសប្បាយចិត្ត ចង់មករៀន សាលាស្អាត ងាយស្រួលពេលប្រលង និងបរិស្ថានសាលារៀនកាន់តែប្រសើរ។ ចំណែកឯតាមរយៈលោកគ្រូ អ្នកគ្រូ នៅអនុវិទ្យាល័យវត្តគរ ខេត្តបាត់ដំបង បានមានប្រសាសន៍ថាពិតជាសប្បាយចិត្តជាខ្លាំង រំភើបដែលទទួលបាន អំណោយ(ក្លោងទ្វា និងការក្រាលការូឡា ៤៨០ម៉ែត្រការេ)ដែលបានរួមចំណែកលើកកម្ពស់សោភ័ណភាពសាលាយ៉ាងស្រស់ជ្រកាល ដែលសាលារៀនស្អាតសិស្សមានចិត្តចង់រៀន។

ម្យ៉ាងវិញទៀតនាយកសាលាអនុវិទ្យាល័យព្រៃជ្រូក ខេត្តសៀមរាបបានលើកឡើងថាគម្រោងសាលាស្អាត ជាគម្រោងមួយដែលល្អ សូម្បីតែឈ្មោះក៏ល្អដែលស្របតាមផែនការយុទ្ធសាស្ត្រក្រសួងអប់រំផ្ដែកលើការលើកកម្ពស់គុណភាពសោភ័ណភាព។ លើសពីនេះទៀត នៅក្នុងវិស័យអប់រំ មានការប្រឡងសាលាស្អាត និង សាលាកុមារមេត្រី។ បន្ថែមពីនេះទៀត អាណាព្យាបាលសិស្សបានលើកឡើងថា កាលមុនផ្លូវភក់ ពិបាកចេញចូលតែបន្ទាប់ពីគម្រោងសាលាស្អាត ជំរុញការសិក្សារបស់សិស្សចាប់មេរៀនបានល្អក្មេងដើរចេញចូលស្រួល។

ដោយឡែកយោងតាមការលើកឡើង របស់នាយកសាលារៀនសុវណ្ណភូមិសាខាខេត្តកំពង់ឆ្នាំងបានបង្ហាញពីទិវាសាលារៀនស្អាត 5s Day ដែលសាលារៀនស្អាតសិស្សមាន សុខភាពល្អ សាលាស្រលាញ់បរិស្ថាន។ ដែលធ្វើឡើងនៅថ្ងៃទី០៥ រៀងរាល់ខែ ដើម្បីប្រារព្ធកម្មវិធី ដែលមានរយៈពេល៧ឆ្នាំ(២០២៣)។ គោលបំណងចង់បានសាលាបៃតងមានស្រលាញ់ចូលរួមថែរក្សាបរិស្ថានសាលាគ្មានប្លាស្ទិកសាលាប្រកបដោយផាសុកភាព ភាពស្រស់ស្រាយ សំអាតថ្នាក់ និងបរិស្ថានជុំវិញ។ ដូច្នេះបរិស្ថានសាលា

រៀនចាំបាច់ណាស់សម្រាប់សិស្សានុសិស្សក្នុងការសិក្សា សម្រាប់សុខភាពប្រចាំថ្ងៃ និងជំរុញឱ្យសិស្សស្រលាញ់ចូលរួមថែរក្សាបរិស្ថាន។

លើសពីនេះទៀត យោងតាមការលើកឡើងរបស់នាយកសាលាវិទ្យាល័យស្វាយរៀងដែលជាសាលាទទួលបានជ័យលាភីលេខ១បានមានប្រសាសន៍ថា ដើម្បីទទួលបានសាលាស្អាត ត្រូវឆ្លើយតបទៅកាន់សូចនាកររបស់ក្រសួង គឺត្រូវកំណត់ទិសដៅ ជំរុញ មានការទទួលខុសត្រូវសម្រេចគោលដៅដែលមានចំនួន១៣០សូចនាករដោយផ្អែកលើបរិស្ថានស្អាតគ្មានសំរាម សិស្សសហការណ៍ តែងតែមានការប្រជុំណែនាំរៀងរាល់ថ្ងៃសៅរ៍ពីការស្រលាញ់បរិស្ថាន ដែលទទួលលទ្ធផលល្អ សាលាស្អាត ចូលចិត្តមករៀនលែងបោះបង់ និងដើរក្រៅ។ បន្ទាប់មកក្នុងសាលាក៏មានគម្រោងបន្តទៀតដើម្បី ជំរុញបុគ្គលិក សិស្សអាណាព្យាបាល និងជំរុញបន្ថែមឱ្យសាលាមានបរិស្ថានស្អាត ដើម្បីទទួលបានជ័យលាភីសាលាស្អាត ពីក្រសួងបរិស្ថាជាកិត្តិយសដល់ខេត្ត និងទទួលបានសាលាមេត្រីបរិស្ថានដែលមានវិន័យ សណ្តាប់ធ្នាប់បរិស្ថាន គុណភាពការរៀនរបស់សិស្ស។

### ២.៤.៥ បញ្ហាប្រឈមក្នុងការរៀបចំបរិស្ថានសិក្សា

«បរិស្ថានជាបញ្ហារួមរបស់យើងទាំងអស់គ្នា ហើយទាមទារចាំបាច់នូវការបានចូលរួមរបស់យើងទាំងអស់គ្នាក្នុងការថែរក្សាអនាម័យបរិស្ថានជុំវិញខ្លួនយើងឱ្យបានល្អស្អាត បង្កើតបរិយាកាសល្អ និងមានផាសុកភាព សម្រាប់ការរស់នៅរស់យើង។ សង្គមកម្ពុជាមានបរិស្ថានស្អាត និងមានភពបៃតង គឺកើតចេញពីពលរដ្ឋកម្ពុជាម្នាក់ៗចូលរួមក្នុងសកម្មភាពបរិស្ថានមានមេត្រីភាពបរិស្ថាន ប្រកបដោយការទទួលខុសត្រូវ និងដោយស្មារតីស្រឡាញ់បរិស្ថានខ្ពស់»។

### (១) ការចូលរួមរបស់អ្នកពាក់ព័ន្ធនៅមានកម្រិត

ការគូសបញ្ជាក់របស់ក្រសួងបរិស្ថាននៅព្រឹកថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៩ នេះក្រោមប្រធានបទ «ដំណោះស្រាយបញ្ហាបរិស្ថានក្នុងនាមអ្នកជាយុវជន» រៀបចំឡើងដោយគម្រោងរបស់កម្ពុជាដោយមានការចូលរួមពីយុវជនជិត៤០០ នាក់នៅសាលប្រជុំនៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាក្នុងរាជធានីភ្នំពេញ។ ដោយហេតុថាក្រសួងបរិស្ថានបាន និងកំពុងយកចិត្តទុកដាក់ខ្ពស់លើការអភិវឌ្ឍមនុស្សជាពិសេសយុវជន

និងកុមារ តាមរយៈការអប់រំផ្សព្វផ្សាយ ការចែករំលែកចំណេះដឹង បទពិសោធន៍ និងរបកគំហើញថ្មីៗ ជាពិសេសបច្ចេកវិទ្យាប្រកបដោយនវានុវត្តន៍ក្នុងវិស័យបរិស្ថាន ដែលជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការលើកកម្ពស់ការយល់ដឹង សំដៅប្រែក្លាយចំណេះដឹងទៅជាការប្រតិបត្តិបរិស្ថានល្អ ដូចដែលបានគូសបង្ហាញនៅក្នុងគោលបំណងជាយុទ្ធសាស្ត្រទី៤ នៃយុទ្ធសាស្ត្រនិងផែនការសកម្មភាពបរិស្ថានជាតិ ២០១៦ – ២០២៣ ដែលជាផែនទីបង្ហាញផ្លូវសម្រាប់ជួយដល់ក្រសួង ស្ថាប័ន គ្រឹះស្ថានអប់រំ វិស័យឯកជន អង្គការមិនមែនរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍និងអ្នកពាក់ព័ន្ធទាំងអស់ក្នុងការធ្វើសមាហរណកម្មបញ្ហាបរិស្ថានទៅក្នុងគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព និងផែនការវិនិយោគទៅតាមសមត្ថកិច្ចរៀងៗខ្លួនដើម្បីធ្វើទំនើបកម្មការគ្រប់គ្រង និងអភិបាលកិច្ចក្នុងវិស័យបរិស្ថាន និងធនធានធម្មជាតិ។

គោលបំណងដ៏សំខាន់របស់ក្រសួងបរិស្ថានគឺការក្តាប់មកវិញនូវមោទនភាពជាតិ និងការកសាងជាតិទំនើបមួយដ៏រស់រវើក ក្នុងសេចក្តីប៉ងប្រាថ្នា ប្រែក្លាយកម្ពុជា ជាប្រទេសមានចំណូលខ្ពស់ រឹងមាំ ពលរដ្ឋមានសមត្ថភាព និងបរិស្ថានរស់នៅល្អប្រសើរ កិច្ចគាំពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ ការប្រើប្រាស់ធនធានធម្មជាតិឱ្យបានសមស្របនិងមាននិរន្តរភាពនិងការរស់នៅដោយចីរភាពសម្រាប់ជាឧត្តមប្រយោជន៍យូរអង្វែងរបស់ប្រជាជនកម្ពុជាគ្រប់រូបនិងគ្រប់ជំនាន់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ដោយហេតុនៅកម្ពុជាកំណើនប្រជាជន និងការរីកចម្រើនសេដ្ឋកិច្ចយ៉ាងឆាប់រហ័ស កំពុងបង្កឱ្យមានការបំពុលបរិស្ថាន។ សកម្មភាពអភិវឌ្ឍន៍សេដ្ឋកិច្ច បានបង្កើតជាផលវិបាកផ្នែកបរិស្ថានសំខាន់ៗ រួមទាំងការបំពុល ខ្យល់ ការបំពុលទឹក ការបំពុលសំលេង និងបញ្ហាសំណល់រឹង។

**(២) បញ្ហាសម្រាម និងកំណើនប្លាស្ទិក**

នៅក្នុងប្រទេសកម្ពុជាក៏ដូចជាប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀត បញ្ហាបរិស្ថានចម្បងមួយទៀតនោះគឺការចោល និងការគ្រប់គ្រងសំណល់រឹង។ ការបញ្ចេញសំណល់ មានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងកំណើនប្រជាជន ដែលវានាំឱ្យមានការព្រួយបារម្ភពីបញ្ហាបរិស្ថាន និងសុខភាពមនុស្ស។

ជាការពិតណាស់តាមសាលារៀននីមួយៗតែងតែជួបនៅបញ្ហាប្រឈម ដោយសារកង្វះខាត នៃការអនុវត្តការគ្រប់គ្រងនូវសំណល់ឱ្យបានត្រឹមត្រូវ និងការយល់ដឹងជាសាធារណៈនៅមានកម្រិត ដែលបញ្ហា

សំណល់រឹងនៅតែជាសម្ពាធបរិស្ថានមួយដ៏ធំ (Royal Kingdom of Cambodia, 2012)។ បន្ថែមពីនេះទៀត ដោយស្ថានភាពជាក់ស្តែងនៅតាមសាលារៀននីមួយតែងតែជួបបញ្ហាសំរាម ដែលជាបញ្ហាពិបាកក្នុងការដោះស្រាយ និងគ្រប់គ្រង។

ជារួមបញ្ហាប្រឈមចម្បងៗក្នុងការរៀបចំបរិស្ថានសិក្សា គឺបណ្តាលមកពី បញ្ហាសំរាម និងកំណើនប្លាស្ទិក កត្តាសកម្មភាពសិស្សមួយចំនួន និងកន្លែងលក់ដូរជាដើម។

## ២.៥ ការកាត់បន្ថយផលប៉ះពាល់បរិស្ថានសិក្សា

ការកាត់បន្ថយផលប៉ះពាល់បរិស្ថានសិក្សា ដើម្បីធ្វើឱ្យសាលារៀនគ្រប់ទិសទី មានបរិស្ថានសិក្សាដែលមានសោភ័ណភាពស្រស់បំព្រងជានិរន្ត ធ្វើឱ្យសាលារៀនបច្ចុប្បន្នក្លាយជាសាលាបៃតង ជាកន្លែងផ្តល់នូវភាពស្រស់ថ្លា ទាក់ទាញបុគ្គលិក សិស្សានុសិស្ស ឱ្យស្រលាញ់សាលារៀន ស្រលាញ់បរិស្ថាន និងធម្មជាតិ ចូលរួមថែរក្សា ការពារ និងបណ្តុះបណ្តុះគំនិតលោកគ្រូ អ្នកគ្រូរួមទាំងសិស្សានុសិស្សឱ្យមានគំនិតច្នៃប្រឌិត និងគំនិតបង្កើតថ្មី។

### ២.៥.១ ផលប៉ះពាល់ពីការប្រើប្រាស់ប្លាស្ទិក

១.ការបំពុលដោយប្លាស្ទិក បង្កផលប៉ះពាល់អវិជ្ជមានដល់បរិស្ថានរបស់យើង៖ បង្កឲ្យមាននូវទឹកជំនន់ដែលផ្តល់ផលវិបាក និងការខូចខាតធ្ងន់ធ្ងរ និងការបំពុលនូវបរិស្ថានសមុទ្រដោយសារប្លាស្ទិកបង្កផលប៉ះពាល់ដល់ប្រព័ន្ធអេកូឡូស៊ី សមុទ្រ ទន្លេ បឹងបួរ ជីវចម្រុះ និងមនុស្ស។

២.ការបំពុលដោយសារប្លាស្ទិក បង្កផលប៉ះពាល់ជាអវិជ្ជមានដល់សុខភាពរបស់យើង៖ ប្លាស្ទិកចូលទៅក្នុងខ្លួនរបស់មនុស្ស តាមរយៈត្រីដែលយើងបរិភោគ ផ្សែងពុលពីការដុតប្លាស្ទិក អាចបង្កបញ្ហាផ្លូវដង្ហើម រួមនឹងជំងឺមហារីកផង។

៣.ការចំណាយថវិកាខ្ពស់ សម្រាប់សម្អាតការបំពុលដែលបង្កឡើងដោយប្លាស្ទិក

### ២.៥.២ វិធានការកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក

មានវិធីសាស្ត្រ៤ យ៉ាងដោយឈរលើដំណោះស្រាយដែលល្អបំផុតដើម្បីកាត់បន្ថយការប្រើប្រាស់ប្លាស្ទិក និងការផលិតសំណល់ គឺត្រូវប្រើប្រាស់យុទ្ធសាស្ត្រ 4R+១៖

១.បដិសេធមិនប្រើប្រាស់ (Refuse)៖ រាល់ប្លាស្ទិកដែលប្រើបានតែម្តងទាំងអស់ ដូចជា បំពង់បឺត កែវ ថង់ ដប ប្រអប់ស្នោដាក់អាហារ ដែលផលិតពីប្លាស្ទិក។

២.កាត់បន្ថយ (Reduce)៖ ការសម្រេចចិត្តទិញទំនិញដែលមិនប៉ះពាល់ដល់បរិស្ថាន មុនពេលទិញផលិតផលពីប្លាស្ទិក។

៣.ប្រើប្រាស់ឡើងវិញ (Reuse)៖ ប្រើប្រាស់ប្លាស្ទិកចាស់ ជាជាងទិញប្លាស្ទិកថ្មី

៤.កែច្នៃ (Recycle)៖ ព្យាយាមកែច្នៃ និងចោលប្លាស្ទិកប្រកបដោយការទទួលខុសត្រូវ

៥.ក្រើនរំឭក (Remind)៖ រំឭកដាស់តឿនអ្នកជុំវិញខ្លួន អំពីភាពចាំបាច់ក្នុងការអនុវត្តតាមយុទ្ធសាស្ត្រ 4R និងការធ្វើសកម្មភាពដើម្បីកាត់បន្ថយប្លាស្ទិក។

ការចូលរួមទាំងអស់គ្នាដើម្បីកាត់បន្ថយប្លាស្ទិក៖ បញ្ហាប្លាស្ទិកនឹងត្រូវបានដោះស្រាយ លុះត្រាតែមានការចូលរួមពីអ្នកទាំងអស់គ្នា។ ខាងក្រោមនេះជាវិធី៧ យ៉ាង ដែលអ្នកអាចចូលរួមកាត់បន្ថយប្លាស្ទិកជារៀងរាល់ថ្ងៃ៖

១. យកថង់ដែលអាចប្រើប្រាស់ឡើងវិញ ឬថង់បរិស្ថានតាមខ្លួនសម្រាប់ទិញទំនិញ ឬវេចខ្ចប់ អាហារ។

២. យកដបទឹកដែលអាចប្រើប្រាស់ឡើងវិញតាមខ្លួនជានិច្ច

៣. យកដប/កែវផ្ទាល់ខ្លួន មកប្រើប្រាស់ជាប្រចាំ

៤. ប្រើប្រាស់វត្ថុ ឬសម្ភារៈ ធ្វើពីសារធាតុដែលអាចរលាយក្នុងបរិស្ថាន

៥. វេចខ្ចប់អាហាររបស់អ្នក ដោយប្រើប្រាស់ប្រអប់ដែលអាចប្រើប្រាស់ឡើងវិញ ឬសម្ភារៈក្រៅ ពីប្លាស្ទិក។

៦. ចៀសវាងទិញអាហារ ឬម្ហូបដែលវេចខ្ចប់ថង់ប្លាស្ទិកច្រើន

៧. ហ៊ាននិយាយ៖ ប្រាប់ទៅក្រុមហ៊ុន ភោជនីយដ្ឋាន និងសូម្បីតែមិត្តភក្តិរបស់អ្នកឱ្យដឹងថា អ្នកមិនចង់ប្រើប្រាស់ផលិតផលប្លាស្ទិកដែលអាចប្រើប្រាស់បានតែម្តងនោះឡើយ។

ហេតុនេះវិធានការដើម្បីកាត់បន្ថយសំណល់រឹងមានដូចជា៖ ចៀសវាងប្រើប្រាស់ផលិតផលដែលផលិតសំរាមច្រើនដូចជា ក្រដាស កែវជ័រ ចានជ័រ ពិសេសថង់ប្លាស្ទិក។ បន្ថយបរិមាណសំណល់រឹងនៅគេហដ្ឋានតាមរយៈការប្រើប្រាស់ផលិតផលដែលបន្ថយសំណល់។ ដែលសំណល់លំនៅដ្ឋានភាគច្រើន

អាចកែច្នៃជាថ្មីបាន។ ការប្រើប្រាស់ឡើងវិញ គឺប្រើក្នុងគោលដៅផ្សេងពីគោលដៅដើម។ ការប្រើប្រាស់ឡើងវិញអាចចៀសវាងការបញ្ចេញសំណល់ចោលទាំងស្រុង។

ការធ្វើជីកំប៉ុស្តពីសំណល់សរីរាង្គដូចជា សំណល់បន្លែ ផ្លែឈើ សំបកដូង សម្បកពងមាន់ជាដើម។ កំប៉ុស្តកម្មអាចកាត់បន្ថយសំណល់រឹងសរីរាង្គដែលត្រូវចាក់ចោល។ ជីកំប៉ុស្តដែលផលិតបានអាចយកទៅប្រើក្នុងការដាំដំណាំ។ កុំចោល ឬដុតសំណល់រឹងតាមផ្លូវក្បែរផ្ទះ។ ទុកសំណល់នៅចំនុចប្រមូលផ្តុំក្នុងរយៈពេលខ្លីមុនការប្រមូល។ ការធ្វើបែបនេះអាចឲ្យសំរាមនៅក្នុងគំនរមិនស្ថិតនៅរាយប៉ាយលើផ្លូវ បើទុកសំរាមចោលនៅគំនរយូរអាចទាក់ទាញសត្វកណ្តុរ និងសត្វចង្រៃដទៃទៀត។

ជាទូទៅការកាត់បន្ថយបរិមាណសំណល់រឹងមានជម្រើសច្រើនបែបដូចជា ការធ្វើកំប៉ុស្ត ការដុតយន្តការ៣R (កាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃឡើងវិញ)។ ហើយជម្រើសដែល គេនិយមប្រើក្នុងកាត់បន្ថយមាន ការធ្វើកំប៉ុស្ត និងយន្តការ៣R។

យោងក្រសួងបរិស្ថាន (២០២០)បានបង្ហាញពីវិធី៥យ៉ាងដើម្បីកាត់បន្ថយសំណល់ប្លាស្ទិក។




រូបភាព២.១៖វិធី៥យ៉ាងដើម្បីកាត់បន្ថយសំណល់ប្លាស្ទិក (www.moe.gov.kh )

### ២.៥.៣ យុទ្ធនាការសាលាគ្មានសំរាម

ដើម្បីរួមចំណែកក្នុងការថែរក្សាការពារបរិស្ថានសិក្សា ក៏ដូចជាបរិស្ថានសង្គមឲ្យទទួលបាននូវខ្យល់អាកាសបរិសុទ្ធ មានអនាម័យ និងសុខភាពល្អ ជាពិសេសគឺការប្រើប្រាស់វត្ថុអចិន្ត្រៃយ៍ ក្នុងន័យអភិវឌ្ឍន៍បរិស្ថានសិក្សាឲ្យមានភាពស្រស់ស្អាត និងចូលរួមចំណែកក្នុងការថែរក្សាបរិស្ថានធម្មជាតិរបស់ភពផែនដីប្រកបដោយការទទួលខុសត្រូវ និងមានចីរភាព។ យុវជនទាំងអស់គួរគប្បីចងចាំថា (សាលាគ្មានសំរាមលុះត្រាណាតែសាលាគ្មានធុងសំរាម) ជាប្រសាសន៍របស់លោកនាយកសាលាឆ្នើមប្រចាំប្រទេសកម្ពុជាពឹង គឹមឆេន នាយកសាលាបឋមសិក្សាវត្តបូព៌។

ដោយការអនុវត្តគោលការណ៍គ្មានសំរាម សាលារៀននឹងកាត់បន្ថយការចំណាយមិនចាំបាច់ដូចជាសេវាប្រមូលសំរាម ការវេចខ្ចប់សំរាម និងជាពិសេសកាត់បន្ថយចំនួនអ្នកអនាម័យក្នុងសាលា មួយវិញទៀតគោលការណ៍នេះបានបណ្តុះគំនិតទទួលខុសត្រូវរបស់បុគ្គលិក និងសិស្សានុសិស្ស ចំពោះសំរាមដែលខ្លួនបានបង្កើតឡើង។

### ២.៥.៤ យុទ្ធនាការកាត់បន្ថយ បញ្ឈប់ការប្រើប្រាស់ប្លាស្ទិកក្នុងសាលា

ប្រសិនបើមិនមានការប្រើប្រាស់ ឬលុបបំបាត់ប្លាស្ទិកនៅក្នុងសាលារៀន។ ដូចនេះដើម្បីកាត់បន្ថយការប្រើប្រាស់ជាតិប្លាស្ទិកជាអតិបរមាទាមទារឱ្យមានការចូលរួមពីសិស្សានុសិស្ស បុគ្គលិកគ្រប់លំដាប់ថ្នាក់បញ្ឈប់ការប្រើប្រាស់ជាតិប្លាស្ទិក ជាពិសេសនៅក្នុងបរិវេណសាលារៀន ដែលជាផ្នែកមួយក្នុងការ ចូលរួមចំណែកថែរក្សា ការពារ បរិស្ថានធម្មជាតិយើង។

ការអនុវត្តគោលការណ៍លប់បំបាត់ការប្រើប្រាស់ប្លាស្ទិកនៅក្នុងសាលារៀនជាផ្នែកមួយ ចូលរួមកាត់បន្ថយ ឬគ្មានសំរាមនៅក្នុងបរិវេណសាលារៀនផងដែរ។ ជួយសន្សំសំចៃការចំណាយផ្សេងៗរបស់សាលាដូចជា ការប្រើប្រាស់ធុងសំរាម ការប្រើប្រាស់បុគ្គលិកអនាម័យច្រើន ចំណាយលើសេវាដឹកជញ្ជូនសំរាម (ក្រសួងបរិស្ថាន ២០២០)។ ទន្ទឹមនឹងនេះ ក៏ជាផ្នែកមួយជួយកាត់បន្ថយការចំណាយចំពោះបុគ្គលខ្លួនឯងផ្ទាល់តាមរយៈកាត់បន្ថយ ចំណាយវេចខ្ចប់ជាដើម។ ចំពោះគោលការណ៍ខាងលើបានចូលរួមបណ្តុះនូវទម្លាប់ល្អ និងការទទួលខុសត្រូវខ្ពស់ក្នុងការថៃទាំបរិស្ថានសាលាក៏ដូចពិភពលោកទាំងមូល។

### ២.៥.៥ យុទ្ធនាការពិពណ៌ស្នាដៃក្នុងការកែច្នៃសំរាម

យុទ្ធនាការពិពណ៌ស្នាដៃសិស្សក្នុងការកែច្នៃសំរាមឡើងវិញ គឺដើម្បីលើកទឹកចិត្តដល់សិស្ស ក្នុងការចូលរួមកាត់បន្ថយសំរាម ឬប្រើប្រាស់ធនធានកម្រ (សំណល់រឹង) ឱ្យអស់លទ្ធភាព និងប្រកបដោយនិរន្តរភាព។ ដើម្បីជំរុញក្នុងការទុក្ខដាក់ កែច្នៃ និងបង្កើនគំនិតច្នៃប្រតិដ្ឋរបស់បុគ្គលិក សិស្សានុសិស្ស ដោយមានពាក្យស្លោកមួយ "យើងរួមគ្នា ដើម្បីបរិស្ថានសិក្សាស្អាត"។

សារៈប្រយោជន៍៖ កាត់បន្ថយកាកសំណល់ដែលមិនចាំបាច់ បង្កើនគំនិតសន្សំសំចៃ មានគំនិតក្នុងការច្នៃប្រតិដ្ឋថ្មីៗ ផ្លាស់ប្តូរបរិយាកាសសិក្សា បង្កើនសាមគ្គីភាព សិស្ស គ្រូ អាណាព្យាបាល និងផ្សារភ្ជាប់ការអែងាសថវិការដើម្បីសង្គម។

## ២.៦ ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀន

### ២.៦.១ អគារសិក្សា និងបន្ទប់រៀន

យោងតាមក្រសួងអប់រំយុវជន និងកីឡា (២០១៧) ស្តីពីស្តង់ដាសាលាបឋមសិក្សាដែលស្តង់ដាទី៨ បានលើកឡើងថា ហេដ្ឋារចនាសម្ព័ន្ធ និងបរិស្ថានសាលារៀនសំដៅដល់ មានអគារសិក្សាតាមនិយាមគរុកោសល្យតាមបទដ្ឋានបច្ចេកទេសរបស់ក្រសួង មានបន្ទប់សិក្សាធៀបនឹងចំនួនសិស្សស្របតាមនិយាមគរុកោសល្យរបស់ក្រសួង។ ដែលមានបន្ទប់ទីចាត់ការ សាលប្រជុំ សាលគ្រូបង្រៀន បន្ទប់ធនធាន បន្ទប់ថែទាំសុខភាព បង្គន់អនាម័យ បុរស និងស្ត្រីតាមនិយាមប្រើឬតាមសមាមាត្រចំនួនសិស្ស។ អគារនិងបន្ទប់ទាំងអស់មានជម្រាលសម្រាប់សិស្សពិការ មានបំពាក់សម្ភារៈបរិក្ខារអគ្គិសនីនៅលើអគារនិងបន្ទប់សិក្សា។

### ២.៦.២ សម្ភារៈបរិក្ខារ និងការផ្គត់ផ្គង់

បន្ទប់ទីចាត់ការត្រូវមានគ្រឿងសង្ហារឹម និងបរិក្ខារ បច្ចេកទេសកុំព្យូទ័រ ព្រីនធ័រ ទូដាក់ឯកសារ និងទូដែក។ មានផ្គត់ផ្គង់សម្ភារៈបរិក្ខារសមស្រប សម្រាប់សាលប្រជុំ បន្ទប់ធនធាន បណ្ណាល័យបន្ទប់រៀនភាសាបរទេស បន្ទប់រៀនកុំព្យូទ័រ បន្ទប់ពិសោធន៍ បន្ទប់រោងជាង បន្ទប់រៀនគំនូរ ចម្លាក់និងសូន្យរូប បន្ទប់រៀនសិល្បៈនិងតូរ្យតន្ត្រី បន្ទប់ថែទាំសុខភាព ប្រអប់សង្គ្រោះបឋម បង្គន់អនាម័យ (សម្រាប់បុរសនិង

សម្រាប់ស្ត្រី) និងកន្លែងលាងសម្អាតដៃ ថែមទាំងមានផ្គត់ផ្គង់ទឹកស្អាតសម្រាប់ប្រើប្រាស់ និងមានផ្គត់ផ្គង់បណ្តាញអគ្គិសនី (ក្រសួងអប់រំ យុវជន និងកីឡា ២០១៧)។

### ២.៦.៣ បរិស្ថានសាលារៀន

មានរបង និងទ្វារសាលារៀនគត់មត់ ស្លាក ខ្លោងទ្វារ ទីធ្លាសាលា សួនច្បារ ដងទង់ជាតិ សួនជីវៈចម្រុះ ទីលានកីឡា សួនកុមារ មណ្ឌលវប្បធម៌ ប្រពៃណី រោងបាយ ធុងសំរាម និងឡដុតសំរាម។ ថែមទាំងមានកន្លែងចតយានជំនិះគ្រប់ប្រភេទប្រកបសណ្តាប់ធ្នាប់។ ថែមទាំងមានផ្លូវដើរពីអគារមួយទៅអគារមួយទៀត និងមានដើមឈើជាម្លប់។ បើមានកន្លែងលក់ចំណីអាហារ ត្រូវមានអនាម័យ និងសុវត្ថិភាព (ក្រសួងអប់រំយុវជន និងកីឡា ២០១៧)។ Miah (2015) បានលើកឡើងថាកត្តាបរិស្ថានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយដល់ការអភិវឌ្ឍន៍សិស្សនៅសាលា។ លើសពីនេះ Konstan (2014) អះអាងថា ដំណើរការសិក្សាប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពតែក្នុងបរិយាកាសគាំទ្រ និងសុវត្ថិភាពប៉ុណ្ណោះ។ ដូច្នេះស្ថាប័នអប់រំគួរយល់ដឹងក្នុងការកើនឡើងគុណភាពនៃបរិយាកាសសាលារៀន ដើម្បីបង្កើតការរៀនសូត្រប្រកបដោយប្រសិទ្ធភាព។ លើសពីនេះទៀតបរិយាកាសសាលារួមបញ្ចូលធាតុផ្សំទាំងអស់ដែលរួមចំណែកបង្កើតបរិយាកាសក្នុងដំណើរការបង្រៀន។ Faulkner, et al (2005) ចែងថាការរៀនសូត្របរិស្ថានមានទាំងរូបវន្ត(សង្គម ចិត្តសង្គម វប្បធម៌) និងមិនមែនរូបវន្តវាក៏រួមបញ្ចូលផងដែរនូវធាតុផ្សំដែលមិនមែនជារូបវន្តដូចជាអន្តរកម្មសង្គមនៅសាលា ដែលពាក់ព័ន្ធនឹងសមាជិកសាលាទាំងអស់។

លើសពីនេះ VidačekHainš, et al (2008) ដោយពន្យល់ថា បរិយាកាសនៃការសិក្សារបស់សិស្សគ្របដណ្តប់ទាំងមូលនៃអថេរនៅក្នុងផ្នែកនៃការស្រាវជ្រាវផ្លូវចិត្ត គរុកោសល្យ និងវប្បធម៌។ ម្យ៉ាងវិញទៀតបរិយាកាសសាលាគឺជា ការរួមបញ្ចូលធាតុទាំងអស់របស់សាលាក្នុងការជះឥទ្ធិពល ដល់ស្ថានភាពនៃសកម្មភាពសិក្សា។ ទោះជាយ៉ាងណាក៏ដោយ លក្ខខណ្ឌនៃបរិយាកាសសាលាមិនអាចខុសពីបរិយាកាសរូបវន្ត ដូចជាស្ថានភាពអគារ និងបរិក្ខារសាលា ដែលគ្រប់គ្នាអាចកំណត់បានដោយងាយ ដោយសង្កេតមើលដោយផ្ទាល់នៅក្នុងសាលាគោលដៅ។ Arsyad (2009) អះអាងថា បរិក្ខារសាលាល្អអាចជំរុញសិស្សឱ្យចាប់អារម្មណ៍ និងចង់បានកាន់តែច្រើនក្នុងការចូលរួមមេរៀនក្នុងថ្នាក់។ បង្កើនឱ្យមានការលើកទឹកចិត្ត

របស់សិស្សក្នុងការសិក្សា ដែលអាចមានឥទ្ធិពលដោយស្វ័យប្រវត្តិលើ សមិទ្ធិផលរបស់សិស្ស។ បរិស្ថានសាលារៀនគឺមានសារៈសំខាន់ក្នុងការធ្វើឱ្យសិស្សរីករាយនឹងមេរៀន និងចូលរួមក្នុងដំណើរការសិក្សា។

យោងពន្លកទិន (២០០២) បរិស្ថានចែកចេញជា៣ប្រភេទសំខាន់ៗគឺៈ

(១) បរិស្ថានធម្មជាតិ(មានជីវិត និងឥតជីវិត)គឺជាអ្វីៗដែលកើតមានឡើងដោយឯកឯង ក្រៅពីសកម្មភាពពលកម្ម ផលិតកម្មមនុស្សគឺវាកើតឡើងដោយធម្មជាតិខ្លួនឯងផ្ទាល់ដូចជាៈទឹក ដី ភ្លើង ខ្យល់។

(២)បរិស្ថានសង្គមវប្បធម៌ សំដៅលើអ្វីៗ ដែលកើតមានជារូបរាងឡើងដោយផ្ទាល់ដៃ ពលកម្មផលិតកម្មប្រកបដោយការប៉ិនប្រសប់ និងការច្នៃប្រឌិតរបស់មនុស្ស ដើម្បីបម្រើសំណូមពរ និងតម្រូវការក្នុងជីវភាពរស់នៅរបស់មនុស្ស។ រាល់សមិទ្ធផលទាំងនេះមនុស្សបានច្នៃក្នុងការបង្កើតឡើង ដោយធ្វើការកែច្នៃធម្មជាតិ បើគ្មានបរិស្ថានធម្មជាតិ គឺមិនអាចមានបរិស្ថានសង្គមវប្បធម៌បានឡើយ។ តួយ៉ាងបរិស្ថានសង្គមវប្បធម៌មានដូចជា សកម្មភាពសង្គម ស្ថាប័ន ការគ្រប់គ្រងដឹកនាំក្នុងសង្គម នយោបាយ សេដ្ឋកិច្ច ការអប់រំ សាសនាប្រវត្តិសាស្ត្រ ការកម្សាន្ត អគារផ្សេងៗ ផ្លូវថ្នល់ ស្ពាន ក្រុង ភូមិ ស្រុក ប្រឡាយទឹក ឧបករណ៍ផលិតកម្ម។

(៣) បរិស្ថានមនុស្ស (មានជិវិត និងឥតជីវិត) មនុស្សទូទៅរស់នៅលើភពផែនដីទាំងអស់

## ២.៦.៤ បរិស្ថានសិក្សា

យោងតាម Ellström, et al (2008) បានឱ្យនិយមន័យបរិស្ថានសិក្សាៈ សំដៅដល់អ្វីៗទាំងអស់ដែលនៅក្នុងបរិវេណនិងជុំវិញគ្រឹះស្ថានសិក្សា ដូចជា អាគារសិក្សា បន្ទប់រៀន កន្លែងលក់ដូរ ឬរៀបចំចំណីអាហារ របង សម្ភារៈរូបវន្តផ្នែកអនាម័យ សម្ភារៈសិក្សា សួនច្បារ សួនបន្លែ រុក្ខជាតិជាដើម។ បរិស្ថានសិក្សាចែកចេញជា២ ប្រភេទគឺ បរិស្ថានសិក្សាអំណោយផល និងបរិស្ថានសិក្សារារាំង។ បរិស្ថានសិក្សាអំណោយផលសំដៅទៅលើលក្ខខណ្ឌ និងការអនុវត្តដែលលើកកម្ពស់តុល្យភាពរវាងការសិក្សា និងការអភិវឌ្ឍន៍ពោលគឺបរិយាកាសដែលបុគ្គលម្នាក់ៗអាចផ្លាស់ប្តូររបៀបសិក្សាបាន។ ផ្ទុយទៅវិញបរិស្ថានសិក្សាដែលមានការរឹតត្បិតសំដៅលើលក្ខខណ្ឌ និងការអនុវត្តដែលទំនងជារារាំងទាំងការសិក្សា និងការអភិវឌ្ឍន៍ឬជំរុញការរៀនសូត្រ។

### ២.៦.៥ ការរៀបចំសោភ័ណភាពសាលា

#### ក. ពាក្យស្លោក

នៅក្នុងសាលាត្រូវរៀបចំពាក្យស្លោកផ្សេងៗ ដើម្បីតាំងលម្អ ក៏ដូចជាការផ្ដល់ឱវាទ អប់រំផ្សេងៗ ដល់សិស្សានុសិស្ស ដូចពាក្យស្លោកមួយពោលថា "ការអប់រំមាននៅគ្រប់ទីកន្លែង"។ ក្នុងនោះមានទីកន្លែងមួយចំនួនដែលត្រូវបានដាក់តាំងពាក្យស្លោកក្រៅពីក្នុងថ្នាក់រៀនដូចជា៖ នៅតាមទីធ្លាសាលា (តាមដើមឈើ សួន ជញ្ជាំងរបងទាំងក្នុង និងក្រៅ ជញ្ជាំងអាគារ សិក្សា)។ នៅក្នុងអាគារសិក្សា (តាមជណ្ដើរឡើងចុះនៃអាគារ ជញ្ជាំងបន្ទប់រៀនខាងក្រៅ)។

#### ខ. ការថែទាំ

ក្រៅពីការរៀបចំការតាំងបង្ហាញផ្សេងៗដើម្បីជាការទាក់ទាញ និងបង្កើនសោភ័ណភាព ការថែទាំក៏ជារឿងមួយដ៏សំខាន់ផងដែរ។ វាអាចជួយនូវអ្វីដែលយើងខិតខំធ្វើ អាចប្រើប្រាស់បានយូរអង្វែងជាពិសេសគឺការជួយសន្សំសំចៃលើការចំណាយថវិកាក្នុងការរៀបចំឡើងវិញ។ ដូចនេះសាលាត្រូវមានកាល វិភាគ និងមានអ្នកទទួលខុសត្រូវឱ្យបានច្បាស់លាស់ ក្នុងការថែទាំ និងប្រើប្រាស់ឱ្យអស់លទ្ធភាព។

#### គ. ធ្វើឱ្យប្រសើរឡើងចំពោះសុខភាព និងសុខុមាលភាព

សាលារៀនត្រូវយកចិត្តទុកដាក់ខ្ពស់ទៅលើសុខភាព និងសុខុមាលភាពចំពោះសិស្សានុសិស្ស និងបុគ្គលិកគ្រប់លំដាប់ផងដែរ។ ដើម្បីលើកកម្ពស់សុខភាព និងសុខុមាលភាព ត្រូវយកចិត្តទុកដាក់លើ៖

(១) សណ្ដាប់ធ្នាប់ និងអនាម័យ៖ ការរៀបចំសណ្ដាប់ធ្នាប់ក្នុងសាលារៀនគឺជាការចាំបាច់ណាស់ ដើម្បីធ្វើយ៉ាងណាឱ្យបរិយាកាសក្នុង សាលាគួរជាទីទាក់ទាញ និងបង្ហាញពីភាពស្អាត និងរបៀបរាបរយ។ ទាំងនេះវាបានបង្ហាញពីការយកចិត្ត ទុកដាក់ទៅលើអនាម័យផង។ យើងដឹងហើយថា ការរស់នៅប្រកបដោយអនាម័យ ធ្វើឱ្យយើងមានសុខភាពល្អ បញ្ញាស្មារតីភ្លឺស្វាង និងជួយឱ្យការរៀន និងការបង្រៀនរបស់លោកគ្រូ អ្នកគ្រូ ដំណើរការប្រកបដោយ ប្រសិទ្ធភាពផងដែរ។

(២) បន្ទប់ទឹក ការរៀបចំ៖ កំណាត់បែងចែក និងឧបករណ៍សម្ភារៈក្នុងបន្ទប់ទឹក ដើម្បីធានាឱ្យមានអនាម័យ និងសោភ័ណភាពក្នុងបន្ទប់ទឹកដោយផ្ដោតសំខាន់ទៅលើ៖ ត្រូវរៀបចំខណ្ឌចែកបន្ទប់ទឹក

ស្រី និងបន្ទប់ទឹកប្រុស (សិស្សតូច សិស្សធំ សម្រាប់បុគ្គលិក) ដោយមានស្លាកសម្គាល់ត្រឹមត្រូវ និងច្បាស់លាស់។ ត្រូវតំឡើងឧបករណ៍ប្រើប្រាស់និងសម្ភារៈក្នុងបន្ទប់ទឹកឱ្យបានគ្រប់គ្រាន់ ស្របតាមស្តង់ដាសម្ភារៈបន្ទប់ទឹក កម្រិតអាយុ និងភេទ (មានភ្ជាប់តារាងឧបករណ៍ និងសម្ភារៈប្រើប្រាស់)។

ត្រូវរៀបចំឱ្យមានជាកូន រុក្ខជាតិ និងកូនផ្កាដើម្បីបន្ថែមភាពបៃតង និងសោភ័ណភាពនៅក្នុង បន្ទប់ទឹក។ ត្រូវមានសម្ភារៈសម្អាតគ្រប់គ្រាន់ និងទុកដាក់បានត្រឹមត្រូវមានសណ្តាប់ធ្នាប់ និងត្រឹមត្រូវ តាមកន្លែងឱ្យបានសមរម្យ។ ត្រូវមាននិងបិទស្លាកសញ្ញាណែនាំ ហាមឃាត់ និងការប្រើប្រាស់បន្ទប់ទឹកឱ្យបានត្រឹមត្រូវ និង បង្ហាញបានច្បាស់លាស់ដល់អ្នកប្រើប្រាស់។ ត្រូវមានស្លាកសញ្ញា ឬរូបភាពបង្ហាញពីរបៀបនៃការលាងសម្អាតដៃ និងការប្រើប្រាស់បន្ទប់ប្រកបដោយអនាម័យ និងសុវត្ថិភាព។ ត្រូវត្រួតពិនិត្យ ថែទាំ និងជួសជុលឧបករណ៍សម្ភារៈក្នុងបន្ទប់ទឹកជាប្រចាំ និងល្អប្រសើរ។ ត្រូវត្រួតពិនិត្យ ថែទាំ និងជួសជុលប្រព័ន្ធទឹកស្អាត និងប្រព័ន្ធបង្ហូរទឹកកាកសំណល់ជាប្រចាំ។ ត្រូវត្រួតពិនិត្យ ថែទាំ និងជួសជុលក្បាលបាញ់ សាក់កាដូរបង្គន់ និងទុយោផ្សេងៗ កុំឱ្យជ្រាបទឹក ឬហូរទឹកចោល (ក្រសួងអប់រំ យុវជន និងកីឡា ២០២៣)។

## ២.៧. ការចូលរួមរបស់ភាគីពាក់ព័ន្ធ

ការអភិវឌ្ឍសាលារៀនទាមទារចាំបាច់នូវធនធានមនុស្ស ធនធានសម្ភារៈ ថវិកាយន្តការចាត់តាំងគ្រប់គ្រង ទំនួលខុសត្រូវ សេវាកម្ម ព្រមទាំងទំនាក់ទំនងខាងក្នុង និងខាងក្រៅឲ្យមានលក្ខណៈស៊ីសង្វាក់គ្នាប្រកបដោយតុល្យភាព។ ការសម្រេចលក្ខខណ្ឌនេះទាមទារការព្យាយាមប្រមូលផ្តុំកម្លាំងអប់រំ ដែលមានក្នុងសាលារៀន និងសហគមន៍ព្រមទាំងទៅតាមលទ្ធភាពរបស់សាលានីមួយៗ ដើម្បីពូតផ្តុំជាអង្គភាពមួយរឹងមាំ សម្រាប់ធានាដល់ដំណើរការប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព និងធានាបាននិរន្តរភាព។

ជាការពិតតាមសាលារៀនសុទ្ធមានគោលនយោបាយ ទស្សនវិស័យច្បាស់លាស់ ថែមទាំងការចូលរួមគាំទ្រពីសហគមន៍ ការគ្រប់គ្រងរដ្ឋបាល និងហិរញ្ញវត្ថុល្អប្រកបដោយតម្លាភាព មានបរិស្ថានប្រកបដោយសុវត្ថិភាពសោភ័ណភាពជាទីពេញចិត្ត។

### ២.៧.១ ការចូលរួមរបស់នាយកសាលារៀន

នាយកសាលារៀនល្អ សំដៅដល់នាយកដែលបង្កើតនូវបរិស្ថានល្អសម្រាប់ការបង្រៀន និងរៀន។ បរិស្ថានល្អបម្រើឲ្យការបង្រៀន និងរៀនបានល្អប្រកបដោយគុណភាព (ហង់ជួន ណារ៉ុន ២០១៦)។ នាយកសាលារៀនមានតួនាទីសំខាន់ណាស់ក្នុងការធ្វើឲ្យដំណើរការអប់រំរបស់អង្គភាពទទួលបាន គុណភាពប្រកបដោយវឌ្ឍភាព ដូច្នេះនាយកសាលាត្រូវមានតួនាទីធ្វើយ៉ាងណាឲ្យអង្គភាពរបស់ខ្លួន មានភាពស្រស់បំព្រង និងសោភ័ណដែលមានភាពទាក់ទាញ សម្រាប់បម្រើការរៀន និងបង្រៀន។ សាលារៀនដ៏ល្អមានបរិស្ថានល្អ ទាមទារនាយកសាលាល្អ មានគុណភាព ប្រសិទ្ធភាព។

នាយកសាលាជាបេះដូងរបស់សាលារៀន ដែលត្រូវមានផែនការទិសដៅច្បាស់លាស់ចំពោះផែនការអភិវឌ្ឍសាលារៀនដូចជាៈ រៀបចំរបាយការអភិវឌ្ឍសាលារៀន ការកែលម្អបរិស្ថានសាលារៀន រៀបចំរបាយការណ៍សម្ភារៈ និងឧបករណ៍ក្នុងការលើកកម្ពស់បរិស្ថានសាលារៀន រៀបចំរបាយការណ៍ថវិកា ក្នុងការចូលរួមលើកកម្ពស់បរិស្ថានសាលារៀន និងរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងបរិស្ថាន និងតាមដានបរិស្ថាន។ ប្រើប្រាស់ថវិកាសាលារៀនបានត្រឹមត្រូវតាមតម្រូវការជាក់ស្តែងចាំបាច់(រៀបចំកែលម្អបរិស្ថាន) របស់សាលារៀន។

ជំរុញលើកទឹកចិត្តបុគ្គលិកឲ្យជួយស្វែងរកដៃគូអភិវឌ្ឍសាលារៀន ដើម្បីអភិវឌ្ឍបរិស្ថានសាលារៀនឲ្យល្អប្រសើរ។ នាយករៀបចំការប្រើប្រាស់ថវិកាគោរពទៅតាមផែនការប្រចាំឆ្នាំ ដើម្បីដំណើរការសាលារៀនឆ្លើយតបតាមគោលដៅ (អភិវឌ្ឍកែលម្អបរិស្ថានសាលារៀន)។ ត្រូវបានរៀបចំបែងចែកតួនាទីភារកិច្ចទទួលខុសត្រូវផ្នែក បរិស្ថានដោយមានតម្លាភាព និងការស្ម័គ្រចិត្ត មានការជំរុញលើកទឹកចិត្តដល់បុគ្គលិកឲ្យមានការប្រាស្រ័យទំនាក់ទំនងល្អនៅក្នុងអង្គភាពមិនថាជាមួយសិស្ស បុគ្គលិកគ្នាឯងនិងជាមួយគណៈគ្រប់គ្រង ដើម្បីដំណើរការអភិវឌ្ឍសាលាសាលរៀនឲ្យមានប្រសិទ្ធភាព។ ក្នុងការជំរុញទឹកចិត្តគ្រូឲ្យមកបំពេញភារកិច្ចប្រកបដោយមនសិកា និងទំនួលខុសត្រូវដើម្បីជួយឲ្យដំណើរការគ្រប់គ្រងបរិស្ថានសាលារៀនមានគុណភាព។

ការចាត់ចែងប្រគល់ការងារដល់បុគ្គលិកដោយឈរលើស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីឲ្យដំណើរការគ្រប់គ្រងបរិស្ថានសាលារៀន មានប្រសិទ្ធភាព និងគុណភាព។ ជំរុញឲ្យលោកគ្រូ អ្នកគ្រូ សិស្ស ចូលរួមក្នុងសកម្មភាពការងារសង្គមដើម្បីបង្កើនទំនាក់ទំនងជា មួយសហគមន៍ មាតាបិតា អាណាព្យាបាល និងដៃគូរអភិវឌ្ឍផ្សេងៗទាំងជាតិ និងអន្តរជាតិ។ មានទំនាក់ទំនងល្អជាមួយអាណាព្យាបាលសិស្ស សហគមន៍ និងសាលារៀនដទៃទៀត និងទំនាក់ទំនងល្អជាមួយអាជ្ញាធរ ថ្នាក់ដឹកនាំគ្រប់កម្រិត ជាមួយគណៈកម្មការទ្រទ្រង់សាលារៀន និងអ្នកផ្គត់ផ្គង់ដើម្បីលើកកម្ពស់ការអភិវឌ្ឍកែលម្អបរិស្ថានសាលារៀន។

មិនតែប៉ុណ្ណោះ នាយកសាលា ត្រូវស្វះស្វែងរកថវិកាផ្សេងទៀតតាមរយៈ ការផ្ញើកង់ ម៉ូតូនិងកន្លែងលក់ដូរក្នុងសាលា ការជួលទីតាំងក្នុង និងក្រៅរបងអាជីវករលក់ដូរ អ្នកបញ្ញើរថយន្ត ម៉ូតូជាដើម។ នាយកសាលាអាចផ្តើមធ្វើបុណ្យផ្កាសាមគ្គី ឥណទានសាលារៀន សមាគមមាតាបិតាសិស្ស ថវិកាអាជីវករសាលារៀន ថវិកា ដឹកជញ្ជូនសិស្ស និងថវិកាសំណល់(អេតចាយ) និងបង្កើតទិវាអប់រំសិល្បៈតន្ត្រីសិស្សប្រចាំឆ្នាំជាដើម។

### ២.៧.២. ការចូលរួមរបស់លោកគ្រូ អ្នកគ្រូ

យោងក្រសួងអប់រំ យុវជន និងកីឡា (២០១៨) គ្រូបង្រៀនជាអ្នកមគ្គទេសដ៏ចំណានក្នុងការបង្ហាញផ្លូវ និងទីប្រឹក្សា ជាអ្នកដឹកនាំព្រមទាំងផ្តល់ឲ្យ សិស្សបានឃើញ បានយល់ពីឧត្តមគតិជឿនលឿន និងបង្ហាញសិស្សពីមាគ៌ាអភិវឌ្ឍចំណេះដឹង សមត្ថភាពប្រកបដោយភាពត្រឹមត្រូវ។ ក្នុងនោះដែរគ្រូបង្រៀនមិនមែនតែបង្រៀនមេរៀនដែលគេកំណត់នោះទ ប៉ុន្តែត្រូវតែជាអ្នករំលេចឲ្យសិស្សបានឃើញពីសង្គមដែលពួកគេបានរស់នៅផង និងបង្ហាញពីគំនិតជឿនលឿនផង។ គ្រូបង្រៀនត្រូវបង្រៀនសិស្សផ្សារភ្ជាប់នឹងបរិស្ថាន ដោយបង្រៀនទ្រឹស្តី ដើម្បីឲ្យសិស្ស យកទៅប្រតិបត្តិក្នុងសហគមន៍ដែលពួកគេរស់នៅឲ្យកាន់តែល្អប្រសើរ គឺសហគមន៍ដែលមានសោភ័ណភាព មានបរិស្ថានល្អ ជាទីកន្លែងដែលគួរឲ្យរស់នៅប្រកបសុខុមាលភាពជាទីមនោរម្យ។ តួនាទីរបស់គ្រូបង្រៀន ក្នុងការចូលរួមគ្រប់គ្រងបរិស្ថានសាលារៀនដូចជា៖

**(១) សកម្មភាពបង្រៀនរបស់គ្រូបង្រៀន៖** ចូលរួមពិនិត្យរបៀបរៀបរយលើបរិស្ថានសាលារៀនជាប្រចាំមុនពេលដល់ម៉ោងបង្រៀន ណែនាំសិស្សឲ្យសម្អាតបរិស្ថាន (ទាំងក្នុងថ្នាក់ និងក្រៅថ្នាក់) មានការ

ត្រួតពិនិត្យសណ្តាប់ធ្នាប់ អនាម័យ របៀបរៀបរយ (ទាំងក្នុង និងក្រៅថ្នាក់រៀន) ចូលរួមជាមួយសិស្សក្នុងការរៀបចំតុបតែងលម្អថ្នាក់រៀន និងក្រើនរំលឹក និងណែនាំសិស្សឲ្យចេះធ្វើអនាម័យ រៀបចំទុកដាក់សំរាម និងកាកសំណល់ជាប្រចាំ។

(២) **លើកទឹកចិត្តសិស្ស៖** គ្រូបង្រៀន តែងតែចូលរួមដឹកនាំសិស្សធ្វើពលកម្មសម្អាតបរិស្ថានសាលារៀន (ទាំងក្នុង និងក្រៅ) សរសើរ ឬឱ្យជារង្វាន់ដល់សិស្សចូលរួមបំពេញការងារចូលរួមថែរក្សា និងសម្អាតបរិស្ថានសាលារៀន។ មានការជួយណែនាំបន្ថែមចំពោះសិស្ស ដែលអសកម្មឲ្យមកចូលរួមក្នុងការសម្អាតបរិស្ថាននិងស្រលាញ់បរិស្ថានសាលារៀន ជួយណែនាំសម្របសម្រួលសិស្សបន្ថែមដល់សិស្សក្នុងការបង្កើត ក្លឹបបរិស្ថាន និងលើកទឹកចិត្តសិស្សឲ្យមានគំនិតច្នៃប្រឌិត និងបត់បែន។

(៣) **ការចូលរួមសហការ៖** ពេញចិត្តទទួលយកតាមការបែងចែងតួនាទីរបស់នាយកសាលារៀនចំពោះផ្នែកបរិស្ថានសាលារៀន មានការសហការជាមួយគ្រូក្នុងអង្គភាព និងសិស្សលើកែលម្អបរិស្ថានសាលារៀន ការសម្រេចរាល់កិច្ចការដែលនាយកបានបែងចែងចំពោះការងារបរិស្ថានសាលារៀន និងសម្រេចកិច្ចការដែលនាយកបានបែកចែងចំពោះការងារបរិស្ថានសាលារៀន។

(៤) **ទំនាក់ទំនង៖** មានទំនាក់ទំនងល្អជាមួយមាតាបិតាសិស្ស និងសហគមន៍ ទំនាក់ទំនងល្អជាមួយថ្នាក់ដឹកនាំគ្រប់កម្រិត និងសាលាដទៃទៀត និងចូលរួមកម្មវិធីផ្សេងៗ ទាក់ទងកាថែរក្សាបរិស្ថាននៅក្នុងសាលារៀន និងសង្គម។

### ២.៧.៣. ការចូលរួមរបស់សិស្ស

ការចូលរួម ពីសិស្សានុសិស្សពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការជួយលើកកម្ពស់បរិស្ថានសិក្សាពីព្រោះ សិស្សជាអ្នកដែលចូលរួម និងទទួលផលប្រយោជន៍ដោយផ្ទាល់ពីបរិស្ថានសាលារៀន។ ដូច្នេះសិស្សត្រូវចូលរួមជាមួយសាលារៀនដូចជា៖ ចូលរួមអនុវត្តផែនការ ភារកិច្ចពីគ្រូ គោរពវិន័យ និងបទបញ្ជាសាលារៀន ចូលរួមសហការជាមួយគ្រូបង្រៀន និងថ្នាក់ដឹកនាំសាលាក្នុងការសម្អាត និងថែរក្សាអនាម័យ និងសណ្តាប់ធ្នាប់សាលារៀន បានចូលរួមរៀបចំតុបតែងលម្អ និងសណ្តាប់ធ្នាប់ថ្នាក់រៀន ចូលរួមជួយសម្អាតបរិស្ថានសាលារៀន ចូលរួមធ្វើពលកម្មរើសសំរាម សម្អាតបរិស្ថានសាលារៀនបន្ទាប់ពីការ

សិក្សា ចូលរួមដាំដើមឈើ និងដើមផ្កាសម្រាប់លម្អបរិស្ថានសាលារៀន ចូលរួមរៀបចំសួនបន្លែចម្រុះ និងសួនច្បារលម្អរ ចូលរួមស្រោចទឹកដើមឈើ ផ្កា និងដំនាំក្នុងសួនបន្លែចម្រុះតាមវេនជាប្រចាំ បានចូលរួមសម្អាតបង្គន់អនាម័យ និងកន្លែងលាងដៃតាមវេនជាប្រចាំ។

រៀបចំទុកដាក់មធ្យោបាយធ្វើដំណើររបស់ខ្លួននៅកន្លែងទុកយ៉ាងរបៀបរៀបរយល្អ ចូលរួមថែរក្សាការពារបរិស្ថាន និងទ្រព្យសម្បត្តិសាលារៀន ណែនាំមិត្តភក្តិ និងអ្នកដ៏ទៃឲ្យចូលរួមថែរក្សាបរិស្ថានសាលារៀន ចូលរួមសហការជាមួយសិស្សដទៃទៀតក្នុងការច្នៃប្រឌិតលើការរៀបចំបរិស្ថានសាលារៀន ចូលរួមរក្សានូវវប្បធម៌សាមគ្គី សន្តិភាព មិនប្រើអំពើហឹង្សា និងគោរពស្រលាញ់គ្នាទៅវិញទៅមកចូលរួមផ្សព្វផ្សាយ និងចូលរួមកម្មវិធីបរិស្ថានសាលារៀន និងបរិស្ថាន សង្គម (ក្រសួងអប់រំ យុវជននិងកីឡា ២០១៨)។

### ២.៧.៤. ការចូលរួមរបស់សហគមន៍

សហគមន៍សំដៅទៅលើ មាតាបិតាសិស្ស រដ្ឋអំណាចមូលដ្ឋាន និងតំណាងសហគមន៍ដែលជាសមាជិកគណៈកម្មការគ្រប់គ្រងសាលារៀន។ យោងរបាយការណ៍របស់ ក្រសួងអប់រំ យុវជន និងកីឡា (២០១៧) សហគមន៍មានតួនាទីយ៉ាងសំខាន់ក្នុងការជួយអភិវឌ្ឍសាលារៀន ជួយអនុវត្តនូវកម្មវិធីកំណែទម្រង់វិស័យអប់រំយ៉ាងមានប្រសិទ្ធភាព និងសក្តានុពល។ ដោយសាលារៀន និងសហគមន៍ជាកោសិការបស់សង្គមជាតិ។

ជានិច្ចកាលសាលារៀន និងសហគមន៍ មានទំនាក់ទំនងគ្នាទៅវិញទៅមក ព្រោះសហគមន៍ គឺមានតួនាទីសំខាន់ក្នុងដំណើរការអភិវឌ្ឍសាលា។ ការជួយរបស់សហគមន៍បានរួមចំណែកក្នុងការលើកកម្ពស់គុណភាពបង្រៀន រៀន លទ្ធផលសិក្សារបស់សិស្ស និងការចូលរួមរៀបចំផែនការ ការស្វែងរកធនធាន និងការតាមដានសកម្មភាពសាលារៀន (ក្រសួងអប់រំ យុវជន និងកីឡា ២០១៧) ដូចនេះសហគមន៍ជាអ្នកចូលរួម និងធ្វើកិច្ចការងារយ៉ាងសកម្មដើម្បីបំរើដល់វិស័យអប់រំ ដោយពួកគាត់មិនទាមទារនូវប្រាក់កម្រៃផ្ទុយមកវិញពួកគាត់ថែមទាំងបានបរិច្ចាគថវិកាផ្ទាល់ខ្លួនដើម្បីអភិវឌ្ឍសាលារៀនទៀតផង។

សហគមន៍មានតួនាទីដ៏សំខាន់ក្នុងដំណើរការអភិវឌ្ឍសាលារៀន ទំនាក់ទំនងល្អរវាងសាលារៀន និងសហគមន៍ជាកត្តាចាំបាច់មិនអាចខ្វះបាន (ក្រសួងអប់រំ យុវជន និងកីឡា ២០១៧)។ សហគមន៍បាន

អនុវត្តសកម្មភាព ដែលមានការឯកភាពនៅក្នុងផែនការកែលម្អសាលារៀនប្រចាំឆ្នាំ ឬដោយមានការប្តេជ្ញាចិត្តពីសំណាក់សហគមន៍ (ក្រសួងអប់រំ យុវជន និងកីឡា ២០១៦)។

ភារកិច្ចរបស់សហគមន៍ គឺប្រមូលកុមារឲ្យចូលរៀនស្វែងរកចំណូលថវិកា គ្រប់គ្រងថវិកា ថែរក្សាទ្រព្យសម្បត្តិសាលារៀន ចូលរួមសាងសង់ ជួសជុលសាលារៀន បំផុសកូនចៅឲ្យទៅសាលារៀន តាមដានការសិក្សារៀនសូត្ររបស់សិស្ស ចូលរួមតាមដានត្រួតពិនិត្យការអនុវត្តរបស់សាលារៀន ពង្រឹងពង្រីកសមត្ថភាពយល់ដឹងអំពីអភិវឌ្ឍសាលាការថែរក្សាសម្បត្តិសាលារៀនត្រូវមានការចូលរួមពីសហគមន៍ផងដែរ។




រូបភាព ២.១ រៀបរៀងដោយ និស្សិត លឿង កុសល (ការថែរក្សាសម្បត្តិសាលារៀន)

ម្យ៉ាងវិញទៀតសហគមន៍ បានចូលរួមសាងសង់ ជួសជុលសាលារៀនដូចតទៅ៖




រូបភាព ២.២ រៀបរៀងដោយ និស្សិត លឿង កុសល (ចូលរួមសាងសង់ ជួសជុលសាលារៀន)

សរុបមក តាមរយៈការលើកឡើងអំពីអ្នកស្រាវជ្រាវនីមួយៗបានបង្ហាញថា នៅសាលាបឋមសិក្សាពិតជាមានការប្រឈមក្នុងការរៀបចំបរិស្ថានសាលា និងបរិស្ថានសិក្សា។ ទន្ទឹមនឹងនោះពួកគេក៏មានតម្រូវការជាច្រើនដើម្បីជួយគាំទ្រដល់ការរៀបចំបរិស្ថានសិក្សាប្រកបដោយប្រសិទ្ធភាព និងគុណភាព។ ក្នុងនោះក៏បានដកស្រង់យកចំណុចគោលសំខាន់ៗនៃបញ្ហាប្រឈមមានដូចជា បញ្ហាសម្ភារៈ បញ្ហាសំរាមនិងរៀបចំហេដ្ឋារចនាសម្ព័ន្ធ។ ចំណែកឯកសារជ្រាវជ្រាវ មុនៗក៏បានរកឃើញពីបញ្ហាបរិស្ថានសិក្សាផងដែរ។




រូបភាព២.៣៖ រៀបរៀងដោយ និស្សិត លឿង កុសល (សង្ខេបពីខ្លឹមសារជំពូកទី២)

# ជំពូក ៣

# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

យោងតាមលិខិតឧទ្ទេសនាមលេខៈ៤០៨២ អយក.វជអ ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៣ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការចាត់តាំងឱ្យចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវតាមសាកលវិទ្យាល័យ និងរាជធានី ខេត្តនានា ចាប់ពីថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣ នៅតាមគ្រឹះស្ថានសិក្សារបស់រដ្ឋ។

អ្នកសិក្សាបានរៀបចំរួចរាល់ដើម្បីយកលិខិតឧទ្ទេសនាមទៅឱ្យមន្ទីរអប់រំខេត្ត និងសាលារៀនគោលដៅព្រមទាំងភ្ជាប់ជាមួយនូវកម្រងសំណួរ និងសំណួរសម្ភាសន៍ពេលចុះប្រមូលទិន្នន័យយកមកធ្វើការវិភាគទិន្នន័យសម្រាប់សរសេរក្នុងនិក្ខេបបទបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ។ ការសិក្សាស្រាវជ្រាវប្រធានបទស្តីពី **«ទស្សនៈរបស់ នាយក គ្រូ សិស្ស និងសហគមន៍ ចំពោះការរៀបចំបរិស្ថានសិក្សានៅកម្រិតបឋមសិក្សាក្នុងខេត្តតាកែវ»** ដើម្បីសិក្សាឈ្វេងយល់ពីស្ថានភាពការរៀបចំបរិស្ថានសិក្សានៅកម្រិតបឋមសិក្សា ព្រមទាំងរកឱ្យឃើញនូវបញ្ហាប្រឈមនានា និងសំណូមពរក្នុងការរៀបចំបរិស្ថានសិក្សាឱ្យកាន់តែប្រសើរឡើង។

## ៣.១ គម្រោងការស្រាវជ្រាវ

យោងតាមប្រធានបទសិក្សាស្រាវជ្រាវខាងលើនេះ អ្នកស្រាវជ្រាវបានសិក្សាតាមបែបបរិមាណវិស័យ(Quantitative Research) គឺជាដំណើរការនៃការប្រមូល និងវិភាគទិន្នន័យជាលេខ និងជាការពិពណ៌នា(Descriptive Research Design)។ យោងទៅតាម Addle and Clark (2003) បានឱ្យនិយមន័យការស្រាវជ្រាវពិពណ៌នាត្រូវបានបង្កើតឡើងដើម្បីពិពណ៌នាអំពីក្រុម សកម្មភាពផ្សេងៗឬព្រឹត្តិការណ៍ដែលទាក់ទងជាមួយអាកប្បកិរិយា។

យោងតាម Ary, et. Al (2010) និយាយថាការសិក្សាស្រាវជ្រាវពិពណ៌នាបានបង្កើតឡើងដើម្បីទទួលបានព័ត៌មានទាក់ទង និងស្ថានភាពបច្ចុប្បន្ននៃបាតុភូត និងជានីតិវិធីជាក់លាក់សម្រាប់ការប្រមូល

និងវិភាគទិន្នន័យ។យោងទៅតាមរយៈពេលនៃការសិក្សាស្រាវជ្រាវនេះមានកំណត់នាងខ្ញុំបានធ្វើការសិក្សាទាក់ទងជាមួយទស្សនៈរបស់នាយក គ្រូ សិស្ស និងសហគមន៍ ចំពោះបរិស្ថានសិក្សា រកឱ្យឃើញនូវបញ្ហាប្រឈមនានា និងសំណូមពរក្នុងការរៀបចំបរិស្ថានសិក្សា។ ម្យ៉ាងវិញទៀតនាងខ្ញុំបានធ្វើការកំណត់នូវគោលបំណងក្នុងការសិក្សាស្រាវជ្រាវផ្អែកទៅលើបញ្ហាកើតមានជាក់ស្តែងនៅទីតាំងផ្ទាល់តែម្តង។

## ៣.២ ការជ្រើសរើសភាគសំណាក

ចំនួនសំណាកគឺ ជាក្រុមនៃបុគ្គលដែលមានលក្ខណៈដូចគ្នា (Creswell, 2012)។ នៅក្នុងការសិក្សានេះ អ្នកស្រាវជ្រាវបានធ្វើការរើសស្រុកដោយចៃដន្យ(Random) តាមរយៈកម្មវិធី Picker Wheel (https://pickerwheel.com/) ដោយធ្វើការវាយចំនួនស្រុកដក់បញ្ចូលហើយយើងចុចយកតែចំនួន៣ស្រុកក្នុងចំណោមស្រុកទាំង១០ក្នុងខេត្តតាកែវ។

ថែមទាំងមានការជ្រើសរើសសាលាតាមស្រុកនីមួយៗដោយផ្អែកលើ សាលាប្រជុំជន សាលាដាច់ស្រយាល សាលាមានចំនួនសិស្សតិច សាលាមានសិកសស្សច្រើន សាលាមានបរិស្ថានស្អាត។ ទីតាំងទាំង៣ស្រុកគឺ ស្រុកអង្គរបុរី មានសាលាបឋមសិក្សាភ្នំបាទេព និងបឋមសិក្សាហ៊ុនសែនអង្គរបុរី ស្រុកព្រៃកប្បាស មានសាលាបឋមសិក្សាព្រៃល្វា និងសាលាបឋមសិក្សាហ៊ុនសែនបានយ និងស្រុកត្រាំកក់ មានសាលាបឋមសិក្សាអង្គរុន និងសាលាបឋមសិក្សាអង្គតាសោម។

ក្រៅពីនេះ Creswell (2012) និយាយថាគំរូ ឬសំណាក គឺជាក្រុមរងនៃចំនួនគោលដៅ ដែលអ្នកស្រាវជ្រាវគ្រោង នឹងសិក្សាសម្រាប់ការធ្វើជាតំណាង។ អ្នកស្រាវជ្រាវបានធ្វើការជ្រើសរើសក្រុមគោលដៅដែលរួមមានគណៈគ្រប់គ្រង គ្រូ និងសិស្សថ្នាក់ទី៦។ ការសិក្សាស្រាវជ្រាវនេះ បានផ្តោតសំខាន់ទៅលើស្ថានភាពការរៀបចំ ទស្សនៈរបស់នាយក គ្រូ សិស្ស ចំពោះបរិស្ថានសិក្សា និងរកឱ្យឃើញនូវបញ្ហាប្រឈមនានា និងសំណូមពរក្នុងការរៀបចំបរិស្ថានសិក្សា។

១. គណៈគ្រប់គ្រងសាលា៖ សំណាកនៃការសម្ភាសន៍នាយកសាលា ដែលមកមានវត្តមាននៅក្នុងការជ្រើសរើសទំហំសំណាក អ្នកស្រាវជ្រាវបានជ្រើសរើសសំណាកសម្ភាសន៍ដោយប្រើវិធីសាស្ត្រចេតនា

(Purposive Sampling) គឺជាការកំណត់យកតាមរយៈ ការរើសអ្នកតំណាង (Critical case sampling) ដូចនេះចំនួនសំណាកមាន០៦នាក់។

២. គ្រូបង្រៀន៖ ចំពោះគ្រូបង្រៀននៅបឋមសិក្សាទាំង៦ មានចំនួនសរុប ៨០នាក់ ដែលជាគ្រូបង្រៀននៅសាលាបឋមសិក្សាទាំង០៦ខាងលើ(ស្ថិតិនិងសូចនាករអប់រំសាធារណៈ២០២១-២០២២)។ ហេតុនេះអ្នកស្រាវជ្រាវបានកំណត់យកចំនួនគ្រូ ដើម្បីយកមកបំពេញកម្រងសំណួរដោយប្រើវិធីសាស្ត្រ (Purposive Sampling) គឺកំណត់យកសំណាកគ្រូទាំងអស់ដែលបង្រៀននៅតាមសាលានីមួយ(បង្រៀនពីថ្នាក់ទី១ ដល់ថ្នាក់ទី៦)។ មូលហេតុ គឺដោយសារគ្រូគ្រប់កម្រិតថ្នាក់ ការផ្តល់ជាគំនិតយោបល់ ការយល់ឃើញខុសៗគ្នាទៅតាមស្ថានភាពជាក់ស្តែង។

៣ សិស្ស៖ចំពោះសិស្សនៅបឋមសិក្សាភ្នំបាទេព បឋមសិក្សាហ៊ុនសែនអង្គរបុរី បឋមសិក្សាព្រៃល្វា បឋមសិក្សាហ៊ុនសែនបានយ បឋមសិក្សាអង្គរុន បឋមសិក្សាអង្គតាសោម មានចំនួនសរុបចំនួន ៣ ២៥៦នាក់ ស្រីចំនួន ១ ៥៩០នាក់ ពីថ្នាក់ទី១ ដល់ថ្នាក់ទី៦។ សម្រាប់ចំនួនសិស្សនៅកម្រិតថ្នាក់ទី៦ សរុបចំនួន៤៧៧នាក់/ស្រី២៣៦នាក់(ស្ថិតិនិងសូចនាករអប់រំសាធារណៈ២០២១-២០២២)។

ហេតុនេះអ្នកស្រាវជ្រាវបានប្រើវិធីសាស្ត្រ(Purposive Sampling) ក្នុងការកំណត់យកកម្រិតថ្នាក់ទី៦នេះ ព្រោះអាចបំពេញកម្រងសំណួរ និងផ្តល់ចម្លើយបាន។ ហេតុនេះ បានកំណត់យកចំនួនសិស្សយកមកបំពេញកម្រងសំណួរដោយប្រើវិធីសាស្ត្រ គឺកំណត់យកសំណាកទាំងអស់នៃសិស្សថ្នាក់ទី៦។ មូលហេតុដែល អ្នកស្រាវជ្រាវយកចំនួនទាំងអស់ គឺដោយសារអ្នកស្រាវជ្រាវរំពឹងថាលទ្ធផលជឿទុកចិត្តបាន និងតំណាងឱ្យសិស្សនៅក្នុងសាលាទាំងមូលបាន។

៤ សហគមន៍៖ អ្នកស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រ(Purposive sampling) ដើម្បីជ្រើសរើសសំណាកតំណាងឱ្យសហគមន៍ គឺមានចំនួន ១២នាក់ ដែលទាំងនោះត្រូវបំពេញកម្រងសំណួរសម្រាប់សាលាគោលដៅទាំង៦។

តារាង៣.១ *ចំនួនសំណាកនៅ បឋមសិក្សាភ្នំបាទេព បឋមសិក្សាហ៊ុនសែនអង្គរបុរី បឋមសិក្សាហ៊ុនសែនបានយ បឋមសិក្សាព្រៃល្វា បឋមសិក្សាអង្គតាសោម និងបឋមសិក្សាអង្គរុន*

| **តួនាទី** | **ចំនួន** | **ប្រភេទនៃសំណាក** |
|---|---|---|
| គណៈគ្រប់គ្រងសាលា | ០៦ | Critical Case Sampling |
| គ្រូ (ថ្នាក់ទី១ ដល់ទី៦) | ៨០ | Purposive sampling |
| សិស្ស(ថ្នាក់ទី៦) | ៤៧៧ | Purposive sampling |
| សហគមន៍ | ២៤ | Purposive sampling |

ប្រភពៈ ស្ថិតិ និងសូចនាករអប់រំសាធារណៈ(២០២១-២០២២)

ក្នុងការសិក្សាស្រាវជ្រាវប្រធានបទនេះ ចាំបាច់ត្រូវប្រើប្រាស់កម្រងសំណួរ ធ្វើជាឧបករណ៍សម្រាប់សម្ភាសន៍គណៈគ្រប់គ្រងសាលារៀន លោកគ្រូអ្នកគ្រូបង្រៀន និងសិស្ស ក្នុងការប្រមូលទិន្នន័យយកមកវិភាគរកលទ្ធផល។ កម្រងសំណួរនេះបានពិនិត្យកែលម្អ ដោយសាស្ត្រាចារ្យដឹកនាំ ដើម្បីរកឱ្យឃើញពីការយល់ឃើញ បញ្ហាប្រឈមនានា និងសំណូមពរក្នុងការរៀបចំបរិស្ថានសិក្សា។

## ៣.៣ ឧបករណ៍ស្រាវជ្រាវ

ក្នុងការសិក្សានេះ អ្នកស្រាវជ្រាវបានប្រើវិធីសាស្ត្រ (Survey Methods) ដោយប្រើប្រាស់កម្រងសំណួរ (Questionnaires) ជាឧបករណ៍ដែលផ្តោតសំខាន់លើព័ត៌មានជាក់លាក់ពីអ្នកឆ្លើយសំណួរ។ យោងតាម Arikunto (2006) កម្រងសំណួរ គឺជាសំណួរដែលត្រូវបានសរសេរនៅក្នុងក្រដាសដើម្បីទទួលបានព័ត៌មាន និងការឆ្លើយតប។ ហេតុនេះកម្រងសំណួរ គឺជាឧបករណ៍នៃការស្រាវជ្រាវ រៀបចំនូវក្រុមងសំណួរមួយចំនួន មានគោលបំណងជួយអ្នកស្រាវជ្រាវឱ្យទទួលបានទិន្នន័យពីអ្នកឆ្លើយសំណួរ។ យោង Dowson (2002) កម្រងសំណួរមាន3 ប្រភេទគឺៈ សំណួរបិទ សំណួរបើក និងការរួមបញ្ចូលទាំងពីរ។ កម្រងសំណួរបិទ គឺជាប្រភេទនៃកម្រងសំណួរទូទៅ។ ប្រភេទនៃកម្រងសំណួរនេះត្រូវបានប្រើដើម្បីបង្កើតស្ថិតិក្នុងការស្រាវជ្រាវបរិមាណវិស័យ។ ដោយសារកម្រងសំណួរទាំងនេះធ្វើតាមទម្រង់ដែលបានកំណត់ជាក់លាក់ ហើយភាគច្រើនត្រូវបានបញ្ចូលទៅក្នុងកុំព្យូទ័រដើម្បីភាពងាយស្រួលសម្រាប់ការវិភាគជាលេខ។

កម្រងសំណួរបើក គឺជាកម្រងសំណួរមួយប្រភេទត្រូវបានប្រើក្នុងការស្រាវជ្រាវបែបគុណវិស័យទោះបីជាការស្រាវជ្រាវមួយចំនួន កំណត់បរិមាណចម្លើយក្នុងដំណាក់កាលវិភាគទិន្នន័យនីមួយៗក៏ដោយ។ កម្រងសំណួរមិនមានប្រអប់សម្រាប់គូសទេ ប៉ុន្តែផ្ទុយទៅវិញទៀតនោះ ទុកផ្នែកទទេមួយសម្រាប់អ្នកឆ្លើយសំណួរដើម្បីសរសេរចម្លើយ។

ម្យ៉ាងវិញទៀតការរួមបញ្ចូលគ្នានៃទាំងទម្រង់សំណួរបើក និងទម្រង់សំណួរបិទ គឺអ្នកស្រាវជ្រាវជាច្រើនមានទំនោរនឹងប្រើការរួមបញ្ចូលគ្នានៃសំណួរបើក និងបិទ។ កម្រងសំណួរជាច្រើនចាប់ផ្ដើមជាមួយនឹងសំណួរបិទជាបន្តបន្ទាប់ ដែលមានប្រអប់ដើម្បីគូស ឬធ្វើមាត្រដ្ឋានដើម្បីចាត់ថ្នាក់ ហើយបន្ទាប់មកបញ្ចប់ដោយផ្នែកនៃសំណួរបើកចំហសម្រាប់ការឆ្លើយតបលម្អិតបន្ថែមទៀត។

ដូចនេះនៅក្នុងការសិក្សានេះ អ្នកស្រាវជ្រាវបានប្រើការរួមបញ្ចូលគ្នានៃទម្រង់សំណួរបើក និងទម្រង់សំណួរបិទ ព្រោះសំណួរដែលបានផ្ដល់ឱ្យនាយក គ្រូ-សិស្ស និងសហគមន៍ក្នុងការឆ្លើយតបឱ្យបានជាក់លាក់ និងចម្លើយរបស់សិស្សផ្ទាល់។ ដូច្នេះហើយអ្នកស្រាវជ្រាវបានផ្ដល់ឱ្យសិស្សនូវកម្រងសំណួរជាលទ្ធផលអ្នកស្រាវជ្រាវទទួលបានការឆ្លើយតបពីនាយក គ្រូ សិស្ស និងសហគមន៍ចំពោះការយល់ឃើញរបស់ពួកគេយ៉ាងត្រឹមត្រូវ សម្រាប់កម្រងសំណួរទាំងអស់ត្រូវបានផ្ដល់ជូនក្នុង២បសម្ព័ន្ធ។ នៅក្នុងកម្រងសំណួរនេះមាននិយាយពីព័ត៌មានប្រជាសាស្ត្រ សាលា ភេទ អាយុ កម្រិតវប្បធម៌ តួនាទី ជនជាតិជាដើម និងមាន៣ផ្នែកសំខាន់ៗគឺ៖

-ផ្នែកទី១៖ និយាយពីបរិស្ថានសិក្សានៅសាលាបឋមសិក្សាមានលក្ខណៈយ៉ាងដូចម្ដេច?

-ផ្នែកទី២៖ តើការរៀបចំបរិស្ថានសិក្សា កំពង់ជួបបញ្ហាប្រឈមអ្វីខ្លះ?

-ផ្នែកទី៣៖ ការឆ្លើយតបដំណោះស្រាយ និងសំណូមពរនៅក្នុងការរៀបចំបរិស្ថានសិក្សា។

ក្នុងនោះផងដែរការបង្កើតកម្រងសំណួរក្នុងផ្នែកទី១ និងទី២ គឺអ្នកស្រាវជ្រាវបានបង្កើតដោយដកស្រង់ចំណុចសំខាន់ពីសូចនាករគោល និងលក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃសាលាស្អាតរបស់ក្រសួងអប់រំ យុវជន និងកីឡា (២០១៨) ដោយប្រើជាទម្រង់សំណួរបិទដែលមានមាត្រដ្ឋាន៥ គឺ យល់ស្របទាំងស្រុង មិនយល់ស្រប គ្មានយោបល់ យល្រ់សប និងយល់ស្របទាំងស្រុង។

ចំពោះផ្នែកទី៣ អ្នកស្រាវជ្រាវបានបង្កើតជាទម្រង់សំណួរបើក ដើម្បីឱ្យអ្នកចូលរួមបានធ្វើការបញ្ចេញជាមតិយល់រៀងៗខ្លួនទៅលើដំណោះស្រាយ បញ្ហាប្រឈម និងសំណូមពរ។

## ៣.៤ ការប្រមូលទិន្នន័យ

ទិន្នន័យ គឺជាព័ត៌មានទាំងឡាយណាដែលអ្នកស្រាវជ្រាវប្រមូលសម្រាប់គោលបំណងនៃការឆ្លើយសំណួរស្រាវជ្រាវរបស់ខ្លួន ហើយប្រភេទទិន្នន័យដែលអ្នកស្រាវជ្រាវត្រូវការអាស្រ័យលើគោលបំណងនៃការស្រាវជ្រាវ។ ដូច្នេះទិន្នន័យនៃការសិក្សាស្រាវជ្រាវនេះត្រូវបានប្រមូលចេញពី ការបំពេញកម្រងសំណួរ (Questionaries)។ យោង Spaulding and Voegtle (2010) ការប្រមូលទិន្នន័យ និងការវិភាគសម្រាប់ការស្រាវជ្រាវបរិមាណវិស័យគឺ ជាដំណើរការពីភាពជាក់លាក់ទៅជាភាពទូទៅ(inductive processes)។ នៅក្នុងការសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានប្រមូលទិន្នន័យពីរប្រភេទ គឺការប្រមូលទិន្នន័យបឋម និងទិន្នន័យបន្ទាប់បន្សំ។

**ក.ការប្រមូលទិន្នន័យបឋម៖** ប្រភពទិន្នន័យបឋម គឺជាអ្វីៗដែលផ្តល់ឱ្យអ្នកស្រាវជ្រាវនូវភស្តុតាងដោយផ្ទាល់អំពីមនុស្ស ព្រឹត្តិការណ៍ឬបាតុភូត ដែលកំពុងស្រាវជ្រាវ និងក្លាយជាវត្ថុសំខាន់នៃការវិភាគរបស់អ្នកស្រាវជ្រាវ។ ចំពោះការចុះប្រមូលទិន្នន័យ អ្នកសិក្សាស្រាវជ្រាវបានជ្រើសរើសយក នាយក គ្រូ-សិស្ស និងសហគមន៍ ជាគោលដៅសម្រាប់ធ្វើការបំពេញកម្រងសំណួរ។ ដោយឱ្យពួកគាត់ផ្តល់ព័ត៌មានត្រឡប់មកវិញ ជុំវិញការយល់ឃើញរបស់គាត់ចំពោះការរៀបចំបរិស្ថានសិក្សានៅតាមសាលានីមួយៗ តាមរយៈការផ្តល់កម្រងសំណួរដោយផ្ទាល់ទៅកាន់អ្នកចូលរួមដើម្បីធ្វើការបំពេញកម្រងសំណួរ។ ដែលជាវិធីមួយក្នុងការដឹងពីស្ថានភាពទូទៅនៃសាលាបឋមសិក្សាទាំង៦គឺ សាលាបឋមសិក្សាភ្នំបាទេព បឋមសិក្សាហ៊ុនសែនអង្គរបុរី បឋមសិក្សាហ៊ុនសែនបានយ បឋមសិក្សាព្រៃល្វា បឋមសិក្សាអង្គតាសោម និងបឋមសិក្សាអង្គរុន ដែលពាក់ព័ន្ធលើការរៀបចំ និងស្ថានភាពបរិស្ថានសិក្សា។

វិធីសាស្ត្រក្នុងការជ្រើសរើសសំណាកចូលរួមមានដូចតទៅ៖

គណៈគ្រប់គ្រងសាលា៖ ដោយប្រើវិធីសាស្ត្រ (Purposive Sampling) ជ្រើសរើសដោយមានគោលបំណង ដោយរើសតាមនីតិវិធី(Critical Sampling) ព្រោះគណៈគ្រប់គ្រង ជាជនបង្គោលមួយរូបក្នុង

សាលាដែលអាចផ្តល់ព័ត៌មានបានលម្អិត។ ដោយពេលវេលាមានកំណត់ ចំនួនសំណាកច្រើន និងទីតាំងសាលាឆ្ងាយៗ ជាពិសេសមានការស្នើសុំពីនាយកផ្ទាល់(តែនាយកមួយបានហើយ ចម្លើយដូចតែគ្នា រវល់ការងារជាដើម) ហេតុនេះបានតែនាយកចូលរួមក្នុងការឆ្លើយមិនបានគណៈគ្រប់គ្រងទាំងអស់។ បន្ទាប់មកអ្នកស្រាវជ្រាវបានធ្វើការជួបសម្ភាសន៍ជាមួយនាយក ដើម្បីដឹងពីស្ថានភាពនៃការរៀបចំបរិស្ថានសិក្សា ដឹងពីរបៀប និងដំណើរការក្នុងការរៀបចំ ថែរក្សាបរិស្ថានសិក្សា។

គ្រូ-សិស្ស៖ ប្រើប្រាស់វិធីសាស្ត្រ (Purposive Sampling) គឺជាវិធីសាស្ត្រជ្រើសរើសដោយគោលបំណងជាក់លាក់ដែលប្រើដើម្បីជ្រើសរើសសំណាកគ្រូ នៅតាមសាលានីមួយៗចាប់ពីថ្នាក់ទី១ ដល់ទី៦ ដើម្បីបង្ហាញពីការយល់ឃើញចំពោះបរិស្ថានសិក្សា។ ចំពោះសិស្ស អ្នកស្រាវជ្រាវបានកំណត់យកតែមួយកម្រិត គឺថ្នាក់ទី៦ព្រោះអាចអានសំណួរ និងផ្តល់ចម្លើយបាន។

សហគមន៍៖អ្នកស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រ (Purposive sampling) ដើម្បីជ្រើសរើសសំណាកដែលត្រូវបំពេញកម្រងសំណួរសម្រាប់សាលាគោលដៅទាំង៦ ដែលជាគណៈកម្មការតាមសាលាក្នុងការបំពេញកម្រងសំណួរនេះ។

**ខ.ការប្រមូលទិន្នន័យបន្ទាប់បន្សំ៖** គឺជាអ្វីៗដែលបានពិពណ៌នា និង បកស្រាយ វាយតម្លៃ ឬវិភាគព័ត៌មានពីប្រភពចម្បង។ ឧទាហរណ៍ទូទៅរួមមាន សៀវភៅ ឯកសារតាមប្រព័ន្ធអ៊ិនធឺណែត គេហទំព័រឬវេបសាយ និងស្ថាប័ននានាជាដើម។ ហេតុដូចនេះប្រភពទិន្នន័យបឋមគឺ មានភាពជឿជាក់ ជាភស្តុតាង ប៉ុន្តែប្រភពទិន្នន័យបន្ទាប់បន្សំបង្ហាញពីរបៀបដែលទាក់ទងនឹងការស្រាវជ្រាវដែលមានស្រាប់។ ក្នុងនោះផងដែរអ្នកស្រាវជ្រាវបានដកស្រង់ចេញពីឯកសារសារណាផ្សេងៗ សៀវភៅតាមបណ្ណាល័យ និងព្រមទាំងអ៊ិនធឺណែត ជាពិសេសឯកសារពីក្រសួងអប់រំ។

ទិន្នន័យនៃការសិក្សានេះត្រូវបានប្រមូលដោយផ្អែកលើជំហានដូចខាងក្រោម៖

1. សុំការអនុញ្ញាតពីនាយកសាលា បាននាំយកលិខិតអនុញ្ញាតស្រាវជ្រាវពីវិទ្យាស្ថានជាតិអប់រំ
2. ការណាត់ជួបជាមួយនាយក គ្រូ សិស្ស និងសហគមន៍ដើម្បីធ្វើការណែនាំពីការស្រាវជ្រាវ។
3. អ្នកស្រាវជ្រាវបានរៀបចំកម្រងសំណួរទាក់ទងនឹងសេចក្តីថ្លែងការណ៍បញ្ហានៃការស្រាវជ្រាវ។

4. បង្កើតបញ្ជីកម្រងសំណួរដើម្បីធ្វើឱ្យនាយក គ្រូ សិស្ស និងសហគមន៍ឆ្លើយយ៉ាងងាយស្រួល។

5. បានចែកកម្រងសំណួរដល់ជនបង្គោលទាំងអស់ សុំឱ្យឆ្លើយឱ្យបានត្រឹមត្រូវ និងស្មោះត្រង់។

6. បានស្រង់មតិដើម្បីដឹងពីស្ថានភាព បញ្ហាប្រឈម និងសំណូមពរក្នុងការរៀបចំបរិស្ថានសិក្សា។

7. អ្នកស្រាវជ្រាវបានប្រមូលទិន្នន័យពីកម្រងសំណួរ

8. អ្នកស្រាវជ្រាវបានដំណើរការប្រកពទិន្នន័យពីការស្រាវជ្រាវរបស់គាត់ដោយប្រើការពិពណ៌នាទូទៅ និងការសន្និដ្ឋាន។

## ៣.៥ ការវិភាគទិន្នន័យ

ការវិភាគទិន្នន័យ គឺជាជំហានចុងក្រោយក្នុងការប្រមូលទិន្នន័យ នៃការសិក្សាស្រាវជ្រាវ។ ដូចដែលបានបញ្ជាក់ដោយ Ary, et.al (2010) ការវិភាគទិន្នន័យសំដៅទៅលើដំណើរការ និងដោយមានការបកស្រាយទិន្នន័យដែលពាក់ព័ន្ធនឹងដំណាក់កាលជាច្រើនដូចជា ការរៀបចំ ការស្គាល់ ការសរសេរកូដ ការកាត់បន្ថយ ការបកស្រាយ និងការតំណាង។

ហេតុនេះបន្ទាប់ពីធ្វើការប្រមូលទិន្នន័យ អ្នកស្រាវជ្រាវបានធ្វើការវិភាគទិន្នន័យពីការបំពេញកម្រងសំណួរ ដោយប្រើប្រាស់វិធីសាស្ត្រវិភាគតាមបែបស្ថិតិពណ៌នា (Descriptive Statistics) រកតម្លៃមធ្យម (M) តម្លៃគម្លាតស្តង់ដារ (SD) ដើម្បីឆ្លើយសំណួរស្រាវជ្រាវ។ បន្ទាប់មកអ្នកស្រាវជ្រាវប្រើប្រាស់កម្មវិធី Ms. Excel ដើម្បីសង់ក្រាហ្វិក ដ្យាក្រាម ដែលបានទិន្នន័យពីកម្មវិធី SPSS និងប្រើប្រាស់កម្មវិធី Microsoft Word ក្នុងការបកស្រាយលើក្រាហ្វិក តារាង ដោយធ្វើការសរសេរជារបាយការណ៍នៅក្នុងការវិភាគទិន្នន័យនេះ។

អាស្រ័យហេតុនេះអ្នកស្រាវជ្រាវបានប្រើមាត្រដ្ឋាន Likert Scale សម្រាប់វិភាគទិន្នន័យ។ មាត្រដ្ឋាន Likert Scale គឺជាមាត្រដ្ឋានមួយក្នុងចំណោមមាត្រដ្ឋានផ្សេងៗ ដែលមានគោលបំណងដើម្បីទទួលបានចម្លើយនៃការស្រាវជ្រាវពីអ្នកឆ្លើយសំណួរដូចជា ការមិនយល់ស្របទាំងស្រុង មិនយល់ស្របគ្មានយោបល់ យល់ស្រប និងយល់ស្របទាំងស្រុងដែលមាននៅក្នុងកម្រងសំណួរ។ ជាលទ្ធផល នៃមាត្រដ្ឋានតំណភ្ជាប់ អ្នកស្រាវជ្រាវបានប្រើការស្រាវជ្រាវបែបបរិមាណ ដើម្បីរាប់ភាគរយនៃបញ្ហាប្រឈម

និងសំណូមពរក្នុងការរៀបចំបរិស្ថានសិក្សា។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការសិក្សានេះអ្នកស្រាវជ្រាវបានកែប្រែជំហានមួយចំនួនដែលសមស្របនឹងបញ្ហាស្រាវជ្រាវនិងការរចនាស្រាវជ្រាវ។ UJIABUDULA, (2019) ចំពោះការបកស្រាយទិន្នន័យគឺ ផ្អែកតាមមធ្យមនៃកម្រិតពិន្ទុពី

១.០០ ដល់ ២.៤៩ កម្រិតទាប

២.៥០ ដល់ ៣.៤៩ កម្រិតមធ្យម

៣.៥០ ដល់ ៥.០០ កម្រិតខ្ពស់។

សរុបជារួមបន្ទាប់ពីទទួលបានទិន្នន័យ អ្នកស្រាវជ្រាវបានធ្វើការសិក្សាដោយប្រើប្រាស់នូវកម្មវិធី Microsoft Excel2010 និង SPSS (version 28) ក្នុងការរៀបចំទិន្នន័យដើម្បីយកមកធ្វើការវិភាគទទួលបានលទ្ធផល និងការពិភាក្សាចុងបញ្ចប់ ធ្វើសេចក្តីសន្និដ្ឋាន និងផ្តល់ជាអនុសាសន៍។

## ៣.៦ ក្រមសីលធម៌នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះធ្វើឡើងទៅបាន ដោយមានការស្នើរសុំការអនុញ្ញាតពីគណៈគ្រប់គ្រងសាលាទាំងអស់ និងមិនបង្កហានិភ័យដល់តំណាងគំរូ។ ម្យ៉ាងវិញទៀតការសិក្សាស្រាវជ្រាវនេះមានស្តង់ដាប្រកបដោយក្រមសីលធម៌ស្រាវជ្រាវដូចជាការរក្សាទំនុកចិត្ត ការរក្សាការសម្ងាត់ ដោយមិនបង្ហាញឈ្មោះអ្នកចូលរួមបំពេញកម្រងសំណួរ (ដាក់ជាលេខកូដតំណាង) ដូចនេះរាល់អ្នកចូលរួមទាំងអស់ នឹងត្រូវបានសុំការអនុញ្ញាតជាមុន។ សម្រាប់អ្នកចូលរួមសម្ភាសន៍គ្រប់រូបទាំងអស់មានសិទ្ធិរំលងសំណួរណាមួយខ្លួនមិនចង់ឆ្លើយបានគ្រប់ពេលវេលា។

ហេតុនេះការសិក្សាស្រាវជ្រាវនេះនឹងដាក់បញ្ចូលនូវសេចក្តីណែនាំផ្សេងៗ ដែលមានបង្ហាញពីគោលបំណងមុននឹងចាប់ផ្តើមឆ្លើយសំណួរនៅខាងលើលិខិតកម្រងសំណួរនីមួយៗ ដូច្នេះរាល់ពត៌មានដែលទទួលបានរក្សាជាការសម្ងាត់ និងរក្សានូវសុវត្ថិភាព។



រូបភាព ៣.១៖ រៀបរៀងដោយ និស្សិត លឿង កុសល ( សង្ខេបពីខ្លឹមសារជំពូកទី៣ )

# ជំពូក ៤

# លទ្ធផល និងការពិភាក្សា

# ជំពូក ៤

# លទ្ធផល និងការពិភាក្សា

## ៤.១ លទ្ធផល

### ៤.១.១ សេចក្តីផ្តើម

ក្នុងជំពូកនេះអ្នកស្រាវជ្រាវនឹងធ្វើការបង្ហាញ បកស្រាយ និងពិភាក្សាលទ្ធផលនៃការវិភាគទិន្នន័យ បានមកពីការបំពេញកម្រងសំណួរពីសំណាក់ គណៈគ្រប់គ្រង លោកគ្រូ អ្នកគ្រូ សិស្ស និងសហគមន៍ ដើម្បីឱ្យដឹងថាតើនៅកម្រិតបឋមសិក្សា ក្នុងស្រុកអង្គរបុរី ស្រុកព្រៃកប្បាស និងស្រុកត្រាំកក់ នៃខេត្តតាកែវ មានការយល់ឃើញបែបណាចំពោះបរិស្ថានសិក្សាហើយដើម្បីឱ្យដឹងថា តើអ្វីខ្លះជាបញ្ហាប្រឈមនៅក្នុងការរៀបចំបរិស្ថានសិក្សានាពេលបច្ចុប្បន្ន ។

### ៤.១.២ ព័ត៌មានទូទៅប្រជាសាស្ត្រ

### ក. ចំនួនសាលាដែលចូលរួម

ក្នុងការសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានធ្វើការកំណត់យកសាលាបឋមសិក្សាចំនួន៦ ក្នុងស្រុកអង្គរបុរី ស្រុកព្រៃកប្បាស និងស្រុកត្រាំកក់នៃខេត្តតាកែវ ជាគោលដៅនៃការសិក្សាស្រាវជ្រាវ ដោយយកសិស្សកម្រិតថ្នាក់ទី៦។ ដោយហេតុជា សាលាទាំងនោះជាសាលាដែលមានចំនួនសិស្សតិច មធ្យម ច្រើន តំបន់ជួបការលំបាក និងតំបន់ប្រជុំជន។ ចំពោះសិស្សថ្នាក់ទី៦វិញ អ្នកសិក្សាបានកំណត់យកដោយគោលបំណង ព្រោះអាចបំពេញកម្រងសំណួរបាន យល់ពីខ្លឹមសារ និងអាចផ្តល់ព័ត៌មានបានយ៉ាងលំអិត។ ជាលទ្ធផលបានបង្ហាញថាសាលាបឋមសិក្សាភ្នំបាទេពចំនួន ៣.៧% សាលាបឋមសិក្សាហ៊ុនសែនអង្គរបុរីមានចំនួន ២៦.៧% បឋមសិក្សាហ៊ុនសែនបានយចំនួន ២៤.៧% សាលាបឋមសិក្សាព្រៃល្វាចំនួន ១៤.៥% បឋមសិក្សាអង្គតាសោមចំនួន១៧.៦% និងបឋមសិក្សាអង្គរុនចំនួន១២.៧%។

ក្រាហ្វិកទី១ ចំនួនសាលាដែលចូលរួម




## ខ. ចំនួនអ្នកចូលរួម

*តារាង២ ចំនួនគណគ្រប់គ្រង គ្រូ សិស្ស សហគមន៍ដែលបានចូលរួមក្នុងការបំពេញកម្រងសំណួរ*

| អ្នកឆ្លើយតប | ចំនួនសំណាក | ភាគរយ% |
|---|---|---|
| គណៈគ្រប់គ្រង | ៦ | ១.២ |
| គ្រូ | ៦៧ | ១៣.១ |
| សិស្ស | ៤២០ | ៨២.៤ |
| សហគមន៍ | ១៧ | ៣.៣ |
| សរុប | ៥១០ | ១០០% |

តាមរយៈតារាងខាងលើអ្នកស្រាវជ្រាវសង្កេតឃើញថា ទំហំភាគសំណាកមានការប្រែប្រួលខុសពីផែនការបានដាក់ចេញ។ នៅក្នុងផ្នែកវិធីសាស្ត្រស្រាវជ្រាវចំនួនសិស្សថ្នាក់ទី៦ចំនួន៤៧៧ គ្រូចំនួន៨០ សហគមន៍ចំនួន២៤នាក់ ដែលសរុបទាំងអស់ ៥៨៧នាក់ ដែលអ្នកស្រាវជ្រាវបានកំណត់ចំនួនអ្នកចូលរួមដោយគោលបំណងដាក់លាក់។ ជាក់ស្តែងអ្នកចូលរួមបំពេញកម្រងសំណួរមានចំនួន៥១០នាក់ ដែលយកមកធ្វើការស្រាវជ្រាវឃើញថា គណៈគ្រប់គ្រងចំនួន៦នាក់ គ្រូ៦៧នាក់ សិស្ស៤២០នាក់ និងសហគមន៍

ចំនួន១៧នាក់។ ដោយមូលហេតុអ្នកចូលរួមមួយចំនួនដូចជា លោកគ្រូ អ្នកគ្រូ សិស្ស និងសហគមន៍ មានធុរៈផ្ទាល់ខ្លួនមិនបានចូលរួមបំពេញកម្រងសំណួរ។

### ៤.១.៣ ស្ថានភាពនៃការរៀបចំបរិស្ថានសិក្សានៅកម្រិតបឋមសិក្សា

#### *៤.១.៣.១ អត្តសញ្ញាណជាតិ និងវិន័យ*

តារាង៤.១.៣.១ បានបង្ហាញឱ្យឃើញថា ការរៀបចំតុបតែងថ្នាក់រៀននូវសម្ភារៈបង្ហាញវប្បធម៌និងប្រពៃណីជាតិខ្មែរ និងការដាក់រូបព្រះឆាយាលក្ខណ៍របស់ព្រះមហាក្សត្រ មានការយល់ស្របច្រើន បន្ទាប់មកការដាក់បាវចនាជាតិនៅក្នុងថ្នាក់រៀននីមួយៗ។ ចំពោះការណែនាំអប់រំ និងការដាក់ពិន័យសិស្សដែលមិនគោរពវិន័យសាលារៀន ការពិន័យចំពោះអ្នកចោលសំរាមនៅក្នុងទីធ្លាសាលារៀនក៏មានលក្ខណៈល្អប្រសើរដែរដែលមានមធ្យមភាគកម្រិតខ្ពស់។ ដែលបញ្ជាក់ឱ្យឃើញថា តាមសាលានីមួយៗមានការយកចិត្តទុកដាក់ចំពោះការរៀបចំបរិស្ថានសិក្សា និងមានការអនុវត្តផងដែរ។

តារាង៤.១.៣.១*អត្តសញ្ញាណជាតិ និងវិន័យ*

| បរិយាយ | ចំនួនអ្នកឆ្លើយសំណួរតាមកម្រិត | | | | | | |
|---|---|---|---|---|---|---|---|
| | | | 1 | 2 | 3 | 4 | 5 |
| | មធ្យម | គម្លាតស្តង់ដារ | SD | D | N | A | SA |
| ៦.ការដាក់បាវចនាជាតិនៅក្នុងថ្នាក់រៀននីមួយៗ | 4.13 | .78 | 0.8 | 5.3 | 4.1 | 59.4 | 30.4 |
| ៧.ការរៀបចំតុបតែងថ្នាក់រៀននូវសម្ភារៈបង្ហាញវប្បធម៌និងប្រពៃណីជាតិខ្មែរ និងការដាក់រូបព្រះឆាយាលក្ខណ៍របស់ព្រះមហាក្សត្រ | 4.14 | .73 | 0.6 | 2.9 | 1.8 | 70.8 | 23.9 |
| ៨.ការណែនាំអប់រំ និងការដាក់ពិន័យសិស្សដែលមិនគោរពវិន័យសាលារៀន | 4.03 | .61 | 1.6 | 1.8 | 2.4 | 80.0 | 14.3 |
| ៩.ការពិន័យចំពោះអ្នកចោលសំរាមនៅក្នុងទីធ្លាសាលារៀន | 4.03 | .60 | 0.4 | 3.7 | 2.9 | 77.6 | 15.3 |

ចំណាំ៖1=SD មិនយល់ស្របសោះ 2=D មិនយល់ស្រប 3=Nគ្មានយោបល់ 4=Aយល់ស្រប 5=SAយល់ស្របទាំងអស់

១.០០ ដល់ ២.៤៩ កម្រិតទាប ២.៥០ ដល់ ៣.៤៩ កម្រិតមធ្យម ៣.៥០ ដល់ ៥.០០ កម្រិតខ្ពស់

### ៤.១.៣.២. ការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន និងភាពស្អាត

ក្រាហ្វិក៤.១.៣.២ ដែលលទ្ធផលសិក្សាបានបង្ហាញថានៅតាមសាលាបឋមសិក្សានីមួយៗមានការណែនាំសិស្សានុសិស្សឱ្យចេះទុកដាក់សំរាមក្នុងធុងសំរាមមិនបោះចោលពាសវាលពាសកាល និងមានការណែនាំដល់អ្នកលក់នំចំណីអាហារក្នុងសាលារៀនអំពីអនាម័យ ចំណីអាហារ និងភាពស្អាត (៣០.២%) ថែមទាំងមានការណែនាំពីភាពស្អាតនៅក្នុងថ្នាក់រៀន និងការដឹកនាំសិស្សានុសិស្សចុះសម្អាតបរិស្ថាននៅក្នុងបរិវេណសាលារៀន(២៩.៤%) ក្រៅពីនោះក៏មានការរៀបចំគំនូរ ឬរូបភាពផ្សេងៗបង្ហាញពីការអប់រំពីបរិស្ថាន ការថែរក្សា និងការសម្អាតនៅក្នុងបន្ទប់សិក្សា។

ម្យ៉ាងវិញទៀត មានការអានជារឿងនិទានអប់រំពីបរិស្ថានឱ្យសិស្សានុសិស្សស្តាប់នៅក្នុងម៉ោងបង្រៀន និងក្នុងបន្ទប់រៀន និងការចែកជូនឯកសារអប់រំនានាទាក់ទង នឹងបរិស្ថានដល់សិស្សានុសិស្សហាក់នៅពុំទាន់មានភាពសំបូរបែបនៅឡើយ។

ហេតុនេះតាមសាលាបឋមសិក្សានីមួយៗ មានការរៀបទៅតាមចំណុចដែលមាននៅក្នុងរង្វាយតម្លៃផ្នែកការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន និងភាពស្អាតពិតប្រាកដមែន។ ដែលបញ្ជាក់ឱ្យឃើញថា តាមសាលារៀននីមួយៗមានការអនុវត្តទៅគោលការណ៍សាលារៀនស្អាតប្រាកដមែន។ ជាពិសេសមានការណែនាំដល់អ្នកលក់នំចំណីអាហារក្នុងសាលារៀនអំពីអនាម័យ ចំណីអាហារ និងភាពស្អាតស្របទៅតាមគោលការណ៍របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីភាពសុខភាពសិក្សារបស់សិស្សនិស្សិត។

**សំគាល់៖**

A10. ការរៀបចំគំនូរ ឬរូបភាពផ្សេងៗបង្ហាញពីការអប់រំពីបរិស្ថាន ការថែរក្សា និងការសម្អាតនៅក្នុងបន្ទប់សិក្សា

A11.ការណែនាំពីភាពស្អាតនៅក្នុងថ្នាក់រៀន និងការដឹកនាំសិស្សានុសិស្សសម្អាតបរិស្ថាននៅក្នុងបរិវេណសាលារៀន

A12.ការណែនាំសិស្សានុសិស្សឱ្យចេះទុកដាក់សំរាមក្នុងធុងសំរាមមិនបោះចោលពាសវាលពាសកាល

A13. ការណែនាំដល់អ្នកលក់នំចំណីអាហារក្នុងសាលារៀនអំពីអនាម័យ ចំណីអាហារ និងភាពស្អាត

A14. ការអានជារឿងនិទានអប់រំ ពីបរិស្ថានឱ្យសិស្សានុសិស្សស្តាប់នៅក្នុងម៉ោងបង្រៀន និងក្នុងបន្ទប់រៀន

A15. ការចែកជូនឯកសារអប់រំទាក់ទង នឹងបរិស្ថានដល់សិស្សានុសិស្ស

ក្រាហ្វិក៤.១.៣.២. *ការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន និងភាពស្អាត*




| | A10 | | A11 | | A12 | | A13 | | A14 | | A15 | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| មិនយល់ស្របទាំងស្រុង | 7 | 1.4% | 1 | 0.2% | 8 | 1.6% | 4 | 0.8% | 7 | 1.4% | 5 | 1.0% |
| មិនយល់ស្រប | 15 | 2.9% | 2 | 0.4% | 10 | 2.0% | 10 | 2.0% | 70 | 13.7% | 41 | 8.0% |
| គ្មានយោបល់ | 15 | 2.9% | 9 | 1.8% | 14 | 2.7% | 24 | 4.7% | 48 | 9.4% | 48 | 9.4% |
| យល់ស្រប | 342 | 67.1% | 348 | 68.2% | 324 | 63.5% | 318 | 62.4% | 326 | 63.9% | 367 | 72.0% |
| យល់ស្របទាំងស្រុង | 131 | 25.7% | 150 | 29.4% | 154 | 30.2% | 154 | 30.2% | 59 | 11.6% | 49 | 9.6% |

### *៤.១.៣.៣.ភាពស្អាតនៅក្នុងបរិវេណសាលា បន្ទប់ បង្គន់ អនាម័យ និងភាពបៃតង*

លទ្ធផលក្នុងតារាង៤.១.៣.៣ បានបញ្ជាក់ឱ្យឃើញថាបន្ទប់រៀនមានសោភ័ណភាពនិងរៀបចំតុបតែងបានស្អាត និងសម្អាតប្រចាំ ដែលមានមធ្យមភាគ (៤.១៥) ថែមទាំងមានទឹកស្អាតគ្រប់គ្រាន់សម្រាប់ប្រើប្រាស់នៅក្នុងបង្គន់អនាម័យ និងមានការថែរក្សាបរិស្ថាននៅក្នុងបរិវេណសាលារៀនបានស្អាតល្អ។ ម្យ៉ាងទៀតទីធ្លាសាលាមានសណ្តាប់ធ្នាប់ល្អគ្មានសំរាមពាសវាលពាសកាល ថែមទាំងមានធុងសំរាមគ្រប់គ្រាន់សម្រាប់ឱ្យសិស្សានុសិស្សដាក់សំរាមផងដែរ។ តាមសាលានីមួយៗមានការដាំដើមឈើ ផ្តល់ម្លប់ និងដើមផ្កានៅបរិវេណខាងក្រៅ/ក្នុងទីធ្លាសាលា បង្គន់អនាម័យត្រូវមានគន្លឹះទ្វារត្រឹមត្រូវ និងមានធុងសំរាមនៅតាមបង្គន់នីមួយៗ និងមានការបែងចែកបង្គន់បុរស នារី និងបង្គន់សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្ស ដែលមានភាពងាយស្រួលសម្រាប់ប្រើប្រាស់ និងមានកន្លែងលាងដៃក្រោយចេញពីបង្គន់ និងកន្សែងឬក្រដាស់សម្រាប់ជូតដៃ។

លើសពីនេះមានការរៀបចំសួនផ្កា និងសួនបន្លែដើម្បីឱ្យកាន់តែមានភាពទាក់ទាញបន្ថែមនៅក្នុងបរិវេណសាលារៀន និងការចតយានជំនិះគ្រប់ប្រភេទក្នុងបរិវេណសាលារៀនមានសណ្តាប់ធ្នាប់ ការរៀបចំ

សួនផ្កាលម្អ ការដាំកូនឈើ ដើមឈើហូមផ្លែឬប្រភេទផ្កាដើមធំ បានស្អាត និងត្រឹមត្រូវមានសោភ័ណភាពល្អ និងមានការថែទាំជាប្រចាំ។

ទន្ទឹមនឹងនោះ ការតុបតែងលម្អដើមរុក្ខជាតិតូចៗ ឬផ្កាផ្សេងៗតាមជញ្ជាំង ឬក្នុងបន្ទប់រៀន (រុក្ខជាតិតូចៗ)ដាំនៅក្នុងបំពង់ឫស្សី ឬក្នុងដបទឹកសុទ្ធជាដើមនៅមានកម្រិតនៅឡើយ។

តារាង៤.១.៣.៣ *ភាពស្អាតនៅក្នុងបរិវេណសាលា បន្ទប់រៀន បង្គន់ អនាម័យ និងភាពបៃតង*

| បរិយាយ | ចំនួនអ្នកឆ្លើយសំណួរតាមកម្រិត | | | | | | |
|---|---|---|---|---|---|---|---|
| | | | 1 | 2 | 3 | 4 | 5 |
| | មធ្យម | គម្លាតស្តង់ដារ | SD | D | N | A | SA |
| ១៦. ទីធ្លាសាលាត្រូវមានសណ្តាប់ធ្នាប់ល្អគ្មានសំរាមពាសវាលពាសកាល | 4.10 | .70 | 0.6 | 4.1 | 3.9 | 67.1 | 24.3 |
| ១៧. ធុងសំរាមគ្រប់គ្រាន់សម្រាប់ឱ្យសិស្សានុសិស្សដាក់សំរាម | 4.07 | .70 | 1.2 | 2.7 | 6.3 | 67.1 | 22.7 |
| ១៨. ការចតយានជំនិះគ្រប់ប្រភេទក្នុងបរិវេណសាលារៀនមានសណ្តាប់ធ្នាប់ | 3.80 | .88 | 2.7 | 9.6 | 5.7 | 68.0 | 13.9 |
| ១៩. បន្ទប់រៀនមានសោភ័ណភាព និងរៀបចំតុបតែងបានស្អាត និងសម្អាតប្រចាំ | 4.15 | .68 | 1.6 | 2.0 | 1.8 | 68.6 | 26.1 |
| ២០. ការបែងចែកបង្គន់បុរស នារី និងបង្គន់សម្រាប់លោកគ្រូ អ្នកគ្រូ និងសិស្ស | 4.10 | .67 | 0.8 | 2.2 | 6.7 | 66.9 | 23.5 |
| ២១. បង្គន់មានអនាម័យ និងគ្មានក្លិនមិនល្អព្រមទាំងមានការសម្អាតជាប្រចាំ | 3.92 | .79 | 1.6 | 6.7 | 6.3 | 69.0 | 16.5 |
| ២២. កន្លែងលាងដៃក្រោយចេញពីបង្គន់ និងកន្សែង ឬក្រដាស់សម្រាប់ជូតដៃ | 3.75 | .88 | 1.6 | 12.5 | 7.6 | 65.5 | 12.7 |
| ២៣. បង្គន់អនាម័យ ត្រូវមានគន្លឹះទ្វារត្រឹមត្រូវ ធុងសំរាមមាននៅតាមបង្គន់នីមួយៗ | 3.95 | .88 | 2.2 | 8.0 | 4.5 | 62.5 | 22.7 |
| ២៤.ទឹកស្អាតមានគ្រប់គ្រាន់សម្រាប់ប្រើប្រាស់នៅក្នុងបង្គន់អនាម័យ | 4.13 | .60 | 0.4 | 2.4 | 2.9 | 72.0 | 22.4 |
| ២៥.ការថែរក្សាបរិស្ថាននៅក្នុងបរិវេណសាលារៀន បានស្អាតល្អ | 4.12 | .66 | 0.8 | 2.9 | 2.5 | 69.6 | 24.1 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២៦.ការរៀបចំសួនផ្កា និងសួនបន្លែដើម្បីឱ្យកាន់តែមានភាពទាក់ទាញបន្ថែមនៅក្នុងបរិវេណសាលារៀន | 3.93 | .76 | 1.4 | 5.7 | 7.5 | 68.8 | 16.7 |
| ២៧.ការដាំដើមឈើផ្តល់ម្លប់ និងដើមផ្កានៅបរិវេណខាងក្រៅ/ក្នុងទីធ្លាសាលា | 3.99 | .77 | 0.8 | 6.3 | 6.3 | 65.7 | 21.0 |
| ២៨.ការតុបតែងលម្អដើមរុក្ខជាតិតូចៗ ឬផ្កាផ្សេងៗតាមជញ្ជាំង ឬក្នុងបន្ទប់រៀន(រុក្ខជាតិតូចៗ)ដែលដាំនៅក្នុងបំពង់ឫស្សី ឬក្នុងដបទឹកសុទ្ធជាដើម | 3.72 | .94 | 1.8 | 12.7 | 13.7 | 55.1 | 16.7 |
| ២៩. ការរៀបចំសួនផ្កាលម្អ ការដាំកូនឈើដើមឈើហូបផ្លែឬប្រភេទផ្កាដើមធំ បានស្អាតនិងត្រឹមត្រូវមានសោភ័ណភាពល្អ និងមានការថែទាំជាប្រចាំ | 3.75 | .84 | 1.8 | 10.2 | 9.2 | 68.0 | 10.8 |

**ចំណាំ៖**1=SD មិនយល់ស្របសោះ 2=D មិនយល់ស្រប 3=Nគ្មានយោបល់ 4=Aយល់ស្រប 5=SAយល់ស្របទាំងអស់

១.០០ ដល់ ២.៤៩ កម្រិតទាប ២.៥០ ដល់ ៣.៤៩ កម្រិតមធ្យម ៣.៥០ ដល់ ៥.០០ កម្រិតខ្ពស់

### *៤.១.៣.៤ ទីតាំងលេងកម្សាន្ត ចំណតយានជំនិះ និងទីតាំងដាក់ធុងសំរាម*

លទ្ធផលក្នុងតារាង៤.១.៣.៤ បានបង្ហាញថាធុងសំរាមមានគ្រប់គ្រាន់ និងមានសរសេរជាអក្សរ និងមានបិទស្លាកសញ្ញាច្បាស់លាស់បានរៀបចំទុកដាក់មានរបៀបរៀបរយ និងមានសណ្តាប់ធ្នាប់ល្អដែលមានកម្រិតនៃការយល់ស្របដល់មធ្យមភាគ (៣.៩៤)។

ដោយឡែកចំណតសម្រាប់ចតយាន្តជំនិះគ្រប់ប្រភេទ ត្រូវបានរៀបចំមានរបៀបរៀបរយដែលមានបរិស្ថាន និងអនាម័យល្អដែលកម្រិតនៃការយល់ស្របចំនួន(៣.៨៧) ទីតាំងលេងកម្សាន្តមានផាសុកភាពអនាម័យល្អ មានការបែងចែកប្រភេទធុងសំរាម (ធុងសំរាមប្លាស្ទិក និងក្រដាស) និងបរិស្ថានល្អ ចំពោះការមានទីតាំងលេងកីឡាមានផាសុកភាពអនាម័យល្អ និងបរិស្ថានល្អ តែហាក់បីដូចជាមានការខ្វះចន្លោះការសម្អាតទីតាំងកីឡាជាប្រចាំ។

តារាង ៤.១.៣.៤ *ទីតាំងលេងកម្សាន្ត ចំណតយានជំនិះ និងទីតាំងដាក់ធុងសំរាម*

| បរិយាយ | ចំនួនអ្នកឆ្លើយសំណួរតាមកម្រិត | | | | | | |
|---|---|---|---|---|---|---|---|
| | | | 1 | 2 | 3 | 4 | 5 |
| | មធ្យម | គម្លាតស្តង់ដារ | SD | D | N | A | SA |
| ៣០.ទីតាំងលេងកីឡាមានផាសុកភាពអនាម័យល្អ និងបរិស្ថានល្អ | 3.72 | .94 | 2.5 | 11.8 | 10.6 | 60.0 | 15.1 |
| ៣១.ការសម្អាតទីតាំងកីឡាជាប្រចាំ (គ្មានសំរាម ឬថង់ប្លាស្ទិក) | 3.71 | .94 | 3.1 | 11.4 | 9.8 | 62.5 | 13.1 |
| ៣២.ទីតាំងលេងកម្សាន្តមានផាសុកភាពអនាម័យល្អ និងបរិស្ថានល្អ | 3.81 | .84 | 2.4 | 7.6 | 8.4 | 68.0 | 13.5 |
| ៣៣.ចំណតសម្រាប់ចតយាន្តជំនិះគ្រប់ប្រភេទបានរៀបចំមានរបៀប មានបរិស្ថាន និងអនាម័យល្អ | 3.87 | .79 | 2.2 | 5.3 | 9.4 | 69.2 | 13.9 |
| ៣៤.ធុងសំរាមមានគ្រប់គ្រាន់ និងមានសរសេរជាអក្សរ និងមានបិទស្លាកសញ្ញាច្បាស់លាស់បានរៀបចំទុកដាក់មានរបៀបរៀបរយ និងមានសណ្តាប់ធ្នាប់ល្អ | 3.94 | .78 | 1.6 | 5.7 | 7.1 | 67.6 | 18.0 |
| ៣៥.ការបែងចែកប្រភេទធុងសំរាម (ធុងសំរាមប្លាស្ទិក និងក្រដាស) | 3.79 | .88 | 0.4 | 12.4 | 12.2 | 57.5 | 17.6 |

**ចំណាំ៖**1=SDមិនយល់ស្របសោះ 2=Dមិនយល់ស្រប 3=Nគ្មានយោបល់ 4=Aយល់ស្រប 5=SAយល់ស្របទាំងអស់

១.០០ ដល់ ២.៤៩ កម្រិតទាប ២.៥០ ដល់ ៣.៤៩ កម្រិតមធ្យម ៣.៥០ ដល់ ៥.០០ កម្រិតខ្ពស់

### *៤.១.៣.៥ ការគ្រប់គ្រងសំណល់ (ការវេចខ្ចប់ និងប្រមូលសំរាម)*

លទ្ធសិក្សាក្នុងក្រាហ្វិកបានបង្ហាញឱ្យឃើញថា សំណល់រឹងត្រូវបានរក្សាទុកនៅក្នុងធុងសំរាមត្រឹមត្រូវ ឬចងមាត់ថង់ឱ្យជិតមុនពេលភ្នាក់ងារប្រមូលមកប្រមូល និងមានការប្រមូលសំណល់រឹងជាប្រចាំនៅក្នុងបរិវេណសាលារៀន ថែមទាំងមានទីតាំងស្តុកសំរាមស្ថិតនៅឆ្ងាយពីកន្លែងអគារសិក្សា សួនច្បារ និងចំណត។ ប៉ុន្តែតាមសាលារៀននីមួយៗហាក់ដូចជាសំណល់រាវត្រូវបង្ហូរទៅក្នុងប្រព័ន្ធមេលូធំ ឬទីតាំងសំរាមស្តុកសំណល់រាវនៅមានទាន់មានភាពប្រសើរនៅឡើយ។

ក្រាហ្វិក៤.១.៣.៥ ការគ្រប់គ្រងសំណល់ (ការវេចខ្ចប់ និងប្រមូលសំរាម)




| | 36 | | 37 | | 38 | | 39 | |
|---|---|---|---|---|---|---|---|---|
| មិនយល់ស្របទាំងស្រុង | 12 | 2.4% | 9 | 1.8% | 9 | 1.8% | 8 | 1.6% |
| មិនយល់ស្រប | 33 | 6.5% | 43 | 8.4% | 50 | 9.8% | 72 | 14.1% |
| គ្មានយោបល់ | 58 | 11.4% | 61 | 12.0% | 45 | 8.8% | 71 | 13.9% |
| យល់ស្រប | 332 | 65.1% | 310 | 60.8% | 336 | 65.9% | 308 | 60.4% |
| យល់ស្របទាំងស្រុង | 75 | 14.7% | 87 | 17.1% | 70 | 13.7% | 51 | 10.0% |

**សំគាល់៖**

៣៦.ការប្រមូលសំណល់រឹងជាប្រចាំនៅក្នុងបរិវេណសាលារៀន

៣៧.សំណល់រឹងត្រូវបានរក្សាទុកនៅក្នុងធុងសំរាមត្រឹមត្រូវ ឬចងមាត់ថង់ឱ្យជិតមុនពេលភ្នាក់ងារប្រមូលមកប្រមូល

៣៨.ទីតាំងស្តុកសំរាមស្ថិតនៅឆ្ងាយពីកន្លែងអគារសិក្សា សួនច្បារ និងចំណត

៣៩.សំណល់រាវត្រូវបង្ហូរទៅក្នុងប្រព័ន្ធមេលូធំ ឬទីតាំងសំរាមស្តុកសំណល់រាវ

### *៤.១.៣.៦.អនាម័យចំណីអាហារ*

តាមរយៈក្រាហ្វិកខាងលើបានបង្ហាញថា នៅតាមសាលារៀននីមួយមានការចំអិនចំណីអាហារបានឆ្អិនល្អ និងអនាម័យ ចំពោះអាហារសម្រាប់លក់ឱ្យសិស្សជាអាហារដែលមានគុណភាពល្អចំណីអាហារត្រូវបានរក្សាទុក និងវេចខ្ចប់ឱ្យបានត្រឹមត្រូវ មានអនាម័យល្អ និងបន្លែ ផ្លែឈើត្រូវមានគុណភាពល្អ និងធ្វើការសម្អាតឱ្យបានស្អាតល្អ ថែមទាំងចំណីអាហារគ្មានសារធាតុគីមី និងមានគុណភាពល្អ។ សបញ្ជាក់ឱ្យឃើញថាតាមសាលានីមួយៗមានការយកចិត្តទុកដាក់ចំពោះអនាម័យចំណីអាហារ។

៤.១.៣.៦ *អនាម័យចំណីអាហារ*




| | 40 | | 41 | | 42 | | 43 | | 44 | |
|---|---|---|---|---|---|---|---|---|---|---|
| គ្មានយោបល់ | 22 | 4.3% | 30 | 5.9% | 28 | 5.5% | 26 | 5.1% | 31 | 6.1% |
| មិនយល់ស្រប | 22 | 4.3% | 36 | 7.1% | 34 | 6.7% | 39 | 7.6% | 27 | 5.3% |
| មិនយល់ស្របទាំងស្រុង | 15 | 2.9% | 14 | 2.7% | 19 | 3.7% | 14 | 2.7% | 11 | 2.2% |
| យល់ស្រប | 303 | 59.4% | 296 | 58.0% | 324 | 63.5% | 342 | 67.1% | 347 | 68.0% |
| យល់ស្របទាំងស្រុង | 148 | 29.0% | 134 | 26.3% | 105 | 20.6% | 89 | 17.5% | 94 | 18.4% |

**សំគាល់៖**

៤០.ការចំអិនចំណីអាហារបានឆ្អិនល្អ និងអនាម័យ អាហារសម្រាប់លក់ឱ្យសិស្សជាអាហារដែលមានគុណភាពល្អ

៤១.កន្លែងទទួលទានអាហារត្រូវមានអនាម័យល្អ ផាសុកភាពគ្មានរុយរោម គ្មានធូលីដី គ្មានក្លិនមិនល្អ គ្មានសត្វចិញ្ចឹមដើរទៅមក

៤២.ចំណីអាហារគ្មានសារធាតុគីមី និងមានគុណភាពល្អ

៤៣.បន្លែ ផ្លែឈើត្រូវមានគុណភាពល្អ និងធ្វើការសម្អាតឱ្យបានស្អាតល្អ

៤៤. ចំណីអាហារត្រូវបានរក្សាទុក និងវេចខ្ចប់ឱ្យបានត្រឹមត្រូវ មានអនាម័យល្អ

### *៤.១.៣.៧ ការប្រើប្រាស់ទឹកស្អាត ការបំពុលដោយសារក្លិន និងការបំពុលដោយផ្សេង*

ក្រាហ្វិកខាងក្រោមបានបង្ហាញថា ទឹកស្អាតមានសម្រាប់ការប្រើប្រាស់គ្រប់គ្រាន់នៅក្នុងសាលារៀន មានការបំបាត់ក្លិនស្អុយដែលចេញពីបង្គន់អនាម័យ ឬកន្លែងធ្វើម្ហូបអាហារនៅក្នុងបរិវេណសាលារៀន និងបន្ទប់សិក្សា ឬកន្លែងលក់អាហារ ឬកន្លែងស្តុកសំរាម និងទឹកស្អាតដែលប្រើប្រាស់ត្រូវបានឆ្លងកាត់ការត្រួតពិនិត្យបានត្រឹមត្រូវ និងជាទឹកដែលមានគុណភាពល្អ។

ក្រាហ្វិក៤.១.៣.៧ *ការប្រើប្រាស់ទឹកស្អាត ការបំពុលដោយសារក្លិន និងការបំពុលដោយផ្សេង*




| | 45 | | 46 | | 47 | | 48 | | 49 | |
|---|---|---|---|---|---|---|---|---|---|---|
| មិនយល់ស្របទាំងស្រុង | 6 | 1.2% | 8 | 1.6% | 17 | 3.3% | 32 | 6.3% | 15 | 2.9% |
| មិនយល់ស្រប | 15 | 2.9% | 41 | 8.0% | 56 | 11.0% | 160 | 31.4% | 59 | 11.6% |
| គ្មានយោបល់ | 20 | 3.9% | 63 | 12.4% | 53 | 10.4% | 83 | 16.3% | 57 | 11.2% |
| យល់ស្រប | 394 | 77.3% | 318 | 62.4% | 323 | 63.3% | 198 | 38.8% | 290 | 56.9% |
| យល់ស្របទាំងស្រុង | 75 | 14.7% | 80 | 15.7% | 61 | 12.0% | 37 | 7.3% | 89 | 17.5% |

**សំគាល់៖**

៤៥.ទឹកស្អាតមានសម្រាប់ការប្រើប្រាស់គ្រប់គ្រាន់នៅក្នុងសាលារៀន

៤៦.ទឹកស្អាតដែលប្រើប្រាស់ត្រូវបានឆ្លងកាត់ការត្រួតពិនិត្យបានត្រឹមត្រូវ និងជាទឹកដែលមានគុណភាពល្អ

៤៧.ការបំបាត់ក្លិនស្អុយដែលចេញពីបង្គន់អនាម័យ ឬកន្លែងធ្វើម្ហូបអាហារនៅក្នុងបរិវេណសាលារៀន និងបន្ទប់សិក្សា ឬកន្លែងលក់អាហារ ឬកន្លែងស្តុកសំរាម

៤៨.ការបំពុលដោយផ្សេងតាមរយៈការដុតចង់ប្លាស្ទិក ឬសំរាមនៅក្នុងបរិវេណ

៤៩.បិតស្លាកសញ្ញាបំរាម ហាមជក់បារីមានបិទនៅក្នុងទីធ្លាសាលារៀន និងក្នុងបន្ទប់រៀន ទីធ្លាសាលារៀន និងបន្ទប់គ្មានផ្សែង។

### ៤.១.៣.៨ *សុខុមាលភាពគ្រូសិស្សនិងបុគ្គលិកអប់រំផ្សេងទៀត*

លទ្ធផលក្នុងក្រាហ្វិកខាងក្រោមបានបង្ហាញឱ្យឃើញថា តាមសាលារៀននីមួយៗ មានបន្ទប់សិក្សាដែលមានសម្ភារៈគ្រប់គ្រាន់ មានបន្ទប់សង្គ្រោះបឋមបានរៀបចំសមស្រប និងសម្ភារៈសង្គ្រោះបឋមគ្រប់គ្រាន់ និងក្រុមសង្គ្រោះបឋមផងដែរ។

ក្រាហ្វិក៤.១.៣.៨ *សុខុមាលភាពគ្រូសិស្សនិងបុគ្គលិកអប់រំផ្សេងទៀត*




| | មិនយល់ស្របទាំងស្រុង | មិនយល់ស្រប | គ្មានយោបល់ | យល់ស្រប | យល់ស្របទាំងស្រុង |
|---|---|---|---|---|---|
| 51 | 2.5% | 16.1% | 15.1% | 54.7% | 11.6% |
| 50 | 3.7% | 12.0% | 13.1% | 51.2% | 20.0% |

**សំគាល់៖**

៥០.បន្ទប់សង្គ្រោះបឋមបានរៀបចំសមស្រប និងសម្ភារៈសង្គ្រោះបឋមគ្រប់គ្រាន់

៥១.ក្រុមសង្គ្រោះបឋមមានប្រចាំការរាល់ថ្ងៃ

### *៤.១.៣.៩ អត្តសញ្ញាណមន្ត្រីរាជការ*

ការយល់ឃើញរបស់គណៈគ្រប់គ្រង គ្រូ សិស្ស សហគមន៍ ចំពោះការស្លៀកពាក់សមរម្យតាមប្រពៃណីជាតិ (មិនស៊ិចស៊ីពេលបំពេញការងារ) ការគោរពម៉ោងកំណត់ក្នុងការបង្រៀន ការប្រកាន់ខ្ជាប់វប្បធម៌តម្លៃរបស់គ្រូបង្រៀន និងអនាម័យស្អាត ការបំពេញការងារ និងធ្វើការស្រាវជ្រាវជាប់ជាប្រចាំ ដើម្បីបង្កើនចំណេះដឹង ជាពិសេសមិនមានអំពើហឹង្សាគ្រប់ប្រភេទ និងសំដីអសុរសនៅក្នុងកន្លែងការងារពិតជាមានលក្ខណៈល្អប្រសើរ។

តារាង៤.១.៣.៩ *អត្តសញ្ញាណមន្ត្រីរាជការ*

| បរិយាយ | ចំនួនអ្នកឆ្លើយសំណួរតាមកម្រិត | | 1 | 2 | 3 | 4 | 5 |
|---|---|---|---|---|---|---|---|
| | មធ្យម | គម្លាតស្តង់ដារ | SD | D | N | A | SA |
| ៥២.ការស្លៀកពាក់សមរម្យតាមប្រពៃណីជាតិ (មិនស៊ិចស៊ីពេលបំពេញការងារ) | 4.09 | .70 | 0.6 | 3.5 | 6.3 | 64.7 | 24.9 |
| ៥៣.ការគោរពម៉ោងកំណត់ក្នុងការបង្រៀន | 4.07 | .61 | 0.4 | 3.3 | 3.5 | 74.1 | 18.6 |
| ៥៤.ការមិនមានអំពើហឹង្សាគ្រប់ប្រភេទ និងសំដីអសុរសនៅក្នុងកន្លែងការងារ | 3.78 | .89 | 2.7 | 9.6 | 8.0 | 65.7 | 13.9 |
| ៥៥.ការបំពេញការងារ និងធ្វើការស្រាវជ្រាវជាប់ជាប្រចាំ | 3.86 | .74 | 1.2 | 5.9 | 10.6 | 69.5 | 12.7 |
| ៥៦.ការប្រកាន់ខ្ជាប់វប្បធម៌តម្លៃរបស់គ្រូបង្រៀន និងអនាម័យស្អាត | 4.06 | .63 | 0.8 | 2.4 | 5.3 | 72.4 | 19.2 |

ចំណាំ៖1=SDមិនយល់ស្របសោះ 2=Dមិនយល់ស្រប 3=Nគ្មានយោបល់ 4=Aយល់ស្រប 5=SAយល់ស្របទាំងអស់

១.០០ ដល់ ២.៤៩ កម្រិតទាប ២.៥០ ដល់ ៣.៤៩ កម្រិតមធ្យម ៣.៥០ ដល់ ៥.០០ កម្រិតខ្ពស់

### ៤.១.៣.១០ ការចាត់តាំងអនុវត្តការងារគ្រប់គ្រងអនាម័យ និងបរិស្ថាន

ការយល់ឃើញរបស់អ្នកចូលរួមបានបង្ហាញក្នុងក្រាហ្វិកខាងលើ ថាតាមសាលាបឋមនីមួយៗការបែងចែកវេនធ្វើអនាម័យថ្នាក់ និងនៅក្នុងបរិវេណសាលារៀន និងមានការគ្រប់គ្រង អនាម័យ និងបរិស្ថានបានល្អថែមទាំងមានការដាក់វិធានការពិន័យចំពោះអ្នកមិនអនុវត្តវេនអនាម័យឬចោលសំរាមក្នុងថ្នាក់ ឬបរិវេណសាលា។

ក្រាហ្វិក៤.១.៣.១០ *ការចាត់តាំងអនុវត្តការងារគ្រប់គ្រងអនាម័យ និងបរិស្ថាន*




| | 57 | | 58 | | 59 | | 60 | |
|---|---|---|---|---|---|---|---|---|
| មិនយល់ស្របទាំងស្រុង | 11 | 2.2% | 7 | 1.4% | 4 | 0.8% | 5 | 1.0% |
| មិនយល់ស្រប | 24 | 4.7% | 34 | 6.7% | 15 | 2.9% | 28 | 5.5% |
| គ្មានយោបល់ | 17 | 3.3% | 48 | 9.4% | 12 | 2.4% | 42 | 8.2% |
| យល់ស្រប | 340 | 66.7% | 338 | 66.3% | 371 | 72.7% | 354 | 69.4% |
| យល់ស្របទាំងស្រុង | 118 | 23.1% | 83 | 16.3% | 108 | 21.2% | 81 | 15.9% |

**សំគាល់៖**

៥៧. ការគ្រប់គ្រង អនាម័យ និងបរិស្ថានបានល្អ

៥៨. ការបង្កើតក្រុមតាមដានការងារបរិស្ថាន និងអនាម័យ តាមរយៈការចូលរួមរបស់ក្រុមប្រឹក្សាយុវជន និងកុមារ

៥៩.ការបែងចែកវេនធ្វើអនាម័យថ្នាក់ និងនៅក្នុងបរិវេណសាលារៀន

៦០.ការដាក់វិធានការពិន័យចំពោះអ្នកមិនអនុវត្តវេនអនាម័យ ឬចោលសំរាមក្នុងថ្នាក់ ឬបរិវេណសាលា

### ៤.១.៤ បញ្ហាប្រឈមក្នុងការរៀបចំបរិស្ថានសិក្សា

#### *៤.១.៤.១. សារៈសំខាន់នៃការរៀបចំបរិស្ថានសិក្សាស្អាត*

ការយល់ឃើញរបស់អ្នកចូលរួមចំពោះ សារៈសំខាន់នៃបរិស្ថានសិក្សាបានលើកឡើងថា បរិស្ថានសិក្សានៅសាលាបឋមសិក្សានេះមានលក្ខណៈល្អប្រសើរ ថែមទាំងការបង្រៀន និងលទ្ធផលសិក្សារបស់សិស្សមានភាពល្អប្រសើរ ទន្ទឹមនឹងនោះសុខភាពរបស់អ្នកសិក្សាល្អ និងមានផាសុកភាពល្អ ជាពិសេសសិស្ស/គ្រូមានអារម្មណ៍ល្អ ចង់មកសាលា។

ក្រាហ្វិក៤.១.៤.១ សារៈសំខាន់នៃការរៀបចំបរិស្ថានសិក្សាស្អាត




| | 61 | | 62 | | 63 | | 64 | |
|---|---|---|---|---|---|---|---|---|
| មិនយល់ស្របទាំងស្រុង | 4 | 0.8% | 6 | 1.2% | 8 | 1.6% | 4 | 0.8% |
| មិនយល់ស្រប | 16 | 3.1% | 28 | 5.5% | 22 | 4.3% | 14 | 2.7% |
| គ្មានយោបល់ | 17 | 3.3% | 28 | 5.5% | 18 | 3.5% | 32 | 6.3% |
| យល់ស្រប | 387 | 75.9% | 386 | 75.7% | 391 | 76.7% | 338 | 66.3% |
| យល់ស្របទាំងស្រុង | 86 | 16.9% | 62 | 12.2% | 71 | 13.9% | 122 | 23.9% |

**សំគាល់៖**

៦១.ការបង្រៀន និងលទ្ធផលសិក្សារបស់សិស្សមានភាពល្អប្រសើរ

៦២.សុខភាពរបស់អ្នកសិក្សា មានផាសុកភាពល្អ

៦៣.បរិស្ថានសិក្សានៅសាលាបឋមសិក្សានេះ មានលក្ខណៈល្អប្រសើរ

៦៤. សិស្ស/គ្រូមានអារម្មណ៍ល្អ ចង់មកសាលា

### *៤.១.៤.២ បញ្ហាប្រឈមក្នុងការរៀបចំបរិស្ថានសិក្សា*

លទ្ធផលក្នុងតារាងខាងក្រោមបានបង្ហាញថា បញ្ហាប្រឈមក្នុងការរៀបចំបរិស្ថានសិក្សា កើតឡើងមកពីកត្តាសកម្មភាពសិស្ស និងសកម្មភាពគ្រូ ថែមទាំងកន្លែងលក់ដូរ និងជាពិសេសតាមសាលានីមួយៗ សំបូរព្រៃ និងស្មៅច្រើន។

តារាង៤.១.៤.២ *បញ្ហាប្រឈមក្នុងការរៀបចំបរិស្ថានសិក្សា*

| បរិយាយ | ចំនួនអ្នកឆ្លើយសំណួរតាមកម្រិត | | 1 | 2 | 3 | 4 | 5 |
|---|---|---|---|---|---|---|---|
| | មធ្យម | គម្លាតស្តង់ដារ | SD | D | N | A | SA |
| ៦៥.កត្តាធម្មជាតិ | 3.38 | 1.01 | 2.5 | 23.3 | 15.9 | 49.8 | 8.4 |
| ៦៦.កត្តាសកម្មភាពសិស្ស និងគ្រូ | 3.48 | .93 | 1.6 | 20.4 | 12.7 | 58.8 | 6.5 |
| ៦៧.កត្តាកន្លែងលក់ដូរ | 3.46 | .90 | 1.6 | 18.4 | 17.3 | 57.3 | 5.5 |
| ៦៨.កត្តាអគារសិក្សា បន្ទប់រៀនចាស់ៗ និងបាក់បែក | 3.22 | 1.03 | 2.9 | 28.6 | 18.2 | 42.9 | 7.3 |
| ៦៩.កត្តាសំបូរព្រៃ និងស្មៅច្រើន | 3.10 | 1.04 | 1.6 | 34.7 | 16.3 | 40.6 | 5.3 |
| ៧០.កង្វះសម្ភារៈរូបវន្តផ្នែកអនាម័យ | 3.28 | .99 | 2.7 | 25.7 | 18.2 | 47.5 | 5.9 |
| ៧១.ខ្វះការសហការពីសហគមន៍ពីអ្នកពាក់ព័ន្ធផ្សេងៗឱ្យទូលំទូលាយ | 3.25 | 1.01 | 3.3 | 25.7 | 19.0 | 45.7 | 6.3 |
| ៧២.កង្វះអ្នកជួយគាំទ្រ និងខ្វះថវិកា | 3.30 | 1.06 | 4.3 | 24.5 | 15.5 | 47.3 | 8.4 |
| ៧៣.បញ្ហាសំរាម និងកំណើនប្លាស្ទិក | 3.22 | 1.03 | 3.1 | 28.2 | 18.2 | 43.3 | 7.1 |

ចំណាំ៖1=SDមិនយល់ស្របសោះ 2=Dមិនយល់ស្រប 3=Nគ្មានយោបល់ 4=Aយល់ស្រប 5=SAយល់ស្របទាំងអស់

១.០០ ដល់ ២.៤៩ កម្រិតទាប ២.៥០ ដល់ ៣.៤៩ កម្រិតមធ្យម ៣.៥០ ដល់ ៥.០០ កម្រិតខ្ពស់

### *៤.១.៤.៣ វិធានការ ឬវិធីសាស្ត្រក្នុងការគ្រប់គ្រងទៅលើបញ្ហាសំរាម*

លទ្ធផលដូចដែលបង្ហាញក្នុងក្រាហ្វិកខាងក្រោមបង្ហាញថា  អ្នកចូលរួមមានការយល់ឃើញថាត្រូវមានការដាក់ពិន័យចំពោះអ្នកបោះចោលសំរាមផ្ដេសផ្ដាស ការណែនាំពីបញ្ហាសំរាម និងរបៀបទុកដាក់ និងការអនុវត្ត៤ក (ការបដិសេធមិនប្រើប្រាស់ ការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ)។

តារាង៤.១.៤.៤ *វិធានការ ឬវិធីសាស្ត្រក្នុងការគ្រប់គ្រងទៅលើបញ្ហាសំរាម*




| | 74 | | 75 | | 76 | | 77 | | 78 | |
|---|---|---|---|---|---|---|---|---|---|---|
| មិនយល់ស្របទាំងស្រុង | 8 | 1.6% | 10 | 2.0% | 3 | 0.6% | 15 | 2.9% | 5 | 1.0% |
| មិនយល់ស្រប | 87 | 17.1% | 28 | 5.5% | 30 | 5.9% | 95 | 18.6% | 49 | 9.6% |
| គ្មានយោបល់ | 44 | 8.6% | 32 | 6.3% | 38 | 7.5% | 62 | 12.2% | 90 | 17.6% |
| យល់ស្រប | 307 | 60.2% | 361 | 70.8% | 353 | 69.2% | 295 | 57.8% | 308 | 60.4% |
| យល់ស្របទាំងស្រុង | 64 | 12.5% | 79 | 15.5% | 86 | 16.9% | 43 | 8.4% | 58 | 11.4% |

**សំគាល់៖**

៧៤.ការបន្ថែមចំនួនធុងសំរាម

៧៥.ការដាក់ពិន័យចំពោះអ្នកបោះចោលសំរាមផ្ដេសផ្ដាស

៧៦.ការណែនាំពីបញ្ហាសំរាម និងរបៀបទុកដាក់

៧៧.ការប្រើប្រាស់ថង់បរិស្ថាន

៧៨.ការអនុវត្ត៤ក (ការបដិសេធមិនប្រើប្រាស់ ការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ)

## ៤.២ ការពិភាក្សា

ការស្រាវជ្រាវបានស្តែងចេញនូវចំណុចសំខាន់ៗ ការរៀបចំបរិស្ថានសិក្សា និងបញ្ហាប្រឈមនានា ក្នុងការរៀបចំបរិស្ថានសិក្សា។ នៅចំណុចនេះអ្នកស្រាវជ្រាវបានសរសេរបញ្ជាក់អំពីការពិភាក្សា ទៅលើលទ្ធផលនៃការស្រាវជ្រាវ និងធ្វើការប្រៀបធៀបជាមួយនឹងការស្រាវជ្រាវតាមរយៈការរំឭកទ្រឹស្តី និងពណ៌នាអំពីទិន្នន័យដែលទទួលបានបន្ទាប់ពីធ្វើការស្រាវជ្រាវជាក់ស្តែង។

### ៤.២.១ ស្ថានភាពនៃការរៀបចំបរិស្ថានសិក្សានៅកម្រិតបឋមសិក្សា

**សំណួរស្រាវជ្រាវទី១៖** តើបរិស្ថានសិក្សានៅបឋមសិក្សាមានលក្ខណៈដូចម្តេច?

ការសិក្សានេះបានបង្ហាញថា តាមសាលារៀននីមួយៗមានការរៀបចំតុបតែងថ្នាក់រៀននូវសម្ភារៈបង្ហាញវប្បធម៌និងប្រពៃណីជាតិខ្មែរ និងការដាក់រូបព្រះឆាយាលក្ខណ៍របស់ព្រះមហាក្សត្រ មានការដាក់បាវចនាជាតិនៅក្នុងថ្នាក់រៀននីមួយៗ។ ចំពោះការណែនាំអប់រំ និងដាក់ពិន័យសិស្សដែលមិនគោរពវិន័យសាលារៀន និងពិន័យចំពោះអ្នកចោលសំរាមនៅក្នុងទីធ្លាសាលារៀនក៏មានលក្ខណៈល្អប្រសើរដែរ។

យោង Fakeye (2012) បានលើកឡើងថា បរិស្ថានសិក្សាមានសារៈសំខាន់ខ្លាំងណាស់ ព្រោះថាវាមានសមត្ថភាពពង្រឹង ឬរារាំងសមត្ថភាពសិក្សារបស់សិស្ស ហើយមានការថយចុះនៃក្តីបារម្ភចំពោះធម្មជាតិនៃបរិស្ថាន ដែលការសិក្សាប្រព្រឹត្តទៅនៅប្រទេសនីហ្សេរីយ៉ា។

ក្នុងនោះផងដែរតាមសាលាបឋមសិក្សានីមួយៗ ពិតជាមានការរៀបទៅតាមចំណុចដែលមាននៅក្នុងរង្វាយតម្លៃ ផ្នែកការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន និងភាពស្អាតពិតប្រាកដមែន។ ជាពិសេសតាមបន្ទប់រៀនមានសោភ័ណភាព និងរៀបចំតុបតែងបានស្អាត និងសម្អាតប្រចាំ ថែមទាំងទឹកស្អាតមានគ្រប់គ្រាន់សម្រាប់ប្រើប្រាស់នៅក្នុងបង្គន់អនាម័យ និងមានការថែរក្សាបរិស្ថាននៅក្នុងបរិវេណសាលារៀន បានស្អាតល្អ។

ទន្ទឹមនឹងនោះ មានកន្លែងលាងដៃក្រោយចេញពីបង្គន់ និងកន្សែង ឬក្រដាស់សម្រាប់ជូតដៃ ថែមទាំងមានការរៀបចំសួនផ្កាលម្អ ការដាំកូនឈើ ដើមឈើហូបផ្លែ ឬប្រភេទផ្កាដើមធំបានយ៉ាងស្អាត និងត្រឹមត្រូវមានសោភ័ណភាពល្អ តែមានការថែទាំជាប្រចាំនៅមានចន្លោះ ជាពិសេសការតុបតែងលម្អដើម រុក្ខជាតិ

តូចៗ ឬផ្កាផ្សេងៗតាមជញ្ជាំងឬក្នុងបន្ទប់រៀន (រុក្ខជាតិតូចៗ) ដែលដាំនៅក្នុងបំពង់ឬស្សីឬក្នុងដបទឹកសុទ្ធជាដើមមានកម្រិតនៅឡើយ។

បរិស្ថានជុំវិញដែលសិស្សរៀនអាចមានឥទ្ធិពលយ៉ាងខ្លាំងលើដំណើរការសិក្សា និងសុខុមាលភាពរបស់ពួកគេទាំង បរិស្ថានខាងក្នុង/ក្រៅថ្នាក់ និងសម្ភារៈបរិក្ខាររបស់សាលាដើរតួនាទីយ៉ាងសំខាន់ក្នុងការរៀបចំបរិស្ថានសិក្សា (Teachernet, 2008)។

មួយវិញទៀតតាមសាលានីមួយ ធុងសំរាមមានគ្រប់គ្រាន់ និងមានសរសេរជាអក្សរ និងមានបិទស្លាកសញ្ញាច្បាស់លាស់ បានរៀបចំទុកដាក់មានរបៀបរៀបរយ និងមានសណ្ដាប់ធ្នាប់ល្អ តែហាក់បីដូចជាខ្វះចន្លោះការសម្អាតទីតាំងកីឡាជាប្រចាំ។ ទន្ទឹមនឹងនោះទីតាំងស្តុកសំរាមស្ថិតនៅឆ្ងាយពីកន្លែងអគារសិក្សា សួនច្បារ និងចំណតដែលធ្វើបរិស្ថានសិក្សាមានផាសុកភាព តែការប្រមូលសំណល់រឹងជាប្រចាំនៅក្នុងបរិវេណសាលារៀននៅមានកម្រិត។ យោងតាម Ijeoma (2007) បានកត់សម្គាល់ឃើញថា បរិស្ថានសិក្សាអំណោយផលអាចមានឥទ្ធិពលទាំងឥរិយាបថ និងលទ្ធផលសិក្សារបស់សិស្ស។

ក្រៅពីនោះនៅតាមសាលារៀននីមួយមានចំណីអាហារត្រូវបានរក្សាទុក និងវេចខ្ចប់ឱ្យបានត្រឹមត្រូវ មានអនាម័យល្អ និងបន្លែ ផ្លែឈើត្រូវមានគុណភាពល្អ និងធ្វើការសម្អាតឱ្យបានស្អាតល្អ ថែមទាំងចំណីអាហារគ្មានសារជាតុគីមី និងមានគុណភាពល្អ ដែលមិនមានការបង្ករជាផលប៉ះពាល់ដល់សុខភាពសិស្ស។ លើសពីនេះតាមសាលានីមួយៗ មានទឹកស្អាតសម្រាប់ការប្រើប្រាស់គ្រប់គ្រាន់នៅក្នុងសាលារៀន មានការបំបាត់ក្លិនស្អុយដែលចេញពីបង្គន់អនាម័យ ឬកន្លែងធ្វើម្ហូបអាហារនៅក្នុងបរិវេណសាលារៀន និងបន្ទប់សិក្សា ឬកន្លែងលក់អាហារ ឬកន្លែងស្តុកសំរាម និងទឹកស្អាតដែលបានប្រើប្រាស់ត្រូវបានធ្វើឆ្លងកាត់ការត្រួតពិនិត្យបានត្រឹមត្រូវ និងជាទឹកដែលមានគុណភាពល្អ។

តាមរយៈការយល់ឃើញរបស់គណៈគ្រប់គ្រង គ្រូ សិស្ស សហគមន៍ ចំពោះការស្លៀកពាក់សមរម្យតាមប្រពៃណីជាតិ (មិនសិុចស៊ីពេលបំពេញការងារ) ការគោរពម៉ោងកំណត់ក្នុងការបង្រៀន ការប្រកាន់ខ្ជាប់វប្បធម៌តម្លៃរបស់គ្រូបង្រៀន និងអនាម័យស្អាត ការមិនមានអំពើហឹង្សាគ្រប់ប្រភេទ និងសំដីអសុរសនៅក្នុងកន្លែងការងារពិតជាមានលក្ខណៈល្អប្រសើរ។ ថែមទាំងតាមសាលាបឋមសិក្សានីមួយៗមានការ

បែងចែកវេនធ្វើអនាម័យថ្នាក់ និងនៅក្នុងបរិវេណសាលារៀន ថែមទាំងមានការដាក់វិធានការពិន័យចំពោះអ្នកមិនអនុវត្តវេនអនាម័យ ឬចោលសំរាមក្នុងថ្នាក់ ឬបរិវេណសាលា។

ហេតុដូច្នេះហើយ បញ្ហាបរិស្ថានសិក្សានោះ បណ្តាលមកពីការទុកដាក់សំរាមមិនបានត្រឹមត្រូវ ដែលបុគ្គលម្នាក់ៗ មិនមានទំលាប់ស្រលាញ់ថែរក្សាបរិស្ថាន ការគ្រប់គ្រងនៅមានកម្រិត។ សិស្សពិតជាមិនមានការយល់ដឹងពីរបៀបក្នុងការបោះចោលសំរាម ដោយមិនទាន់បានធ្វើការបែងចែកសំរាមទៅតាមប្រភេទ បង្កឱ្យមានភាពពិបាកសម្រាប់ការគ្រប់គ្រង និងថែរក្សា។ យោង Waldman (2016) បានសង្កេតឃើញថា មុនពេលសិស្សអាចទទួលបានជោគជ័យក្នុងការសិក្សា ពួកគេត្រូវតែមានអារម្មណ៍ថាសុវត្ថិភាពទាំងផ្លូវកាយ និងផ្លូវចិត្ត ហើយដើម្បីឱ្យមានបរិស្ថានសិក្សាប្រកបដោយសុវត្ថិភាពសិស្សត្រូវតែមានអារម្មណ៍ ទទួលបានការស្វាគមន៍ គាំទ្រ និងគោរព។

តាមរយៈការយល់ឃើញរបស់អ្នកចូល ចំពោះការបញ្ជ្រាបការយល់ដឹងពីបរិស្ថាន តាមលទ្ធផលក្នុងតារាងបានបង្ហាញថា នៅសាលាមានដាក់ពាក្យស្លោក សុភាសិត រូបភាព គំនូរ និងពាក្យអប់រំក្នុងបរិវេណសាលារៀន ដែលទាក់ទងបរិស្ថាន ហាក់បីដូចជាមិនមានការអនុវត្តសកម្មភាពជាប្រចាំ និងរៀបចំក្លឹបបរិស្ថាននោះទេ។ យោងក្រសួងអប់រំ យុវជន និងកីឡា (២០១៧) លក្ខណៈវិនិច្ឆ័យទី២៖ ការបង្រៀនមេរៀនបរិស្ថាន និងសកម្មភាពអប់រំបរិស្ថានក្នុងសាលា និង សហគមន៍។ ដែលមានសូចនាករទី៧ កម្មវិធីសិក្សាគោល និងបន្ថែម/បញ្ជ្រាប។ សូចនាករទី ៨ កសាងនូវសមត្ថភាពរបស់គ្រូបង្រៀន។ សូចនាករទី៩ មេរៀន និងសកម្មភាពរៀនសមស្របទៅបរិបទក្នុងស្រុក តំបន់។ សូចនាករទី១0 សម្ភារៈឧបទេសបង្រៀន (ទាក់ទងបរិស្ថាន) និងសូចនាករទី១១ គឺមានក្លឹបបរិស្ថាន។

សរុបមកយោងតាមលទ្ធផលនៃការស្រាវជ្រាវ និងអ្នកស្រាវជ្រាវមុនៗបានបង្ហាញឱ្យឃើញថាសិស្សនៅសាលាបឋមសិក្សាមួយចំនួនមិនទាន់ចូលចិត្តបរិស្ថានសាលានៅឡើយទេ ដោយសារការបោះចោលសំរាមដោយមិនមានការបែងចែង និងមិនមានការយល់ដឹងពីបញ្ហាបរិស្ថាន។ ជាពិសេសបញ្ហាទាក់ទងជាមួយនឹងសំរាមនៅក្រៅធុងសំរាម តាមថ្នាក់ ក្រោយថ្នាក់ជាដើម។

### ៤.២.២ បញ្ហាប្រឈមក្នុងការរៀបចំបរិស្ថានសិក្សា

**សំណួរស្រាវជ្រាវទី២៖** តើការរៀបចំបរិស្ថានសិក្សានៅសាលាបឋមសិក្សាជួបបញ្ហាប្រឈមអ្វីខ្លះ?

ការសិក្សានេះបានបង្ហាញថា បរិស្ថានសិក្សា តាមសាលារៀនបឋមសិក្សានីមួយមានបញ្ហាប្រឈមតិចតួចក្នុងការរៀបចំបរិស្ថានសិក្សា ដែលជាហេតុងាយស្រួលសម្រាប់ការរៀបចំបរិស្ថានសិក្សាឱ្យបានល្អ។ ដោយផ្អែកទៅលើលទ្ធផលនៃការសិក្សានេះ អាចសន្និដ្ឋានបានថា បញ្ហាបរិស្ថានសិក្សាបង្កឡើងដោយសារកត្តាមួយចំនួនគឺ កើតឡើងមកពីកត្តាសកម្មភាពសិស្ស និងសកម្មភាពគ្រូ ពុំសូវមានការចូលរួម។ មួយវិញទៀតបណ្តាលមកពីកន្លែងលក់ដូរ និងជាពិសេសតាមសាលានីមួយៗសំបូរព្រៃ និងស្មៅជាច្រើន។ លើសពីនេះទៀតបញ្ហាបរិស្ថានសិក្សាចម្បងៗ ដែលកើតមាននៅតាមសាលាបឋមសិក្សាគឺ បណ្តាលមកពីបញ្ហាសំរាម កង្វះធុងសំរាម និងសំបូរដោយស្មៅ។

ដូចដែលបានបញ្ជាក់ដោយ វិទ្យាស្ថានជាតិគ្រូបង្រៀន National Teachers Institute (NTI 2008) គឺរាល់ការត្រួតពិនិត្យអនាម័យសាលារៀន អាចជួយដល់គុណភាពនៃបរិស្ថានសិក្សា។ នេះសំដៅលើយុទ្ធសាស្រ្តទាំងអស់បានអនុម័តដោយប្រព័ន្ធសាលារៀនក្នុងការគ្រប់គ្រងកាកសំណល់ និងសម្ភារៈបរិក្ខារដែលបានផ្តល់នៅក្នុងសាលា ជាពិសេស គឺការធ្វើយ៉ាងណាឱ្យបរិស្ថានសិក្សាមានពណ៌បៃតង គឺការគ្រប់គ្រងដែលផ្តល់អនាម័យ ការដាំផ្កា ដើមឈើ ការថែរក្សាស្មៅឱ្យបានល្អជាដើម ធ្វើឱ្យគុណភាពជីវិត និងបរិស្ថានសិក្សាកាន់តែមានភាពប្រសើរឡើង។

ហេតុនេះដោយសារកង្វះខាតនៃការអនុវត្តការគ្រប់គ្រងសំណល់ឱ្យបានត្រឹមត្រូវ និងការយល់ដឹងជាសាធារណៈនៅមានកម្រិតនៅឡើយ នាំឱ្យបញ្ហាសំណល់រឹងនៅតែជាសម្ពាធចំពោះបរិស្ថានមួយដ៏ធំ (Royal Kingdom of Cambodia, 2012)។

ដូច្នេះបញ្ហាសំរាម គឺបញ្ហាមួយដែលកើតមានឡើងនៅតាមសាលាបឋមសិក្សា ដែលបង្កជាភាពពិបាកក្នុងការថែរក្សាបរិស្ថានសិក្សាឱ្យបានល្អ ដែលជាហេតុនាំឱ្យមានផលប៉ះពាល់ខ្លាំងចំពោះសុខភាព។ ទន្ទឹមនឹងនេះ ផលប៉ះពាល់នៃសំរាមអាចបង្កឱ្យសោភ័ណភាពមិនអំណោយផលដល់ការសិក្សា និងបង្កជាផលប៉ះពាល់ចំពោះគុណភាពដី បង្កឱ្យពិបាកដាំដុះរុក្ខជាតិផ្សេងៗ។ សំរាមពិតជាប៉ះពាល់ខ្លាំង និងបង្កឱ្យ

បរិស្ថានសិក្សាមានបញ្ហា និងពិបាកក្នុងការរៀបចំឱ្យបានស្អាត និងប៉ះពាល់ចំពោះសុខភាពយ៉ាងខ្លាំងដូចជា បញ្ហាផ្លូវដង្ហើម ធុញថប់ និងចម្លងជំងឺផ្សេងៗ។

យោងក្រសួងបរិស្ថាន (២០២០) បានបង្ហាញពីវិធី៥យ៉ាងដើម្បីកាត់បន្ថយសំណល់ប្លាស្ទិក គឺបដិសេធការប្រើប្រាស់ កាត់បន្ថយ ប្រើប្រាស់ឡើងវិញ ឬប្រើវត្ថុជំនួស កែច្នៃឡើងវិញ និងរំលឹកអ្នកដទៃ។ ដូចដែលមានពាក្យស្លោកមួយចំនួននៅតាមសាលាបានលើកឡើងថាថ្ងៃនេះខ្ញុំមិនប្រើប្លាស្ទិកទេ លាហើយប្លាស្ទិក សាលារៀនគ្មានសំរាមផ្តើមចេញពីយើងទាំងអស់គ្នា អនាម័យល្អ បរិស្ថានល្អ នាំមកនូវសុខភាពល្អ យើងទាំងអស់គ្នាចូលរួមលប់បំបាត់ការចោលសំរាមរាយប៉ាយ និងចោលសំរាមបែប ISO គឺចោលសំរាមក្នុងធុងសំរាម។

# ជំពូក ៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

# ជំពូក ៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១ សេចក្តីសន្និដ្ឋាន

### ៤.២.១ ស្ថានភាពនៃការរៀបចំបរិស្ថានសិក្សានៅកម្រិតបឋមសិក្សា

ការស្រាវជ្រាវបានស្វែងចេញនូវចំណុចសំខាន់ៗមួយចំនួន ដែលចំពោះស្ថានភាពនៃការរៀបចំបរិស្ថានសិក្សា និងបញ្ហាប្រឈមក្នុងការរៀបចំបរិស្ថានសិក្សា។ ក្រោយពីបានធ្វើការសិក្សាស្រាវជ្រាវ និងវិភាគទិន្នន័យស្តីពី "ទស្សនៈរបស់នាយក គ្រូ សិស្ស និងសហគមន៍ចំពោះការរៀបចំបរិស្ថានសិក្សានៅកម្រិតបឋមសិក្សាក្នុងខេត្តតាកែវ" រួចមកលទ្ធផលបានបង្ហាញឱ្យឃើញថាសិស្សមានអារម្មណ៍សប្បាយរីករាយ យល់ច្បាស់ពីតម្រូវការ និងភាពចាំបាច់នៃបរិស្ថានសិក្សា មានការយកចិត្តទុកដាក់ និងឱ្យតម្លៃខ្ពស់ទៅលើការបរិស្ថានសិក្សា។

ជាងនេះទៅទៀតមានការលើកឡើងថា មករៀនដោយពេញចិត្តប្រសិនបើបរិស្ថានសិក្សាល្អ។ម៉្យាងទៀតពួកគេក៏មិនសូវមានការព្រួយបារម្ភទៅលើបញ្ហាសុខភាព និងហានិភ័យផ្សេងៗ ដែលកើតមានដោយសារបញ្ហាបរិស្ថានសិក្សា ពាក្យមួយលើកឡើងថា អនាម័យល្អបរិស្ថានល្អ នាំមកនូវសុខភាពល្អ។

សរុបមកការយល់ឃើញរបស់អ្នកចូលរួម ចំពោះការរៀបចំបរិស្ថានសិក្សាល្អប្រសើរគួរជាទីមោទនៈក្រៃលែង។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ចំពោះដំណើរការរៀបចំបរិស្ថានសិក្សានៅតាមសាលាបឋមសិក្សានីមួយៗ នៅមិនទាន់ប្រព្រឹត្តទៅដោយរលូននៅឡើយទេ។

### ៤.២.២ បញ្ហាប្រឈមក្នុងការរៀបចំបរិស្ថានសិក្សា

លទ្ធផលនៃការសិក្សាក៏បានបង្ហាញផងដែរថា នៅតាមសាលានីមួយៗ មិនមានភាពខុសគ្នានោះទេចំពោះបញ្ហាការទុកដាក់សំរាម។ ផ្អែកលើលទ្ធផលនៃការសិក្សាស្រាវជ្រាវ អ្នកចូលរួមភាគច្រើនយល់ឃើញថាមានបញ្ហាសំរាម ខ្វះធុងសំរាម បរិវេណជុំវិញសំបូរព្រៃ និងស្មៅ ដែលជាបញ្ហាចម្បងមួយក្នុងដំណើរការរៀបចំបរិស្ថានសិក្សា។ រីឯការយល់ដឹងពីរបៀបទុកដាក់ និងការបែងចែកសំរាមនៅមានកម្រិត ដែលប្រការនេះអាចជះឥទ្ធិពលសោភ័ណភាព សុខភាព បរិយាកាសសិក្សា និងរំខានដល់ការរៀនរបស់សិស្ស។

បន្ថែមពីលើនេះទៀត លទ្ធផលនៃការសិក្សាស្រាវជ្រាវខាងលើក៏បានបង្ហាញផងដែរថា អ្នកចូលរួមជាច្រើនយល់ឃើញថាបញ្ហាសំរាម និងកំណើនប្លាស្ទិក ជាបញ្ហាចម្បងដែលត្រូវដោះស្រាយ ហើយមួយចំនួនទៀតយល់ឃើញថា ប្រសិនបើបរិស្ថានស្អាត គឺបង្កើនសោភ័ណភាពបរិស្ថានសិក្សាដែលជាចំណែកមួយ ក្នុងការធ្វើឱ្យសិស្សចង់មកសាលារៀនផងដែរ។ ក្នុងនោះផងដែរក៏មានការលើកឡើងពី បញ្ហាដែលបណ្ដាលមកពីកត្តាសកម្មភាពសិស្ស និងគ្រូមួយចំនួនដែលមិនបានចូលរួម។ លើសពីនេះទៀតបណ្ដាលមកពីកង្វះការចូលរួមពីសំណាក់អ្នកលក់ដូរនៅតាមសាលានីមួយៗ

សរុបសេចក្ដីមក អ្នកចូលរួមមានការយល់ឃើញល្អប្រសើរហើយចំពោះការរៀបចំបរិស្ថានសិក្សាក៏ប៉ុន្តែមិនទាន់គ្រប់គ្រាន់នៅឡើយទេ។ ដោយហេតុបញ្ហាប្រឈមមួយចំនួនដែលមានដូចជា បញ្ហាសំរាម និងកំណើនប្លាស្ទិក កង្វះធុងសំរាម ការចូលរួម និងការយល់ដឹងពីបរិស្ថានសិក្សាមិនទាន់ទូលំទូលាយ។ ថែមទាំងកង្វះឯកសារស្រាវជ្រាវផ្សេងៗ និងសម្ភារៈដែលបម្រើឱ្យការរៀបចំបរិស្ថានសិក្សា ដែលជាកត្តាជះឥទ្ធិពលមិនល្អដល់ការសិក្សារបស់សិស្ស។

## ៥.២ សំណូមពរ

ដើម្បីរួមចំណែកក្នុងការលើកស្ទួយគុណភាព និងប្រសិទ្ធភាពនៃរៀបចំបរិស្ថានសិក្សាក៏ដូចជាការចូលរួមមួយផ្នែកក្នុងការលើកកម្ពស់គុណភាពអប់រំនៅកម្ពុជាទាំងមូល អ្នកសិក្សាសូមលើកនូវសំណូមពរមួយចំនួនដល់គណៈគ្រប់គ្រងសាលា ក្រសួងអប់រំ យុវជន និងកីឡា អ្នកពាក់ព័ន្ធនានា ក៏ដូចជាអ្នកសិក្សាស្រាវជ្រាវក្រោយៗ ដើម្បីពិនិត្យកែលម្អ ដោះស្រាយទៅតាមស្ថានភាព និងលទ្ធភាពជាក់ស្ដែងដូចតទៅៈ

### ៥.២.១ មន្ទីរអប់រំ យុវជន និងកីឡា

បរិស្ថានសិក្សា គឺជាផ្នែកមួយយ៉ាងសំខាន់ដែល តាមសាលារៀននីមួយៗ ត្រូវតែយកចិត្តទុកដាក់ក្នុងការរៀបចំ និងថែរក្សាឱ្យបានល្អ។ ដើម្បីចូលរួមចំណែកនូវក្នុងការលើកស្ទួយ នៃគុណភាពការរៀបចំបរិស្ថានសិក្សា ដោយមន្ទីរអប់រំ យុវជន និងកីឡា គួរតែមានយន្តការ និងបទបញ្ជាផ្សេងៗឱ្យតាមសាលានីមួយៗបានអនុវត្ត ក្នុងការរៀបចំបរិស្ថានសិក្សាឱ្យបានល្អប្រសើរ។ ក្រៅពីនេះគួរតែមានការចុះត្រួតពិនិត្យ ឬបង្កើតជាគណៈកម្មការខាងបរិស្ថានសិក្សា ដើម្បីមានការចូលរួមពីសំណាក់សាលារៀននីមួយៗ។

### ៥.២.២ ចំពោះគណៈគ្រប់គ្រងសាលា

ជាការពិតណាស់ ការបំពេញកិច្ចការជាគណៈគ្រប់គ្រងសាលាមិនងាយមនុស្សគ្រប់គ្នាអាចធ្វើទៅបានគ្រប់គ្នានោះទេរឹតតែលំបាកនោះ គឺការគ្រប់គ្រងមនុស្ស។ ជាមួយនឹងបញ្ហាក្នុងការរៀបចំបរិស្ថានសិក្សានេះ សូមគណៈគ្រប់គ្រងសាលាមេត្តាស្វែងយល់បន្ថែមទៀតអំពីសារៈសំខាន់នៃបរិស្ថានសិក្សាស្អាត បញ្ហាប្រឈមអ្វីខ្លះដែលកើតមានឡើង នៅសាលាបឋមសិក្សាទាំងមូល ដែលនាំឱ្យបរិស្ថានសិក្សាមិនមានភាពល្អប្រសើរ។

ជាមួយគ្នានេះដែរ សូមជួយជំរុញលោកគ្រូ អ្នកគ្រូ សិស្សានុសិស្សឱ្យស្រលាញ់ថែរក្សា បរិស្ថានសិក្សាទាំងអស់គ្នាដើម្បីពួកគេបានចូលជួយគាំទ្របានទាន់ពេលវេលាមុនពេល។ បន្ថែមពីនេះទៀត សូមជួយជំរុញដល់លោកគ្រូអ្នកគ្រូ និងសិស្សានុសិស្សកាត់បន្ថយការបោះចោលសំរាម ប្រើប្រាស់ថង់បរិស្ថាន និងដបផ្ទាល់ខ្លួន។ ជាពិសេសបង្កើតច្បាប់ ឬវិន័យឱ្យបានតឹងរឹងទៅលើអ្នកបោះចោលសំរាម ឬធ្វើសកម្មភាពដែលប៉ះពាល់ដល់បរិស្ថានសិក្សា ការបន្ថែមចំនួនធុងសំរាមនៅកន្លែងអាហារដ្ឋាន តាមថ្នាក់រៀនជាដើម។ គួរមានការដាក់ពិន័យចំពោះអ្នកមិនគោរពវិន័យ ក្នុងការបោះចោលសំរាម រៀបចំកន្លែងទុកដាក់ម៉ូតូឱ្យមានសណ្ដាប់ធ្នាប់ ធ្វើការដុតសំរាមនៅក្នុងឡដើម្បីជៀសវាងរំខានដល់ការសិក្សា។

កាន់តែពិសេសមានបន្ថែមពាក្យស្លោកពីបរិស្ថានសិក្សា និងបង្កើតគោលការណ៍ផ្សេងៗ កំណត់ពេលវេលាច្បាស់លាស់សម្រាប់សិស្សចូលរួមថែរក្សាបរិស្ថានសិក្សា និងបន្ថែមសម្ភារៈដែលជាជំនួយដល់ការសម្អាតបរិស្ថាន។ បង្កើតឱ្យមានការប្រកួតប្រជែងផ្សេងៗទាក់ទងបរិស្ថានសិក្សា២ដងក្នុងមួយឆ្នាំ និងមានការលើកទឹកចិត្តចំពោះអ្នកដែលមិនប្រើប្រាស់ប្លាស្ទិកក្នុងសាលា។ គួរតែកាប់ឆ្ការព្រៃនៅក្រោយថ្នាក់ និងជួសជុលបន្ទប់ទឹកដែលខូចៗ។ មួយវិញទៀតនោះ ម្នាក់ៗត្រូវមានទំនួលខុសត្រូវចំពោះសំរាមរបស់ខ្លួន បន្ថែមសកម្មភាពដែលទាក់ទងជាមួយការថែរក្សាបរិស្ថានសិក្សា។ បង្កើនការយកចិត្តទុកដាក់ចំពោះបញ្ហាសំរាម និងបន្ថែមចំនួនធុងសំរាម បង្កើនការធ្វើពលកម្មឱ្យបានម្ដង ទៅពីរដងក្នុងមួយសប្ដាហ៍ ដើម្បីទាក់ទាញចំណាប់អារម្មណ៍សិស្សឱ្យមានការស្វែងយល់ពីបញ្ហាបង្កឱ្យមានផលប៉ះពាល់ចំពោះបរិស្ថានសិក្សា។

### ៥.២.៣ ចំពោះគ្រូ

លោកគ្រូ អ្នកគ្រូ សូមចូលរួមសហការជាមួយគណៈគ្រប់គ្រងសាលាគ្រប់សម្មភាពចំពោះការគ្រប់គ្រងបរិស្ថានសិក្សា បង្រៀនសិស្សផ្សារភ្ជាប់ជាមួយនឹងបរិស្ថាន វិន័យ អនាម័យ សណ្តាប់ធ្នាប់ និងមានការណែនាំសិស្សបញ្ហានៃបរិស្ថានសិក្សា។ ចូលរួមដឹកនាំសិស្ស សម្អាតបរិស្ថាន និងថែរក្សាការពារបរិស្ថានសាលារៀន ថែមទាំងចូលរួមសហការជាមួយគណៈគ្រប់គ្រងក្នុងការផ្សព្វផ្សាយ កៀរគរអាណាព្យាបាលសិស្ស សហគមន៍ អង្គការនានាចូលរួមអភិវឌ្ឍ កែលម្អបរិស្ថានសិក្សា។

បង្រៀនសិស្សអំពីរបៀបកាត់បន្ថយការប្រើប្រាស់ឡើងវិញ ការកែច្នៃ និងការបែងចែកនូវសំរាម ជាពិសេសមានការពិន័យ ឬដាក់ទណ្ឌកម្មចំពោះអ្នកបោះសំរាមផ្តេសផ្តាស លើកទឹកចិត្តឱ្យសិស្សានុសិស្សមានការកែច្នៃ និងមានការតាំងពិព័រណ៍ស្នាដៃរបស់សិស្សចំពោះផលិតផលកែច្នៃពីសំរាម។ ការថែរក្សានូវបរិស្ថានសិក្សាប្រៀបបាន និងការបង្កើតបរិយាកាសសិក្សាមួយប្រកបដោយផាសុខភាពដែលមិនប៉ះពាល់ដល់ការសិក្សា។

### ៥.២.៤ ចំពោះសិស្ស

សិស្សគួរខិតខំសង្វាតក្នុងការសិក្សា ការចូលរួមយ៉ាងសកម្មក្នុងសកម្មភាពនានាក្នុង សាលាបានចេះរៀបចំខ្លួនជាកូនល្អ សិស្សល្អ មិត្តល្អ និងពលរដ្ឋល្អ ពិសេសជាងនេះទៅទៀត សិស្សពូកែៗគួរចេះរៀនសូត្រពីគ្នាចែករំលែកគ្នា និងផ្តល់ការគោរពដល់គ្រូ។ ក្នុងនាមសិស្សានុសិស្សត្រូវថែរក្សាបរិស្ថានសិក្សាទាំងអស់គ្នា និងណែនាំអ្នកជុំវិញ ដោយមិនត្រូវបោះចោលសំរាមក្រៅធុង ព្រោះប្រសិនបើបរិស្ថានស្អាត គឺសុខភាពល្អ។ សូមចូលរួមសហការជាមួយសាលារៀន លោកគ្រូ អ្នកគ្រូ ថ្នាក់ដឹកនាំសាលារៀន ជាពិសេសគឺចូលរួមគោរពវិន័យ និងបទបញ្ជាផ្ទៃក្នុងរបស់សាលារៀន ធ្វើអនាម័យ សណ្តាប់ធ្នាប់ និងចូលរួមថែរក្សាការពារបរិស្ថានសិក្សា។ ព្រមទាំងការចូលរួមថែរក្សា ការពារទ្រព្យសម្បត្តិសាលា និងជួយផ្សព្វផ្សាយអំពីគុណតម្លៃរបស់បរិស្ថានសិក្សា។

សិស្សត្រូវមានទំនួលខុសត្រូវខ្ពស់ចំពោះសំរាមរបស់ខ្លួន និងសកម្មភាពរបស់ខ្លួនចំពោះបរិស្ថានសិក្សា។ ត្រូវចូលរួមថែរក្សា ការពារបរិស្ថានសិក្សា ឱ្យកាន់តែល្អប្រសើរជាងមុន និងត្រូវមានស្មារតីភ្ជាក់

លើកចំពោះការស្រលាញ់បរិស្ថានជុំវិញខ្លួន និងមានការអនុវត្តទៅតាមយុទ្ធនាការរបស់ក្រសួងបរិស្ថានក្រោមប្រធានបទ ថ្ងៃនេះខ្ញុំ មិនប្រើថង់ប្លាស្ទិក និងលាហើយប្លាស្ទិក។

### ៥.២.៥ ចំពោះសហគមន៍

គួរចូលរួមជំរុញកូនៗឱ្យចូលរួមសកម្មភាពនានាក្នុងសាលាឱ្យបានសកម្ម ជាមួយគ្នានេះសូមមាតាបិតាជួយសម្របសម្រួលកូនៗឱ្យមានការស្រលាញ់ថែរក្សាបរិស្ថានទាំងនៅក្នុងសាលា និងនៅផ្ទះ ដើម្បីទទួលបានសុខភាពល្អ។ កាន់តែពិសេសជាងនេះទៅទៀតបណ្តុះស្មារតីសិស្សឱ្យមានការខ្វាយខ្វល់ពីបញ្ហាសំរាម និងបរិស្ថានដែលខ្លួនរស់នៅ មិនថានៅផ្ទះឬនៅសាលា គឺត្រូវតែស្អាតជានិច្ច។ ឱ្យស្របទៅតាមពាក្យមួយបានលើកឡើងថា មាតាបិតាសិស្សចូលរួមថែរក្សាបរិស្ថានសិក្សានៅតាមសាលា ដូចជាជួយដល់កូនៗឱ្យសុខភាពល្អ។

ជាពិសេសបញ្ហាសំរាមត្រូវស្វែងយល់ពីរបៀបនៃការទុកដាក់ និងអនុវត្តន៍ ៤ក (ការបដិសេធមិនប្រើប្រាស់ការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ)។

### ៥.២.៦ អ្នកសិក្សាជំនាន់ក្រោយ

ដោយសារតែការសិក្សាស្រាវជ្រាវនេះធ្វើឡើងតែនៅក្នុងខេត្តតាកែវ ដែលមានចំនួន៣ស្រុក គឺនៅស្រុកអង្គរបុរី ស្រុកព្រៃកប្បាស និងស្រុកត្រាំកក់ តែប៉ុណ្ណោះ ដូចនេះវាមានលក្ខណៈតូចចង្អៀតនៅឡើយ។ ដូច្នេះអ្នកសិក្សាក្រោយៗមានបំណងសិក្សាលើប្រធានបទនេះឬស្រដៀងគ្នានេះគួរតែពង្រីកវិសាលភាពនៃការស្រាវជ្រាវឱ្យកាន់តែទូលំទូលាយជាងនេះ។

